**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីរឹបអូសដាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

រៀបរៀងដោយ

និស្សិតៈ **លោក ព្រហ្ម សៀងហៃ**

**កញ្ញា មួន ស្រីខេង**

សាស្ត្រាចារ្យណែនាំៈ

លោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត**

សម្រាប់ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្ដីថ្លែងអំណរគុណ**

នាងខ្ញុំ **មួន ស្រីខេង** និងខ្ញុំបាទ **ព្រហ្ម សៀងហៃ** ជានិស្សិតថ្នាក់នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ លេខកូដថ្នាក់L4C5 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជាជ្រៅបំផុតជូនចំពោះ**

១.អ្នកម្ដាយ **ម៉ែន ផល្លា** និងក្រុមគ្រួសារទាំងអស់។

២.លោកឪពុក **ឡុង សារ៉ុម** និងអ្នកម្ដាយ **ព្រហ្ម សុម៉ាលី**។

សូមសម្ដែងនូវភាពគោរព និងដឹងគុណជាទីបំផុត ដែលបានបង្កើត ព្រមទាំងបំពេញករណីកិច្ចជាឪពុកម្ដាយដ៏មានព្រហ្មវិហារធម៌សម្រាប់យើងខ្ញុំ និងតស៊ូអោយកូនទទួលនូវអ្វីដែលល្អៗ ផ្ដល់អោយកូនទទួលបានការសិក្សាអប់រំតាំងពីថ្នាក់តូចរហូតដល់ថ្នាក់ធំ ដោយលោកទាំងពីរបានប្រៀមប្រដៅ ជ្រោមជ្រែង គាំទ្រជាកំលាំងចិត្ត ទំនុកបម្រុងទាំងប្រាក់កាក សម្ភារៈសិក្សា និងការផ្គត់ផ្គង់ផ្សេងៗទៀតជាច្រើន ចំពោះគុណបំណាច់យ៉ាងធំធេងនេះ យើងខ្ញុំមិនអាចភ្លេចបានឡើយ។

សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ** គ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ឱកាសឱ្យយើងខ្ញុំទទួលបានការសិក្សាដ៏ល្អឥតខ្ចោះ ហើយតែងតែខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត មិនបានខ្វល់ពីសុខភាពឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសជូនលោកគ្រូសាស្ត្រាចារ្យ **ម៉ម ចាន់ណែត** ជាសាស្ត្រាចារ្យណែនាំសារណា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ ណែនាំ ត្រួតពិនិត្យ និងព្យាយាមក្នុងការកែលម្អកិច្ចការស្រាវជ្រាវនេះ តាំងពីចំណុចចាប់ផ្ដើមរហូតដល់បញ្ចប់កិច្ចការ ហើយទទួលបានផលជាទីគាប់ចិត្ត។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយទាំងពួង ដែលមានបារមីនៅលើលោកនេះ សូមមេត្តាបីបាច់ថែរក្សាអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំង លោកគ្រូសាស្ត្រាចារ្យ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់ជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើន និងពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងអំឡុងពេលសិក្សាថ្នាក់នីតិសាស្ត្ររយៈពេល ៤ ឆ្នាំ មកនេះខ្ញុំបានយល់ដឹងអំពីការបង្កើតច្បាប់របស់រដ្ឋសភា និងព្រឹទ្ធសភាដោយគោរពទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ននេះ យើងបានសិក្សាស្វែងយល់អំពីក្រមសំខាន់ៗដែលអនុវត្តនាពេលសព្វថ្ងៃនេះ គឺក្រមព្រហ្មទណ្ឌ,នីតិវិធីព្រហ្មទណ្ឌ,ក្រមរដ្ឋប្បវេណី,នីតិវិធីរដ្ឋប្បវេណី មូលហេតុចម្បងដែលជំរុញអោយយើងខ្ញុំជ្រើសរើស ប្រធានបទស្តីពី « **នីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** » ខាងលើនេះ ព្រោះតែប្រធានបទមួយនេះស្ថិតនៅទិដ្ឋភាពក្នុងសង្គមបច្ចុប្បន្នមានការអនុវត្តជាច្រើនទាក់ទងនិងវិវាទជាច្រើន ដែលឈានដល់ការរឹបអូសជាបណ្តោះអាសន្នដោយហេតុប្រធានបទមួយនេះ វាមានលក្ខណៈលំបាកខ្លាំងសម្រាប់និស្សិតកំពុងសិក្សា ដោយពុំមានបទពិសោធន៍ក្នុងការអនុវត្ត។ កិច្ចការស្រាវជ្រាវនេះចងក្រងឡើងក្នុងបំណង ដើម្បីបង្ហាញពីខ្លឹមសារសំខាន់ៗនៅដំណាក់កាលនីមួយៗនូវការអនុវត្តនាពេលបច្ចុប្បន្ន ក្នុងផ្នែកនីតិវិធីរដ្ឋប្បវេណីផ្តោតយ៉ាងខ្លាំងលើដំណាក់កាល នៃនីតិវិធីចាត់ចែងរក្សាការពារមុននឹងឈានដល់នីតិវិធីរឹបអូសជាបណ្តោះអាសន្ន ដែលនីតិវិធីនីមួយៗមានការលើកឡើងបកស្រាយនូវមាត្រាច្បាប់ពាក់ព័ន្ធផងដែរ។

យើងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះ និងអាចជាឯកសារមួយដែលអាចជួយផ្តល់ចំណេះដឹងបន្ថែមសម្រាប់យើងខ្ញុំ និងនិស្សិតដទៃទៀតបានយល់ដឹងពាក់ព័ន្ធការរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុដល់ប្រិយមិត្តអ្នកអានអ្នកមើល រួមទាំងនិស្សិតដែលមានបំណងស្រាវជ្រាវ អោយច្បាស់ពីនីតិវិធីរឹបអូសនេះអោយកាន់តែច្បាស់ផងដែរ។ ជាបទពិសោធន៍យើងខ្ញុំផ្ទាល់ការសិក្សាក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណី គឺមានភាពលំបាកជាខ្លាំងក្នុងសិក្សា ប៉ុន្តែបើគ្មានការចង្អុលបកស្រាយពីសំណាកសាស្ត្រាចារ្យអ្នកទាំងអស់គ្នាទេ យើងខ្ញុំក៏គ្មានឱកាស ក្នុងការបង្ហាញ ឬចែករំលែកនូវចំណេះដឹងដែលទទួលបានពីការបង្រៀនយ៉ាងស្វាតស្វែង និងយកចិត្តទុកដាក់របស់សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះផងដែរ។ ហេតុនេះហើយ បើទោះបីសាណារមួយបានបង្កើតឡើងដោយការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់នូវយ៉ាងណាក្តីក៏សម្រាប់កំហុសដោយអចេតនាមួយចំនួនក៏អាចកើតមានឡើងផងដែរដូចជា ពាក្យពេចន៍ ឃ្លោងឃ្លា ស្រះប្រយោគ គឺតែងតែកើតមានឡើងជារើយៗចំពោះប្រធានបទ។ អាស្រ័យហេតុនេះ យើងខ្ញុំសូមទទួលនូវការរិះគន់ក្នុងន័យស្ថាបនា អំពីសំណាក់ សាស្ត្រាចារ្យ មិត្តនិស្សិត បងប្អូនអ្នកអានទាំងអស់គឺជាចំណែកមួយដែល ក្នុងការលម្អនូវចំណុច ដែលខុសនិងអភិវឌ្ឍខ្លួនឯងតទៅមុខទៀតឱ្យកាន់តែល្អជាងនេះបន្ថែមទៀត ។ ជាថ្មីម្តង យើងខ្ញុំទាំងពីរនាក់សូមលំអោនកាយទទួលនូវការរិះគន់ទាំងអស់ដែលយើងខ្ញុំមាន និងសូមខន្តីអភ័យទោសពីសំណាក់លោកគ្រូ/អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងបងប្អូនអ្នកអានទាំងអស់គ្នានូវភាពខ្វះ ខាតមួយ និងកំហុសឆ្គងនូវប្រការណាមួយដែលកើតមានឡើងអចេតនាពីសំណាក់យើងខ្ញុំទាំងពីរ

# មាតិកា


**សេចក្តីផ្តើម**.....១

១. លំនាំបញ្ហានៃការស្រាវជ្រាវ.....១

២. ចំណោទបញ្ហានៃការដោះស្រាយ.....១

៣. គោលបំណងនៃការស្រាវជ្រាវ.....២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.....៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ.....៣

៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ.....៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៣

**ជំពូកទី ១**

**សញ្ញាណនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**១.១. អត្ថន័យ និងគោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន**.....៤

១.១.១. អត្ថន័យនៃការរឹបអូសជាបណ្តោះអាសន្ន.....៥

១.១.២. គោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន.....៥

**១.២. ពាក្យសុំរឹបអូសជាបណ្តោះអាសន្ន**.....៦

១.២.១. អត្តសញ្ញាណរបស់ភាគី.....៧

១.២.២. ខ្លឹមសារនៃដីការក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ.....៨

១.២.២.១. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវនឹងបានរក្សាការពារ.....៩

១.២.២.២. ភាពចាំបាច់នៃរក្សាការពារ.....៩

១.២.២.៣. សេចក្តីបញ្ជាក់ដំបូង.....១០

១.២.២.៤. ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង.....១០

១.២.២.៥. ឯកសារដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ.....១១

១.២.២.៦.ឯកសារដើម្បីបញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន.....១១

១.២.៣.សោហ៊ុយ.....១២

១.២.៣.១. ពន្ធដាក់ពាក្យសុំ.....១២

១.២.៣.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ.....១៣

**១.៣. តុលាការដែលមានសមត្ថកិច្ច** ............ ១៤
១.៣.១.តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ............ ១៤
១.៣.២. សមត្ថកិច្ចតុលាការតាមទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ............ ១៥
**១.៤. អចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន** ............ ១៦
១.៤.១. អចលនវត្ថុដែលបានចុះបញ្ជី ............ ១៧
១.៤.២. អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ............ ១៨

## ជំពូកទី ២

## នីតិវិធីតុលាការពាក់ព័ន្ធនឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**២.១. ការពិនិត្យសំណុំរឿងរឹបអូសជាបណ្ដោះអាសន្ន** ............ ២០
**២.២. ការដាក់ប្រាតិភោគ** ............ ២០
២.២.១. គោលបំណងនៃការដាក់ប្រាតិភោគ ............ ២០
២.២.២. ចំនួននៃប្រាតិភោគ ............ ២១
២.២.៣. នីតិវិធីនៃការដាក់ប្រាតិភោគ ............ ២១
**២.៣. ការដាក់ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន** ............ ២២
២.៣.១. គោលបំណងនៃការដាក់ប្រាក់រំដោះ ............ ២២
២.៣.២. ចំនួននៃប្រាក់រំដោះ ............ ២៣
២.៣.៣. នីតិវិធីនៃការដាក់ប្រាក់រំដោះ ............ ២៣
**២.៤. ទម្រង់ដីការឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ............ ២៤
២.៤.១. ចំណុចដែលចាំបាច់ដើម្បីបញ្ជាក់អំពីរឿងក្ដី ............ ២៤
២.៤.២. ចំនួនទឹកប្រាក់សម្រាប់ដាក់ប្រាតិភោគ និងវិធីនៃការដាក់ប្រាតិភោគ ............ ២៥
២.៤.៣. សេចក្ដីសម្រេច ............ ២៥
២.៤.៤. ការកំណត់ជាក់លាក់នូវកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ............ ២៥
២.៤.៥. បន្ទុកនៃប្រាក់ប្រដាប់ក្ដី ............ ២៦
**២.៥. ការសម្រេចលើពាក្យសុំរបស់តុលាការ** ............ ២៧
២.៥.១. វិធីនៃការវិនិច្ឆ័យ ............ ២៧
២.៥.២. ដីកាសម្រេចតាមពាក្យសុំ ............ ២៧
២.៥.៣. ដីកាសម្រេចលើកចោលពាក្យសុំ ............ ២៨

**២.៦. ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ**....................២៩
២.៦.១. វិធីនៃការបញ្ជូនដីកា ..............................................................................................៣០
២.៦.២. ការបញ្ជូនទៅបុគ្គលដែលពាក់ព័ន្ធ ........................................................................ ៣២
**២.៧. ការអនុវត្តដីការឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ**.............................. ៣៣
២.៧.១. លក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ .............................. ៣៣
២.៧.២. ប្រភេទផ្សេងៗ នៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចនវត្ថុ ............................៣៤
២.៧.៣. ការផ្អាក និង ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ............៣៥
២.៧.៤. ការបំលែងពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ទៅជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ..........................................................................................................៣៥

## ជំពូកទី ៣

## ស្ថាប័នអនុវត្ត និងការតវ៉ាចំពោះដីកាសម្រេចរឹបអូស

**៣.១. ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តដីកាសម្រេច** .......................................៣៨
៣.១.១. ស្ថាប័នអយ្យការ.......................................................................................................៣៨
៣.១.២. ស្ថាប័នអាជ្ញាសាលា ..................................................................................................៣៩
**៣.២. ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**...............................៣៩
៣.២.១. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន...............................................៤០
៣.២.២. ការវិនិច្ឆ័យអំពីពាក្យសុំតវ៉ា ...................................................................................... ៤១
៣.២.៣. ដីកាសម្រេចអំពីពាក្យតវ៉ាចំពោះដីកាសម្រេច...............................................................៤២
៣.២.៤. ការអនុវត្តដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេច..............................................៤៤
**អនុសាសន៍**..........................................................................................................៤៦
**សេចក្ដីសន្និដ្ឋាន**.....................................................................................................៤៧
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើពិភពលោក មិនថាតែប្រទេសកម្ពុជាទេ មនុស្សតែងតែរស់នៅដោយប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកមិនថាពីសម័យកាលណាមកទេ ការរស់នៅមិនអាចរស់តែឯង គ្មានការប្រាស្រ័យទាក់ទងជាមួយមនុស្សជុំវិញខ្លួនទេ ដែលការវាជំណើរមួយដែលនាំអោយមនុស្សមានភាពស្និតស្នាល ចេះជួយគ្នាទៅវិញទៅមកក្នុងការរស់នៅប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ ដោយសារតែទំនាក់ទំនងទាំងអស់នេះហើយទើបអាចបង្កើតទៅជាចំណងគតិយុត្តិជាច្រើនដែលនាំឱ្យកើតមាននូវសិទ្ធិ និងកាតព្វកិច្ច ហើយកាតព្វកិច្ច និងសិទ្ធិនេះត្រូវបានគេធ្វើឡើងតាមរយៈកិច្ចសន្យា។ កាលណាដែលកើតមានឡើងនូវកាតព្វកិច្ចតែងតែបង្កើតឱ្យមានម្ចាស់បំណុល និងកូនបំណុលប៉ុន្តែអានុភាពនៃកិច្ចសន្យានោះមានសុពលភាព លុះត្រាតែមានការលាយល័ក្សអក្សរ និងហត្ថលេខារបស់ភាគីផងដែរ។

នៅពេលសកម្មភាពរបស់កូនបំណុលមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ដែលនាំឱ្យម្ចាស់បំណុលបានខាតបង់នូវប្រយោជន៍ ដូច្នេះហើយដើម្បីការពារនូវផលប្រយោជន៍របស់ម្ចាស់បំណុល ច្បាប់បានបញ្ញត្តិបើកសិទ្ធិឱ្យម្ចាស់បំណុលធ្វើការទាមទារទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីឱ្យតុលាការចេញសេចក្តីសម្រេចលើកូនបំណុលឱ្យអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនទៅម្ចាស់បំណុល។ វាមានលក្ខណៈពិសេសសម្រាប់ម្ចាស់បំណុលក្នុងការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល និងបង្កកសិទ្ធិចាត់ចែងរបស់កូនបំណុល អំឡុងពេលដែលម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើកូនបំណុលបាន ។

សិទ្ធិដែលម្ចាស់បំណុលទទួលបានត្រូវតែប្រើឱ្យបានត្រឹមត្រូវ នូវសិទ្ធិដែលច្បាប់បានកំណត់ឱ្យខ្លួន។ ការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្ន គឺជានីតិវិធីប្រភេទទី ១ ឬ ក៏ជំហានដំបូង នៃការចាត់ចែងរក្សាការពារសម្រាប់អោយម្ចាស់បំណុល ចាប់ផ្តើមពឹងពាក់អំណាចរដ្ឋដើម្បីទាមទារផលប្រយោជន៍របស់ខ្លួន។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ក្នុងករណីដែលភាគី ឬ បុគ្គលណាម្នាក់មិនបានអនុវត្តករណីកិច្ចរបស់ខ្លួនទេពេលនោះទៀតសោតបានកើតមានឡើងនូវវិវាទហើយវិវាទភាគច្រើនពាក់ព័ន្ធនិងការខ្ចីប្រាក់ និងការទិញលក់។ ប៉ុន្តែករណីដែលគូរភាគីណាម្នាក់មិនគោរពកាតព្វកិច្ចរបស់របស់ខ្លួន ហេតុនេះហើយទើបបានជាមានវិវាទបានកើតមានឡើង។ នាំឱ្យភាគីម្ខាងទៀតដែលជាម្ចាស់បំណុលនៃការលក់ និងការខ្ចីប្រាក់នោះមានភាពព្រួយបារម្ភពីទ្រព្យសម្បត្តិរបស់ខ្លួន ដូច្នេះហើយទើបការបង្កើតឡើងនូវស្ថាប័នតុលាការដើម្បីធ្វើការពារសិទ្ធិ និងផលប្រយោជន៍របស់គូភាគីក្នុងការដោះស្រាយវិវាទទាមទាររកយុត្តិធម៌ និងទាមទារសំណងជាដើម។

ដោយឡែកគូភាគី នៅពេលវិវាទកើតមានឡើងត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឱ្យតុលាការដែលជាស្ថានប័នដែលមានសមត្ថកិច្ចធ្វើការ ដោះស្រាយនូវបញ្ហាវិវាទ និងចាត់វិធានការក្នុងការអនុវត្តចំពោះភាគីម្ខាងទៀត ដើម្បីការពារសិទ្ធិបុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថាការមិនអនុវត្តដោយបង្ខំ នឹងមិនអាចធ្វើទៅបាន ឬ មានការលំបាកក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលនូវស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬខ្លាចមានការខូចខាតយ៉ាងធ្ងន់ធ្ងរណាមួយនាពេលអនាគត ម្ចាស់បំណុលអាចដាក់ពាក្យសុំចាត់ចែងរក្សាការពារបាននៅក្នុងអំឡុងពេលបណ្តឹងអង្គសេចក្តី ឬ មុនបណ្តឹងអង្គសេចក្តី។

ប្រសិនបើកូនបំណុលមានទ្រព្យសម្បត្តិជាចលនវត្ថុ ឬ អចលនវត្ថុ ម្ចាស់បំណុលអាចដាក់ពាក្យសុំចាត់ចែងរក្សាការពារ គឺកុំឱ្យមានការផ្លាស់ប្តូរស្ថានភាពនៃទ្រព្យសម្បត្តិ ឬ អនុប្បទានសិទ្ធិ ឬ គេចវេស ឬលក់ជាដើម ក្នុងករណីដែលកូនបំណុលមិនមានលទ្ធភាពក្នុងការសង និងអនុវត្តកាតព្វកិច្ចបាន។ ពេលដែលតុលាការសម្រេចចេញដីកាសម្រេចការពារ គឺមាននីតិវិធិបន្តបន្ទាប់ដែលត្រូវអនុវត្ត។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលបានចេញប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ មានគន្ថីចំនួន ៩ (ប្រាំបួន) ដោយនៅក្នុងគន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារដែលក្នុងនោះមានចែងអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមានចាប់ពីមាត្រា ៥៣០ ដល់ មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តើនីតិវិធីរឹបអូសជាបណ្តោះចំពោះអចលនវត្ថុ ដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះប្រព្រឹត្រទៅយ៉ាងដូចម្តេចខ្លះ? តើស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការអនុវត្ត?

## ៣. គោលបំណងនៃការស្រាវជ្រាវ

យើងដឹងច្បាស់ហើយថា ការធ្វើការស្រាវជ្រាវប្រធានបទណនេះឡើង គឺដើម្បីធ្វើជារបាយការណ៍ ឬ សាណារបញ្ចប់ការសិក្សា បន្ថែមពីលើនេះទៀតឯកសារដែលស្រាវជ្រាវមកនេះមានគោលបំណងដូចជា៖

ទី១. ចែករំលែកជាចំណេះដឹង

ទី២. ដំណោះស្រាយនៅពេលកើតវិវាទកើតមានឡើង

ទី៣. ជាឯកសារជំនួយដល់និស្សិតជំនាន់ក្រោយបានសិក្សាស្វែងពីនីតិវិធី

ទី៤. បង្ហាញពីលំហូរនីតិវិធីនីមួយៗក្នុងការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្ន

ទី៥. ដើម្បីចូលរួមចែករំលែកក្នុងការផ្សព្វផ្សាយច្បាប់

ទី៦. ការចែករំលែកចំណេះដឹងទៅប្រជាជនដែលមិនមែនជាអ្នកច្បាប់បានយល់ដឹង។

ទី៧. ចែកចាយសៀវភៅនេះទៅបងប្អូនមួយចំនួនអោយបានយល់ដឹង

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទសាណារយើងខ្ញុំបានកំណត់ជាក់លាក់ហើយថា « នីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ » មានន័យថាយើងខ្ញុំធ្វើការបកស្រាយប្រធានបទកម្រិតត្រឹមពីវិសាលភាពនៃ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ រហូតដល់ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តែយើងខ្ញុំមិនភ្លេចបញ្ចូលនូវខ្លឹមសារមួយចំនួនដែលទាក់ទងការអនុវត្តទូទៅដែរ បើទោះបីជាប្រភេទណាក៏ដោយនោះ។ ចំពោះឯកសារដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវមកតាមរយៈតែប្រព័ន្ធអ៊ីនធើណេតតែប៉ុណ្ណោះ ដោយហេតុតែកត្តាការកើតមានឡើងនូវ កូវីត១៩ ដូច្នេះសាកលវិទ្យាល័យមិនអនុញ្ញាតអោយនិស្សិតចុះទៅស្រាវជ្រាវទៅតាមស្ថាប័នឡើយ និងតាមស្ថាប័នមួយចំនួនមានការរឹតត្បិបនៅការចេញចូលផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការធ្វើការស្រាវជ្រាវរាល់ឯកសាររបាយការណ៍ និងសារណាបញ្ចប់ការសិក្សទាំងអស់សុទ្ធសឹងតែមានគោលបំណង និងសារៈសំខាន់ផ្សេងៗគ្នាទាំងអស់ ដោយឡែកការសិក្សាស្រាវជ្រាវនៅលើប្រធានបទនីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មួយនេះជាការបង្ហាញអំពីការចាប់បាននូវចំណេះដឹងផ្នែកនីតិវិធីរដ្ឋប្បវេណីដែលយើងខ្ញុំបានធ្វើការសិក្សាអស់រយៈពេល បួន ឆ្នាំ កន្លងមកនេះ មួយវិញទៀតកាសិក្សាទៅលើប្រធានបទមួយនេះក៏បានធ្វើឱ្យយើងខ្ញុំយល់ដឹងបន្ថែម អំពីនីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុបញ្ញាត្តិផ្សេងៗដែលមានទំនាក់ទំនងនឹងនីតិវិធីរដ្ឋប្បវេណី និងឆ្លុះបង្ហាញអំពីការដោះស្រាយបញ្ហានាពេលបច្ចុប្បន្ន។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការចងក្រងសៀវភៅនេះឡើងបានលទ្ធផលមួយ ដែលសមប្រកបទៅតាមទម្រង់ដែលបានកំណត់ យើងខ្ញុំទាំងពីរអ្នកបានសិក្សាស្រាវជ្រាវរកឯកសារដែលពាក់ព័ន្ធជាច្រើនទាក់ទង និងប្រធានបទនីតិវិធីរឹបអូសជាបណ្តោះអាសន្ន ដែលមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសអន្តរក្រសួង ឯកសារវគ្គបណ្តុះបណ្តាលសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ឯកសារអាជ្ញាសាលា ឯកសារក្រសួងយុត្តិធម៌ ព្រមទាំងបានសាកសួរពីសិស្សច្បងដែលជាអ្នកសិក្សា មេធាវី អាជ្ញាសាលា មួយចំនួនផងដែល។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទដែលយើងខ្ញុំធ្វើការស្រាវជ្រាវបានបែងចែកជា ៣ ជំពូកសំខាន់ៗរួមមាន៖

**ជំពូកទី ១៖ សញ្ញាណនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ជំពូកទី ២៖ នីតិវិធីតុលាការពាក់ព័ន្ធនឹងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ជំពូកទី ៣៖ ស្ថាប័នអនុវត្ត និងការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

## ជំពូកទី១ :

# សញ្ញាណនៃការរឹបអូស
# ជាបណ្ដោះអាសន្នចំពោះ
# អចលនវត្ថុ

# ជំពូកទី១

## សញ្ញាណនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះដីការក្សាការពារមានបីប្រភេទ ប៉ុន្តែក្នុងវិសាលភាពដែលយើងបង្ហាញនៅពេលនេះ គឺពាក់ព័ន្ធនឹងដីកាមួយដែលពាក់ព័ន្ធដីកាចាត់ចែងជាបណ្តោះអាសន្ន។ គោលបំណងនៃការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលមានបំណងការពារ និង ថែរក្សាការពារស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរដ្ឋ ដើម្បីការពារសិទ្ធិបុគ្គលណាម្នាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំ និងអនុវត្តលើសិទ្ធិលើបំណុលមានការពិបាកខ្លាំង ដោយសារអាចមានការប្រែប្រួលនូវស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬនៅពេលដែលមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។[1] ដោយនៅក្នុងការចាត់ចែងរក្សាការពារមាន ៣ ប្រភេទរួមមានដូចជា៖

- ការរឹបអូសជាបណ្តោះអាសន្ន
- ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ
- ការចាត់ចែងជាបណ្តោះអាសន្នដោយកំណត់ឋានៈបុគ្គល។

ការរឹបអូសជាបណ្តោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារមានគោលបំណងឱ្យសងជាប្រាក់ ( ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ប្រសិនបើចង់សម្រេចដោយឱ្យសងជាប្រាក់ ក៏អាចសុំឱ្យចាត់ចែងរក្សាការពារ តាមរយៈការសុំរឹបអូសជាបណ្តោះអាសន្ន ) ។[2]

ការចាត់ចែងជាបណ្តោះអាសន្នដចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទារឱ្យសងជាប្រាក់។[3]

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតមានឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។[4]

[1] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣០

[2] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣១ កថាខណ្ឌទី ១

[3] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣១ កថាខណ្ឌទី ២

[4] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣១ កថាខណ្ឌទី ៣

## ១.១. អត្ថន័យ និងគោលបំណងនៃការរឹបអូសជាបណ្ដោះអាសន្ន

### ១.១.១. អត្ថន័យនៃការរឹបអូសជាបណ្ដោះអាសន្ន

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាវិធានការមួយដើម្បីការពារជាបណ្ដោះអាសន្ននូវសិទ្ធិរបស់ម្ចាស់បំណុល នៅពេលដែលការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ ការរឹបអូសជាបណ្ដោះអាសន្នអាចអនុវត្តទៅបានចំពោះវត្ថុផ្សេងៗ ដែលជាកម្មវត្ថុជាទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីជៀសវៀងនូវការប្រែប្រួលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ឬ ការអនុប្បទានសិទ្ធិ ឬ លក់ទៅឱ្យតតិយជនជាដើមដែលនាំឱ្យទ្រព្យសម្បត្តិបាត់បង់។ល។ ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើបានចំពោះកម្មវត្ថុដែលមានដូចជា៖ អចលនវត្ថុ ចលនវត្ថុ និងសិទ្ធិលើបំណុល។

ឧទាហរណ៍ ៖ លោក ក បានខ្ចីប្រាក់លោក ខ ចំនួន២០លានរៀល។ លោក ក ជាកូនបំណុលមានដីស្រែនៅភូមិចំនួន ២ ហិចតា ដែលមានតម្លៃប្រហែល១៥លានរៀល។ នៅក្នុងនីតិវិធីបណ្ដឹងអាចនឹងទាមទារឱ្យសងប្រាក់ មានការប្រើពេលវេលាយូរដែលនាំឱ្យលោក ខ អាចនឹងបាត់បង់ផលប្រយោជន៍នូវស្ថានភាពណាមួយដោយការ ផ្ទេរ ឬ លក់ជាដើម។ ហេតុនេះ លោក ក ត្រូវតែដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលជាដីស្រែរបស់លោក ខ ដើម្បីធានានូវសិទ្ធិរបស់ម្ចាស់បំណុល ក នៅពេលឈ្នះក្ដី។

### ១.១.២. គោលបំណងនៃការរឹបអូសជាបណ្ដោះអាសន្ន

ការរឹបអូសជាបណ្ដោះអាសន្ន គឺមានគោលបំណងអោយកូនបំណុលសងជាប្រាក់ នឹងជាធ្នាក់មួយក្នុងការចងកាតព្វកិច្ចរបស់កូនបំណុលឱ្យសងបំណុលផងដែរ។ នៅក្នុងបណ្ដឹងអង្គសេចក្ដី ចាប់ពីពេលដាក់ពាក្យបណ្ដឹងរហូតដល់ពេលចេញសាលក្រមស្ថាពរត្រូវចំណាយពេលវេលាច្រើន ហេតុនេះអាចមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ទោះបីជាម្ចាស់បំណុលឈ្នះក្ដីក៏ដោយ អាចមានករណីដែលមិនអាចធ្វើការអនុវត្តដោយបង្ខំបាន។[5] ឧទាហរណ៍ ៖ ប្រសិនបើ លោក ក បានលក់ដី B1/B2 ឱ្យតតិយជន ទោះបីជា លោក ខ ឈ្នះក្ដីក៏ដោយ ក៏មិនអាចធ្វើការអនុវត្តដោយបង្ខំចំពោះ ដីB1/B2 នោះដែរ ពីព្រោះដីនោះមិនមែនជាទ្រព្យសម្បត្តិម្ចាស់កម្មសិទ្ធិទទួលខុសត្រូវរបស់លោក ក ទៀតទេ។

ហេតុនេះហើយ ដើម្បីបង្កាកុំឱ្យមានបញ្ហានេះកើតមានឡើង ឬជួយការពារនូវផលប្រយោជន៍របស់ម្ចាស់បំណុលដែលជាដើមបណ្ដឹងត្រូវដាក់ «ពាក្យសុំចាត់ចែងរក្សាការពារ» ទៅលើទ្រព្យសម្បត្តិរបស់កូនបំណុល

[5] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣០

ដែលជាកម្មវត្ថុរក្សាការពារ នឹងជាមធ្យោបាយសង្គ្រោះជាបណ្ដោះអាសន្នរហូតដល់ពេលម្ចាស់បំណុលចេញសាលក្រមជាស្ថាពរក្នុងរឿងបណ្ដឹងអង្គសេចក្ដី ហើយអាចអនុវត្តបានប្រកបដោយសុវត្ថិភាព។

ប្រសិនបើមានបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល នៃការអនុវត្តដោយបង្ខំ បុគ្គលដែលមានបំណងចងការពារសិទ្ធិរបស់ខ្លួន អាចធ្វើការទាមទាឱ្យចាត់ចែងរក្សាការពារបាន។

ឧទាហរណ៍ ៖ សិទ្ធិមួយដែលត្រូវដាក់រក្សាការពារ ជាសិទ្ធិលើបំណុល ឬ សិទ្ធិរក្សាការពារលើកម្មវត្ថុនៃវិវាទជាដើម។

បើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិបុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទាឱ្យរក្សាការពារបាន។

បន្ទាប់ពីធ្វើការសុំចាត់ចែងរក្សាការពាររួចរាល់ហើយ គឺឈានចូលទៅដល់ដំណាកាល «**នីតិវិធីរឹបអូសជាបណ្ដោះអាសន្ន**» ដែលនីតិវិធីរឹបអូសជាបណ្ដោះអាសន្ននេះ ជាវិធានការមួយដើម្បីការពារជាបណ្ដោះអាសន្ននូវសិទ្ធិរបស់ម្ចាស់បំណុល។ ការរឹបអូសជាបណ្ដោះអាសន្នអាចអនុវត្តបានចំពោះវត្ថុផ្សេងទៀតដែលជាទ្រព្យរបស់កូនបំណុល ដើម្បីជៀសវាងចេតនាទុច្ចរិតរបស់កូនបំណុលដែលអាចធ្វើឱ្យទ្រព្យសម្បត្តិផ្សេងទៀតនោះបាត់បង់ដោយការផ្ទេរ ឬ ធ្វើអនុប្បទាន ឬ លក់ទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅតតិយជនជាដើម។ល។ ហើយការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើទៅបានចំពោះ ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល។

## ១.២. ពាក្យសុំរឹបអូសជាបណ្ដោះអាសន្ន

ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ[6] ហើយពាក្យសុំត្រូវតែសរសេរជាលាយល័ក្ខអក្សរដាក់ទៅកាន់តុលាការដែលមានសមត្ថកិច្ច ហើយពាក្យសុំត្រូវសរសេរចំណុចដែលច្បាប់បានកំណត់ និងត្រូវបញ្ជាក់ចំណុចចាំបាច់ដែលច្បាប់បានកំណត់ ដោយសេចក្ដីបញ្ជាក់ដំបូង។ ម៉្យាងវិញទៀតតុលាការអាចចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្នបាន លុះត្រាតែមានពាក្យសុំរបស់ភាគីម្ខាងណាទើប នីតិវិធីដំណើរការទៅមុខបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវសរសេរឱ្យបានច្បាស់លាស់ទៅលើចំណុចសំខាន់ៗដែលរួមមានដូចជា:

1. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះអ្នកតំណាងដោយច្បាប់បានកំណត់។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣២ ចំណុចទី ១

2. ខ្លឹមសារនៃដីការក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ។

3. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។

4. ភាពចាំបាច់នៃរក្សាការពារ។[7]

ចំណុចខាងលើនេះ ជាមូលដ្ឋានគ្រឹះដ៏សំខាន់ដែលត្រូវសរសេរបញ្ជាក់នៅក្នុងពាក្យសុំ ហើយចំពោះអត្ថន័យនូវចំណុចនីមួយៗដែលត្រូវសរសេរបែបណានោះ នឹងបង្ហាញនៅខាងក្រោមនេះ ។

### ១.២.១. អត្តសញ្ញាណរបស់ភាគី

អ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវហៅកាត់ថា ម្ចាស់បំណុល ចំណែកឯភាគីម្ខាងទៀតនៃពាក្យសុំ ត្រូវហៅកាត់ថា កូនបំណុល។

ម្ចាស់បំណុល៖ **ក** មានអាសយដ្ឋាន ផ្ទះលេខ....... ផ្លូវលេខ..... ភូមិ......... ឃុំ/សង្កាត់...... ស្រុក/ខណ្ឌ....... រាជធានី/ខេត្ត

កូនបំណុល៖ **ខ** មានអាសយដ្ឋាន ផ្ទះលេខ....... ផ្លូវលេខ..... ភូមិ......... ឃុំ/សង្កាត់...... ស្រុក/ខណ្ឌ....... រាជធានី/ខេត្ត

អ្នកមានអំណាចមេបា៖ **គ** មានអាសយដ្ឋាន ផ្ទះលេខ....... ផ្លូវលេខ..... ភូមិ......... ឃុំ/សង្កាត់...... ស្រុក/ខណ្ឌ....... រាជធានី/ខេត្ត (ប្រសិនបើមានអ្នកតំណាងដោយដែលច្បាប់កំណត់)

មិនតែប៉ុណ្ណោះការពាក់ព័ន្ធគ្នាក្នុងប្រសិទ្ធភាពទំនាក់ទំនង ដែលសមស្របទៅនឹងការជឿនលឿនរបស់សង្គមបច្ចុប្បន្ននេះ គឺលេខទូរស័ព្ទដែលគួរតែសរសេរភ្ជាប់មកជាមួយ ដែលវាជាមធ្យោបាយជឿនលឿនក្នុងការជូនដំណឹងទៅភាគីម្ខាងៗ ។[8]

### ១.២.២. ខ្លឹមសារនៃដីការក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ការចាត់ចែងរក្សាការពារមាន ៣ ប្រភេទ ហើយដំណើរការនីតិវិធីនៃប្រភេទនីមួយៗមានលក្ខណៈខុសៗគ្នា។[9] ដូច្នេះខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញនោះជាចំណុចដែលមិនអាចខ្វះបាន ពីព្រោះដើម្បីឱ្យតុលាការដឹងថា ម្ចាស់បំណុលចង់ឱ្យតុលាការចេញដីកាសម្រេចប្រភេទមួយណា ចំពោះកម្មវត្ថុជាក់លាក់ដូចមាន ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល នាវាជាដើម ផ្សេងៗ។ រក្សាការពារទាំង ៣ប្រភេទនោះមានដូចខាងក្រោម ៖

- ដីការក្សាការពារ ដើម្បីធ្វើការរឹបអូសជាបណ្តោះអាសន្ន

[7] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤១

[8] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ក

[9] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ខ

– ដីការក្សាការពារការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

– ដីការក្សាការពារការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។

នៅក្នុងរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ការកំណត់ជាក់លាក់នូវអចលនវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន និងការកំណត់ជាក់លាក់ចំពោះសិទ្ធិលើបំណុលដែលត្រូវរក្សាការពារ គឺត្រូវសរសេរបញ្ចូល នៅក្នុងពាក្យដើម្បីកំណត់ជាក់លាក់ នូវកម្មវត្ថុនៃដីកាសម្រេច។[10]

ឧទាហរណ៍ ៖ ខ្លឹមសារនៃដីកាម្រេចរបស់អ្នកដាក់ពាក្យសុំទាមទារ « រឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់បញ្ជីសារពើភណ្ឌនៃវត្ថុ ( សរសេរពីអត្តសញ្ញាណនៃអចលនវត្ថុ ) » ។

នៅក្នុងរឿងក្ដីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដើម្បីរក្សាកាពារសិទ្ធិទាមទាដែលពាក់ព័ន្ធនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទក្រៅពីសិទ្ធិទាមទារឱ្យសងជាប្រាក់ ហើយវាអាចអនុវត្តបានតែចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទតែប៉ុណ្ណោះ។

នៅក្នុងការទាមទារឱ្យចុះបញ្ជី ម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ឱ្យច្បាស់អំពីខ្លឹមសារចាត់ចែងជាបណ្ដោះអាសន្ន។[11]

ឧទាហរណ៍ ៖ ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ « កូនបំណុលមិនអាចធ្វើអនុប្បទានដាក់ប្រាតិភោគ និងចាត់ចែងផ្សេងៗ ចំពោះអចលនវត្ថុដូចមានកំណត់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុ ( សរសេរអត្តសញ្ញាណនៃអចលនវត្ថុ ) » ។

នៅក្នុងរឿងក្ដីនៃការចាត់ចែងជាបណ្ដោះអាសន្នកំណត់ឋានៈជាបណ្ដោះអាសន្ន ជាការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្ន រហូតដល់សេចក្ដីសម្រេចចូលជាស្ថាពរនៅក្នុងករណីចាំបាច់ ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតមានដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។[12]

ឧទាហរណ៍ ៖ មុននឹងចេញសាលក្រមលែងលះចូលជាស្ថាពរ ក (ម្ដាយ) បានដាក់ពាក្យសុំចាត់ចែងរក្សាការពារ ដែលកំណត់អំណាចមេបាជាបណ្ដោះអាសន្នទៅម្ដាយ និងកំណត់ឱ្យ ខ (ឪពុក) បង់សោហ៊ុយបីបាច់ចិញ្ចឹមកូនចំនួន $ ៥០០/ខែ។

---

[10] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣១ កថាខណ្ឌទី១ ចំណុច ក

[11] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣១ កថាខណ្ឌទី២ ចំណុច ខ

[12] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣១ កថាខណ្ឌទី៣ ចំណុច គ

ឧទាហរណ៍ ៖ លោក ក (ម្ចាស់ដីL ដែមានអាគារ) លោក ខ (ម្ចាស់ដី F)។ ដី L និងដី F ជាដីដែលជាប់គ្នា លោក ក បានសាងសង់អាគារនៅលើដីរបស់គាត់ L ប៉ុន្តែនៅពេលសាងសង់បណ្តាលឱ្យមានស្នាមប្រេះផ្ទះដី F របស់លោក ខ ។ ដូច្នេះលោក ខ បានស្នើសុំឱ្យ លោក ក ផ្អាកការសាងសង់ជាបណ្តោះអាសន្ន និងពិនិត្យអំពីលក្ខណៈបច្ចេកទេស ប៉ុន្តែលោក ក នៅតែបន្តសាងសង់ ហេតុនេះលោក ខ បានដាក់ពាក្យសុំចាត់ចែងរក្សាការពារ បង្គាប់ឱ្យ លោក ក ផ្អាកការសាងសង់សំណង់នៅលើដី F ដែលមានកំណត់ក្នុងបញ្ជីសារពើភ័ណ្ឌនៃវត្ថុ។

**១.២.២.១. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលត្រូវនឹងបានរក្សាការពារ**

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវសរសេរអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារ ក្នុងគោលបំណងឱ្យតុលាការពិចារណាអំពីសិទ្ធិ និងភាពចាំបាច់របស់ម្ចាស់បំណុល ក្នុងការទាមទាឱ្យតុលាការចេញដីកាសម្រេចរក្សាការពារ។ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ គឺជាការអះអាងអំពីអង្គហេតុចម្បង ឬអង្គហេតុដែលជាមូលហេតុនៃការទាមទារអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុ ដែលជាមូលហេតុនៃការទាមទារដើម្បីតុលាការយល់ឃើញថា ម្ចាស់បំណុលមានសិទ្ធិទាមទារ ( មានអង្គហេតុកកើតសិទ្ធិ ) ។

**១.២.២.២. ភាពចាំបាច់នៃរក្សាការពារ**

នៅក្នុងពាក្យសុំដីការក្សាការពារ ភាគីអ្នកសុំត្រូវសរសេរយ៉ាងណាបញ្ជាក់ឱ្យច្បាស់លាស់អំពីតម្រូវ

ការចាំបាច់ ដើម្បីឱ្យចៅក្រមចេញដីការក្សាការពារ។ ភាពចាំបាច់នៃរក្សាការពារដែលត្រូវសរសេរនៅក្នុងពាក្យសុំគឺជាការពន្យល់អំពីស្ថានភាពទ្រព្យសម្បត្តិ ឬ ទំនាក់ទំនងនៃសិទ្ធិដែលមានវិវាទ ឬ ឋានៈរបស់កូនបំណុល ដែលអាចប្រែប្រួល ឬមានហានិភ័យដល់ការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុល ក្នុងគោលបំណងបង្ហាញតុលាការបានឃើញថា ប្រសិនបើមិនចាត់វិធានការជាបន្ទាន់ទេនោះ ផលប្រយោជន៍ម្ចាស់បំណុលនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ [13] ចំណែកឯការសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ អាចធ្វើទៅបានចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឱ្យសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនាអនាគតនឹងមិនអាចធ្វើទៅបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ប្រសិនស្ថានភាពបច្ចុប្បន្ននៅ

[13] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤១ កថាខណ្ឌទី៤ ចំណុច ឃ

ដដែល។ ភាពចាំបាច់រក្សាការពារមានដូចជា ៖ ស្ថានភាពទ្រព្យសម្បត្តិកូនបំណុល ទំនងជាធ្លាក់តម្លៃ ( បរិមាណ ឬ គុណភាព ) ឬ ការលក់ក្នុងតម្លៃថោកជាអាទិ៍។[14]

ឧទាហរណ៍: លោក ក មានសិទ្ធិលើបំណុលចំពោះ លោក ខ ចំនួន USD 500,000 ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ សន្យាថាសងឱ្យគ្រប់រយៈពេល ១ ឆ្នាំ រហូតដល់ថ្ងៃកំណត់សងបានផុតទៅដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ដោយលោក ខ មិនបានបង់ការប្រាក់ឱ្យទៀងទាត់ ហើយពុំមានដំណឹងអ្វីពីលោក ខ ទៀតនោះ លោក ក បានធ្វើការដាក់ពាក្យប្តឹងទាមទារឱ្យលោក ខ សងនៅប្រាក់កម្ចីចំនួន USD ៥០០,០០០ ដែលបានខ្ចី ទន្ទឹមនឹងពេលនោះ លោក ក ប្រទះឃើញការផ្សាយព័ត៌មានអំពីការលក់ផ្ទះតាមប្រព័ន្ធអនឡាញថា លោក ខ បានប្រកាសលក់ផ្ទះ ឃ ដែលមានទីតាំងនៅភ្នំពេញ ដែលមានតម្លៃទាបក្រោមទីផ្សារ។

ក្នុងករណីនេះ ប្រសិនបើបណ្តោយឱ្យស្ថានភាពបច្ចុប្បន្ននៅដដែល ( គ្មានការចាត់ចែងណាមួយដើម្បីការពារសិទ្ធិម្ចាស់បំណុលទេនោះ ) ការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើបាន ពីព្រោះកូនបំណុលអាចអនុប្បទាន ឬ លក់នូវអចលនវត្ថុនោះតាមអំពើចិត្តបាន ហេតុនេះអចលវត្ថុជាកម្មវត្ថុដែលត្រូវរឹបអូសនេះម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ដោយបញ្ជាក់អំពីស្ថានភាពនៃទ្រព្យសម្បត្តិរបស់កូនបំណុល ដែលជាភាពចាំបាច់ដែលត្រូវរក្សាការពារ។

**១.២.២.៣. សេចក្តីបញ្ជាក់ដំបូង**

នៅក្នុងពាក្យសុំដីការក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ននេះ ចំណុចដែលត្រូវសរសេរដូចជាបានរៀបរាប់ដូចខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងនូវចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ និងភាពចាំបាច់រក្សាការពារនេះ។[15] សេចក្តីបញ្ជាក់ដំបូងនេះ ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗ បន្ទាប់ពីម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរួចហើយ ម្ចាស់បំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងចំពោះចំណុចមួយចំនួន ដើម្បីឱ្យតុលាការយកធ្វើជាមូលដ្ឋានមួយក្នុងការចេញ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយម្ចាស់បំណុលដាក់ឯកសារណាមួយឱ្យតុលាការពិនិត្យមើលភ្លាមៗ ដែលជាឯកសារដែលងាយស្រួលក្នុងការពិនិត្យដោយពុំប្រើរយៈពេលយូរក្នុងការពិនិត្យភស្តុតាងនេះ។

---

[14] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៥ កថាខណ្ឌទី១

[15] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤១

### ១.២.២.៤. ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង

យោងតាមមាត្រា ១៣១ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ ដូច្នេះឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង គឺជាឯកសារធ្វើភស្តុតាង ត្រូវជាឯកសារមួយដែលអាចពិនិត្យបានភ្លាមៗដោយមិនប្រើរយៈពេលយូរងាយស្រួល នៅពេលធ្វើសេចក្តីបញ្ជាក់ដំបូង។[16] នៅក្នុងច្បាប់មិនបានកំណត់អំពីការធ្វើសេចក្តីបញ្ជាក់ដំបូងទេ ប៉ុន្តែច្បាប់បានកំណត់ចំណុចមួយចំនុចដែលត្រូវយកមកធ្វើសេចក្តីបញ្ជាក់ដំបូងដែលមានចែងនៅក្នុងមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និងសេចក្តីបញ្ជាក់ដំបូង( សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ ) ។

### ១.២.២.៥. ឯកសារដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ

ការបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ក្រមនីតិវិធីរដ្ឋប្បវេណី បានអនុញ្ញាតឱ្យមានអ្នកតំណាងដោយអាណត្តិនៅក្នុងនីតិវិធីរក្សាការពារដែរហើយអ្នកតំណាងដោយអាណត្តិនៅក្នុងនេះ គឺមានសិទ្ធិអំណាចក្នុងការធ្វើរាល់សកម្មភាពបណ្តឹង ព្រមទាំងការពាក្យបណ្តឹង ការឆ្លើយតបដោះសារចំពោះបណ្តឹង ការប្តឹងតបការចូលរួមអន្តរាគមន៍បណ្តឹង ការប្តឹងទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់នូវការទាមទារ ចំពោះរឿងក្តីដែលខ្លួនទទួលអាណត្តិ។[17] នីតិវិធីរក្សាការពារ មានលក្ខណៈដូចនិងនីតិវិធីសម្រាប់ការជំនុំជម្រះដែរ គឺអ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារមានសិទ្ធិជ្រើសរើសអ្នកតំណាងដោយអាណត្តិ ដើម្បីការពារសិទ្ធិឱ្យខ្លួន និងការពារផលប្រយោជន៍របស់ខ្លួនបានដោយធ្វើសកម្មភាពបណ្តឹងជំនួសខ្លួន។[18]

### ១.២.២.៦.ឯកសារដើម្បីបញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

នៅក្នុងបញ្ញត្តិនៃមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌទី១ ចំណុចទី១ ពាក្យសុំត្រូវសរសេរទៅតាមចំណុចខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ដែលអ្នកដាក់ពាក្យសុំទាមទារដែលចូលរួមមានប្រភេទដីកាសម្រេចកម្មវត្ថុនៃការរឹបអូស និងគោលបំណងនៃការរក្សាការពារ។ កម្មវត្ថុនៃការរឹបអូសក៏ត្រូវមានឯកសារបញ្ជាក់ដើម្បីភ្ជាប់ជាមួយពាក្យសុំ ពីព្រោះថាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបញ្ជាក់ពីកម្មវត្ថុ លើកលែងករណីចលនវត្ថុ។ ក្នុងករណីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ឬសិទ្ធិលើបំណុល តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុនេះ។ ប៉ុន្តែចំពោះចលនវត្ថុវិញ

---

[16] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ១៣១

[17] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤ កថាខណ្ឌទី១

[18] សៀវភៅស្តីពី នីតិវិធីរឹបអូសជាបណ្តោះអាសន្ន បោះពុម្ព នៅខែមិនា ឆ្នាំ២០០៩

តុលាការអាចចេញដីកាសម្រេចបានដោយមិនចាំបាច់កំណត់កម្មវត្ថុទេ។[19] មូលហេតុ គឺថាមានការលំបាកសម្រាប់ម្ចាស់បំណុល ឬតុលាការក្នុងការស្វែងរកថា តើប្រភេទទ្រព្យអ្វីខ្លះដែលកូនបំណុលមាន? ហើយពេលមានការអនុវត្ត ដោយការបង្ខំចំពោះចលនវត្ថុអ្នកអនុវត្តគេនឹងដឹងនីតិវិធីនៃការអនុវត្តហើយដូចជា ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ[20] ( ការរឹបអូសចលនវត្ថុ មិនត្រូវឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលក្នុងការអនុវត្ត និងសោហ៊ុយក្នុងការអនុវត្តទេ ប្រសិនបើករណីការរឹបអូសហួសកម្រិតដែលបានកំណត់ក្រោយ ពីការរឹបអូសរួចអាជ្ញាសាលាត្រូវធ្វើការលុបចោលការរឹបអូសដែលហួសកម្រិតនោះ ) និងចលនវត្ថុណាដែលហាមឃាត់មិនឱ្យរឹបអូស[21] ។ ឯកសារបញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺអ្នកដាក់ពាក្យសុំត្រូវធ្វើបញ្ជាក់យ៉ាងណា ដើម្បីឱ្យតុលាការជឿជាក់លើកម្មវត្ថុនៅក្នុងពាក្យសុំនៃការរឹបអូសជាបណ្តោះអាសន្ន ថាពិតជាទ្រព្យសម្បត្តិរបស់កូនបំណុលពិតប្រាកដមែន ដូចជាលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់កូនបំណុលចំពោះទ្រព្យសម្បត្តិមានដូចជា ទីតាំងដី ទំហំដីប្រហែលប៉ុន្មាន ឬ ទីតាំងផ្ទះ ទំហំផ្ទះប្រហែលប៉ុន្មាន ជាកម្មសិទ្ធិរបស់កូនបំណុលជាដើម ហើយការបញ្ជាក់ពីកម្មសិទ្ធិនៃអចលវត្ថុនោះ ជាភារកិច្ចរបស់សុរិយោដី។

### ១.២.៣.សោហ៊ុយ

អ្នកដាក់ពាក្យសុំ ឬម្ចាស់បំណុលនៃការអនុវត្តរក្សាការពារ ត្រូវបង់សោហ៊ុយចាំបាច់ផ្សេងៗ ទៅតុលាការដែលមានសមត្ថកិច្ចអនុវត្តរក្សាការពារ ដើម្បីបន្តនីតិវិធីអនុវត្តរក្សាការពារ។

#### ១.២.៣.១. ពន្ធដាក់ពាក្យសុំ

ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ឬពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬបណ្តឹងជំទាស់ ឬសុំលុបចោលដីកាសម្រេចរក្សាការពារ ឬសុំឱ្យអនុវត្តរក្សាការពារ ពាក្យសុំដាក់ទៅរដ្ឋបាលតុលាការត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល។[22] អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធជាមុនសិននូវចំនួនទឹកប្រាក់ដែលបានកំណត់ដោយតុលការអនុវត្តរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តរក្សាការពារ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធទេ តុលាការអាចលើកចោលពាក្យសុំឱ្យធ្វើអនុវត្តរក្សាការពារ ឬអាចលុបចោលនូវនីតិវិធីអនុវត្តរក្សាការពារ។ សោហ៊ុយនៃនីតិវិធីចេញដីកាសម្រេចរក្សាការពារ ជាគោលការណ៍នៅបញ្ញាស្តីពីប្រាក់ប្រដាប់ក្តី ក្នុងជំពូកទី៤ នៃគន្ថីទី១ ត្រូវយកមកអនុវត្ត ប៉ុន្តែលកលែងតែបញ្ញត្តិនៃមាត្រា ៦១ ( ពន្ធដាក់ពាក្យសុំ ) និងកថាខណ្ឌទី៣ ទី៤ នៃមាត្រា៦២។ បើទោះបីជា ចំណុចស្តីអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត

[19] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៦

[20] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៣៩១

[21] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៣៨០

[22] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣៧

ដែលត្រូវរក្សាការពារ ឬភាពចាំបាច់នៃរក្សាការពារ មិនអាចបញ្ជាក់ដោយភស្តុតាងដែលជាសេចក្តីបញ្ជាក់ដំបូងក៏ដោយ ក៏តុលាការអាចចេញដីកាសម្រេចរក្សាការពារបានដែល។

ឧទាហរណ៍ ៖ អ្នកលក់បានប្តឹងទាមទារឱ្យអ្នកទិញ បង់ប្រាក់ថ្លៃទិញគោយន្ត ខណៈដែលអ្នកលក់បានប្រគល់គោយន្តនោះទៅឱ្យអ្នកទិញ (ហេតុនាំឱ្យមានការប្រគល់គោយន្តមុនការបង់ប្រាក់នេះ ដោយសារអ្នកលក់យល់នូវមនោសញ្ចេតនា អ្នកស្គាល់គ្នាឱ្យសាកល្បងនូវម៉ាក់ចេញថ្មី) ដែលជាកម្មវត្ថុនៃការលក់ទិញឱ្យអ្នកទិញរួចរាល់ ហើយបច្ចុប្បន្ននេះ អ្នកទិញកំពុងកាន់កាប់គោយន្តនេះ។ ដោយអ្នកលក់បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ប៉ុន្តែអ្នកលក់គ្មានភស្តុតាងដែលអាចបញ្ជាក់ថា រថយន្តអាចនឹងត្រូវបានធ្វើអនុប្បទាន ឬធ្វើការចាត់ចែងនោះទេ ប៉ុន្តែតុលាការអាចទទួលស្គាល់ថា មានភាពចាំបាច់នៃការរក្សាការពារ ដោយផ្អែកលើស្ថានភាពនៃការមិនបង់ថ្លៃប្រាក់ទិញរបស់អ្នកទិញ ដែលនាំឱ្យអ្នកទិញទំនងអាចធ្វើការលក់គោយន្តបន្តទៀតបាន។

ក្នុងករណីនេះ អ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥,០០០ (ប្រាំពាន់) រៀល ទៅរដ្ឋបាលតុលាការ។ ពន្ធដាក់ពាក្យសុំខាងលើនេះ តម្រូវឱ្យត្រូវបង់ជាដាច់ខាត ក្នុងករណីដែលមិនបានបង់ តុលាការនឹងបង្គាប់ម្ចាស់បំណុលបង់ប្រាក់ទៅតាមកាលបរិច្ឆេទកំណត់ណាមួយសមរម្យ ទៅតាមបញ្ញត្តិនៃមាត្រា ៧៨ កថាខណ្ឌទី១ ហើយប្រសិនបើអ្នកដាក់ពាក្យសុំមិនបង់តាមការកំណត់ខាងលើទេ តុលាការនឹងលើកចោលពាក្យសុំដោយដីកាសម្រេចតាមបញ្ញត្តិនៃមាត្រា ៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ១.២.៣.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធនេះ គឺភាគី ឬបុគ្គលណាដែលពាក់ព័ន្ធនឹងរឿងក្តីនេះត្រូវបង់ប្រដាប់ក្តីនេះទៅតាមចំនួនប្រាក់ដែលតុលការបានកំណត់។ ចំពោះការបង់ប្រាក់ប្រដាប់ក្តីនេះមានភាពចាំបាច់ណាស់សម្រាប់ការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយការធ្វើដំណើរ ស៊ោយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម ឬក្រឡាបញ្ជី ក្នុងករណីពេលធ្វើដំណើរទៅពិនិត្យភស្តុតាង ស្រាវជ្រាវឯកសារអង្គហេតុ ដូច្នេះហើយភាគី ឬបុគ្គលណាដែលទាក់ទងរឿងក្តី ត្រូវបង់ប្រដាប់ក្តីជាមុនសិន ទៅតាមការបង្គាប់របស់តុលាការនៅក្នុងបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ ខាងលើនេះ ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់សកម្មភាពដែលធ្វើឡើងដោយពាក្យ (អ្នកដាក់ពាក្យសុំ) រីឯចំពោះប្រាក់ប្រដាប់ក្តីសម្រាប់សកម្មភាបធ្វើឡើងដោយឆន្ទានុសិទ្ធិតុលាការ គឺអ្នកតុលាការដែលកំណត់ឱ្យបង់។[23] ប្រសិនបើភាគី ឬបុគ្គលណាទាក់ទងរឿងក្តី មិនបានបង់សោហ៊ុយតាមការបង្គាប់របស់តុលាការទេ តុលាការអាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្ត ឬ លុបចោលនូវនីតិវិធីអនុវត្តរក្សាការពារនោះតែម្តង។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៦២

## ១.៣. តុលាការដែលមានសមត្ថកិច្ច

មុននឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុពីតុលាការ ម្ចាស់បំណុលត្រូវធ្វើឡើងសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅស្ថាប័នណា? បើយោងទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលទទួលបានដោយស្របច្បាប់នូវបណ្តឹងវិនិច្ឆ័យលើរឿងក្តីហើយចេញសាលក្រម ឬសាលាដីកាបាន។[24]

### ១.៣.១.តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី

នៅតុលាការដែលមានសមត្ថកិច្ចរឿងក្តីនៃដីកាសម្រេច រក្សាការពារទៅតាមពាក្យសុំរបស់ម្ចាស់បំណុលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។[25] ប្រសិនបើតុលាការអង្គសេចក្តីជាតុលាការនៃការជំនុំជម្រះលើកទី១ ( សាលាដំបូង ) អាចយកតុលាការនេះជាតុលាការមានសមត្ថកិច្ចសម្រាប់សំណុំរឿងរក្សាការពារ។[26]

ឧទាហរណ៍ ៖ លោក ក បានប្តឹង លោក ខ ទាមទារឱ្យសងប្រាក់ទៅសាលាដំបូងរាជធានីភ្នំពេញ ហើយបណ្តឹងកំពុងចាត់ការ ក្នុងករណីនេះដែលសាលាដំបូងរាជធានីភ្នំពេញជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី ហើយសាលាដំបូងរាជធានីភ្នំពេញ ក៍ជាតុលាការដែលមានសមត្ថកិច្ចលើសំណុំរឿងរក្សាការពារផងដែរ។ ហេតុនេះ លោក ក អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារបាននៅសាលាដំបូងរាជធានីភ្នំពេញ។[27]

ក្នុងករណីតុលាការនៃបណ្តឹងអង្គសេចក្តី ជាតុលាការនៃជំនុំជម្រះលើទី២ (សាលាឧទ្ធរណ៍) អាចយកតុលាការនេះ ជាតុលាការមានសមត្ថកិច្ចសម្រាប់សំណុំរឿងរក្សាកាពារផងដែរ។[28]

ឧទាហរណ៍ ៖ សាលាដំបូងបានចេញសាលក្រម អំពីរឿងក្តីទាមទារឱ្យសងប្រាក់កម្ចីរវាង លោក ក និងលោក ខ ។ ហើយលោក ក បានប្តឹងទៅសាលាឧទ្ធរណ៍ភ្នំពេញចំពោះសេចក្តីសម្រេចរក្សាការពារ ដែលសម្រេចក្នុងករណីនេះ សាលាឧទ្ធរណ៍ភ្នំពេញជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី ហើយក៏ជាតុលាការ

[24] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៧

[25] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤០ កថាខណ្ឌទី១

[26] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី១

[27] វគ្គបណ្តុះបណ្តាលច្បាប់សារធាតុ និងនីតិវិធី III សំណុំរឿងចាត់ចែងរក្សាការពារ មេធាវី អ៊ីវ ប៉ូលី និងមេធាវី ទេព បូផល ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២

[28] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី២

ដែលមានសមត្ថកិច្ចលើសំណុំរឿងរក្សាការពារនេះដែរ។ ហេតុនេះ លោក ក អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។[29]

ប៉ុន្តែប្រសិនបើតុលាការអង្គសេចក្តី ជាតុលាការជំនុំជម្រះលើកចុងក្រោយ (តុលាការកំពូល) មិនអាចយកតុលាការនេះ ជាតុលាការមានសមត្ថកិច្ចសម្រាប់សំណុំរឿងរក្សាការពារបានឡើយ ពីព្រោះគោលការណ៍តុលាការកំពូលជាតុលាការអង្គច្បាប់ មិនវិនិច្ឆ័យអង្គហេតុនោះទេ ហើយសិទ្ធិជម្រះពីរដងរបស់គូភាគីនៃសំណុំរឿងរក្សាការពារមិនអាចត្រូវបានផ្តល់ជូនបានឡើយ។ បើទទួលស្គាល់តុលាការកំពូលក្នុងនាមជាតុលាការអង្គសេចក្តីសម្រាប់សំណុំរឿងរក្សាការពារ ហេតុនេះប្រសិនបើបណ្តឹងអង្គសេចក្តីបានទៅដល់តុលាការកំពូល ហើយមានភាគីណាមួយយល់ថាត្រូវធ្វើនីតិវិធីចាត់ចែងរក្សាការពារ ត្រូវបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះទៅតុលាការនៃការជំនុំជម្រះលើកទី១វិញ (តុលាការមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី)។ គួរបញ្ជាក់បន្ថែមថាទោះបីជាពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការដែលមានលំដាប់ផ្សេង (សាលាដំបូង) ពីតុលាការដែលកំពុងចាត់ការបណ្តឹងអង្គសេចក្តី (សាលាឧទ្ធរណ៍) ក៏អាចធ្វើបាន ដោយមិនចាំបាច់តុលាការនៃបណ្តឹងអង្គសេចក្តី ផ្ញើសំណុំរឿងបណ្តឹងអង្គសេចក្តីមកតុលាការកំពុងចាត់ការសំណុំរឿងរក្សាការពារឡើយ ពីព្រោះតុលាការរក្សាការពារពិនិត្យតែសេចក្តីបញ្ជាក់ដំបូងតែប៉ុណ្ណោះ។

### **១.៣.២. សមត្ថកិច្ចតុលាការតាមទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស**

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុ នោះត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះ ហើយបើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាចលនវត្ថុត្រូវបញ្ជាក់អំពីទីកន្លែងចលនវត្ថុនោះ។ វត្ថុដែលជាកម្មវត្ថុនៃវិវាទអាចមានដូចជា ចលនវត្ថុ អចលនវត្ថុ នាវា ហើយក៏អាចមាន កម្មវត្ថុជាសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត។ ហើយវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលមានសិទ្ធិជ្រើសរើសសាលាដំបូងដែលមានសមត្ថកិច្ចបណ្តឹងអង្គសេចក្តីណាក៏បាន ឬដាក់ទៅតាមទីកន្លែងវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសនោះស្ថិតនៅក៏បាន។[30]

ឧទាហរណ៍ ៖ កូនបំណុលមានដី H ដែលមានទីតាំងនៅរាជធានីភ្នំពេញ ក្នុងករណីនេះម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ នៅសាលាដំបូងរាជធានីភ្នំពេញបានក្នុងការរឹបអូសជាបណ្តោះអាសន្នចំពោះដី H ដែលជាកម្មវត្ថុរឹបអូស ( តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តីនៃការរឹបអូសជា

[29] វគ្គបណ្តុះបណ្តាលច្បាប់សារធាតុ និងនីតិវិធី III សំណុំរឿងចាត់ចែងរក្សាការពារ មេធាវី អ៊ីរ ប៉ូលី និងមេធាវី ទេព បូផល ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២

[30] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ សូមមើលមាត្រា ៨

បណ្តោះអាសន្ន )។

ឧទាហរណ៍ ៖ ម្ចាស់បំណុលទាមទារឱ្យកូនបំណុលលុបការចុះបញ្ជីលើដី H ដោយមូលហេតុរំលាយកិច្ចសន្យាដែលដី H មានទីតាំងខេត្តកណ្តាលក្នុងករណីនេះ ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារចាត់ចែងបណ្តោះអាសន្នចំពោះដី H នៅសាលាដំបូងខេត្តកណ្តាល (តុលាការដែលមានសមត្ថកិច្ចលើទីតាំងវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ)។

បើកម្មវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុលត្រូវចាត់ទុកថាសិទ្ធិលើបំណុលនោះស្ថិតនៅកន្លែងរបស់កូនបំណុលទី៣ ដែលបានកំណត់ក្នុងមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[31]

ឧទាហរណ៍ ៖ កូនបំណុល B គ្មានទីកន្លែងរស់នៅពិតប្រាកដសម្រាប់ឱ្យម្ចាស់បំណុលដាក់ពាក្យប្តឹងទៅតុលាការទេ ប៉ុន្តែកូនបំណុលមានកូនបំណុលរបស់ខ្លួនបន្តទៀត (កូនបំណុលទី៣) ម្ចាស់បំណុលអាចជ្រើសរើសទីកន្លែងតុលាការដែលមានសមត្ថកិច្ចនៅទីកន្លែងរបស់កូនបំណុលទី៣ ដែលរស់នៅជាសមត្ថកិច្ចតុលាការវិញបានដោយយោងតាមមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឧទាហរណ៍ ៖ ករណីកម្មវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្នមានច្រើនកន្លែង ដូចជា ដី $B_1$ ស្ថិតនៅខេត្តកំពត ដី $B_2$ ស្ថិតនៅខេត្តកំពងចាម និងដី $B_3$ ស្ថិតនៅខេត្តភ្នំពេញ (កម្មវត្ថុរក្សាការពារមានទីតាំងខុសៗគ្នា) សាលាដំបូងកំពត សាលាដំបូងកំពងចាម និងសាលាដំបូងរាជធានីភ្នំពេញ ជាតុលាការដែលមានសមត្ថកិច្ចលើសំណុំរឿងរក្សាការពារ ហេតុនេះ ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាករពារនៅសាលាដំបូងរាជធានីភ្នំពេញ តុលាការអាចចេញដីកាសម្រេចរក្សាកាពារចំពោះដីទាំងកន្លែងបាន ទោះបីជាដីដែលត្រូវរឹបអូសមានទីតាំងផ្សេងក៏ដោយ។[32]

## ១.៤. អចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

កម្មវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្ន ភាគច្រើនជាអចលនវត្ថុដែលបានចុះបញ្ជីរួចដែលក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ពីឯកសារមួយចំនួនដើម្បីបញ្ជាក់ពីកម្មសិទ្ធិកររបស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ។ ប៉ុន្តែមានអចលនវត្ថុមួយចំនួនតូចដែលកូនបំណុល ឬ ម្ចាស់កម្មសិទ្ធិនៃវត្ថុនោះពុំបានយកទៅចុះបញ្ជីដីធ្លីទេដោយសារជាដីដែលបន្សល់ពីជំនាន់មុន ឬ តំបន់មិនទាន់អភិវឌ្ឍពុំបានដឹងអំពីការចុះបញ្ជីដីធ្លីក្នុងសៀវភៅចុះបញ្ជី។ ហេតុនេះហើយប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូស ជាចំពោះអចលនវត្ថុដែលមិនទាន់ចុះបញ្ជី បានបង្កើតច្បាប់នេះឡើងដើម្បីធានានូវប្រសិទ្ធភាពនៃការចុះបញ្ជី ទាក់ទង

[31] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤០ កថាខណ្ឌទី៣

[32] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤០ កថាខណ្ឌទី២,មាត្រា ១១ និងមាត្រា ១៧

នឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត។

### ១.៤.១. អចលនវត្ថុដែលបានចុះបញ្ជី

តាមក្រមនីតិវិធីរដ្ឋប្បវេណី វត្ថុជាកម្មវត្ថុនៃការរឹបអូសរួមមានដូចជា ចលនវត្ថុ អចលនវត្ថុ នាវា សិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត។ អចលនវត្ថុ ដែលបានចុះបញ្ជីហើយ គឺសំដៅលើអចលនវត្ថុដែលបានចុះបញ្ជីសុរិយោដីដើម្បីទទួលបានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ (ប្លង់រឹង)។ ដោយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនាពេលបច្ចុប្បន្នកម្មវត្ថុជាអចលនវត្ថុ គឺសំដៅទៅលើដីអាគារដែលត្រូវបញ្ជីចំណែកនៃកម្មសិទ្ធិអវិភាគ លើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះជាសិទ្ធិរួម ( សិទ្ធិអវិភាគ )។ អាគារត្រូវបានគេចាត់ទុកថា គឺជាអចលនវត្ថុមួយដែលស្ថិតនៅផ្ទៃដីដែលមានភាពឯករាជ្យ ឬ យ៉ាងណាវាអាស្រ័យទៅលើច្បាប់នីមួយៗនៃប្រទេសនោះ ដោយឡែកច្បាប់នៅប្រទេសកម្ពុជាយើងបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចែងនៅក្នុងមាត្រា ១២២ សមាសភាគនៃដីជាគោលការណ៍ វត្ថុដែលជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសង់នៅ លើដីហើយមិនអាចប្តូរកន្លែងបាន ឬ ពូជដែលសាបនៅលើដីដំណាំដែលបានដាំរុក្ខជាតិដែលរស់នៅលើដី គឺជាសមាសភាគនៃដី[33] លុះត្រាតែមិនបំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មសិទ្ធិឯករាជ្យបានឡើយ លើកលែងតែមានបញ្ញត្តិផ្សេង ពោលមានន័យថាអានុភាពនៃកម្មសិទ្ធិ ឬ សិទ្ធិប្រត្យក្សផ្សេងទៀតដែលមានលើដី ក៏មាន ចំពោះអាគារ ឬ សំណង់លើដីនោះដែរ ដោយកំណត់ថា អាគារ ឬ សំណង់ដែលជាប់នឹងដី គឺជាសមាសភាគនៃដី។ ក្រឡាបញ្ជីត្រូវធ្វើការផ្ទុកផ្តាក់ទៅឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្ន [34] ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីលិខិតផ្ទុកផ្តាក់ ចង់សំដៅទៅលើរដ្ឋបាលសុរិយោដីថ្នាក់រាជធានី/ខេត្ត/ក្រុង រដ្ឋបាលសុរិយោដីថ្នាក់ស្រុក/ខណ្ឌ/ក្រុង ដែលអចលនវត្ថុនោះស្ថិតនៅ។ នៅក្នុងលិខិតផ្ទុកផ្តាកត្រូវសរសេរអំពីក្បាលដី ឬលេខប័ណ្ណ ,ទីតាំងដី,ឈ្មោះកម្មសិទ្ធិករ,អាសយដ្ឋាន ហើយក្រឡាបញ្ជីជាអ្នកផ្ទុកផ្តាក់នូវអចលនវត្ថុនេះត្រូវធ្វើឡើងតាមរយៈលិខិតដែលមានឈ្មោះថា **លិខិតឱ្យផ្ទុកផ្តាក់ឱ្យចុះបញ្ជី** ហើយក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនលិខិតនេះទៅកាន់ស្ថាប័នដែលមានសមត្ថកិច្ចដូចខាងលើ។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ១២២

[34] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦៧ កថាខណ្ឌទី៣ ចំណុច ៣

### ១.៤.២. អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី

អចលនវត្ថុដែលមិនទាន់ចុះបញ្ជី គឺសំដៅទៅលើដី និងចំណែកឯកជននៃអគាសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។[35] ដីដែលមិនទាន់ចុះបញ្ជី គឺសំដៅដល់ដីដែលមិនទាន់បានចុះក្នុងសៀវភៅចុះបញ្ជីដីធ្លីរបស់សុរិយោដី ពោលមានន័យថា អចលនវត្ថុជា ( ប្លង់ទន់ ) ដោយគ្រាន់តែធ្វើឡើងតាមរយៈ ភូមិ/ឃុំ/ ស្រុក/ខណ្ឌ តែប៉ុណ្ណោះ ហើយដែលតុលាការបានសន្មត់ថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬភាគីនៃដីនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី៣ និងមាត្រា ៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[36] រីឯឯកជននៃអាគារសហកម្មសិទ្ធិដែលមិនទាន់ចុះបញ្ជី គឺសំដៅលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដែលមិនទាន់ចុះក្នុងសៀវភៅគោលបញ្ជី ចំណែកឯកជននៃអាគារសហកម្មសិទ្ធិ ដែលតុលាការបានសន្មត់ថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអាគារសហកម្មសិទ្ធិ។ ជាគោលការណ៍ ការធ្វើលិខិតផ្ទុកផ្តាក់ដូចគ្នានិងអចលវត្ថុដែលចុះរួចដែរ ក៏ប៉ុន្តែខ្លឹមសារនៃការកំណត់ជាក់លាក់នូវអចលនវត្ថុខុសគ្នា ( ចំណុចដែលសរសេរក្នុងឧបសម្ព័ន្ធស្តីពីអចលនវត្ថុ )។ គោលបំណងក្នុង ប្រកា១ មានគោលបំណងធានានូវប្រសិទ្ធិភាពនៃការចុះបញ្ជី ទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូស ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត [37] ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនេះ គឺមានតែរដ្ឋបាលសុរិយោដីថ្នាក់រាជធានី/ខេត្ត ឬរដ្ឋបាលសុរិយោដិថ្នាក់ក្រុង/ស្រុក/ខណ្ឌ ហើយបន្ទាប់បីខាងរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង/ស្រុក/ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីហើយត្រូវចុះលេខនៃការទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីក្នុងសៀវភៅទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រក្សត្យ លើអចលនវត្ថុដែលបានបង្កើតឡើងដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត។[38]

[35] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី ប្រការ ៤ ចំណុច ១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

[36] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី ប្រការ ៤ កថាខណ្ឌទី ២ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

[37] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី ប្រការ ១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

[38] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី ប្រការ ៥ កថាខណ្ឌទី ២ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

# ជំពូកទី២ :

# នីតិវិធីតុលាការពាក់ព័ន្ធ
# នឹងការរឹបអូសជាបណ្ដោះ
# អាសន្នចំពោះអចលនវត្ថុ

# ជំពូកទី២

# នីតិវិធីតុលាការពាក់ព័ន្ធនឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

## ២.១. ការពិនិត្យសំណុំរឿងរឹបអូសជាបណ្ដោះអាសន្ន

តុលាការពិនិត្យមើលទៅលើសំណុំរឿងរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុលត្រូវបង្ហាញឯកសារសេចក្ដីបញ្ជាក់ដំបូងដើម្បីឱ្យតុលាការអាចសម្រេចថាគ្រប់លក្ខខណ្ឌដែលបានកំណត់រួមមាន ៖

ក. អត្តសញ្ញាណភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់

ខ. ខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលអ្នកដាក់ពាក្យសុំបានទាមទារ

គ. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តនឹងត្រូវបានរក្សាការពារ

ឃ. ភាពចាំបាច់នៃរក្សាការពារ

សេចក្ដីបញ្ជាក់ដំបូងត្រូវភ្ជាប់ជាមួយពាក្យសុំ ដើម្បីតុលាការពិចារណា ជាដំបូងតុលាការត្រូវពិនិត្យមើលទៅលើឯកសារអំពីសេចក្ដីបញ្ជាក់ដំបូង។ ឯកសារបញ្ជាក់ដំបូងមានដូចជា : ឯកសារកិច្ចសន្យា ប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិ មូលប្បទានប័ត្រ មតកសាសន៍ បង្កាន់ដៃ កំណត់ហេតុ រូបថត របាយការណ៍ដែលធ្វើឡើងដោយម្ចាស់បំណុលផ្ទាល់តែម្ដង។

## ២.២. ការដាក់ប្រាតិភោគ

### ២.២.១. គោលបំណងនៃការដាក់ប្រាតិភោគ

នៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ មានន័យថាយកការដាក់ប្រាតិភោគធ្វើជាលក្ខខណ្ឌចេញដីការក្សាការពារ ពីព្រោះជាទូទៅយតុលាការចេញដីការក្សាការពារដោយមិនសាកសួរកូនបំណុល និងសម្រេចផ្អែកលើសេចក្ដីបណ្ដាក់របស់ម្ចាស់បំណុល ដែលអាចមានករណីខ្លះប៉ះពាល់ផលប្រយោជន៍របស់កូនបំណុលយ៉ាងខ្លាំង ហេតុនេះដើម្បីការពារផលប្រយោជន៍របស់កូនបំណុលតុលាការ អាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ មុនពេលចេញដីកាសម្រេចរក្សាការពារ។[39]

ប្រាតិភោគ គឺជាប្រព័ន្ធធានាសំណងនៃការខូចខាតចំពោះកូនបំណុល នៅក្នុងករណីម្ចាស់បំណុលចាញ់ក្ដីក្នុងបណ្ដឹងអង្គសេចក្ដី។

ឧទាហរណ៍ ៖ ម្ចាស់បំណុល ដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្នចំពោះដី L ដែលជាកម្មសិទ្ធិរបស់កូនបំណុល ផ្អែកលើសិទ្ធិលើបំណុលប្រាក់កម្ចី ក្នុងករណីនេះ តុលាការបាន

[39] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤២

បង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ មុននឹងចេញដីកាសម្រេចរក្សាការពារ ប៉ុន្តែក្រោយមកម្ចាស់បំណុលចាញ់ក្នុងបណ្តឹង អង្គសេចក្តី។

ក្នុងករណីម្ចាស់បំណុលចាញ់ក្តី កូនបំណុលអាចទាមទារសំណងនៃការខូចខាតពីម្ចាស់បំណុលបានដោយផ្អែកលើអំពើអនីត្យានុកូល ហើយប្រសិនបើកូនបំណុលឈ្នះក្តីក្នុងរឿងក្តីទាមទារសំណងនៃការខូចខាត និងធ្វើការអនុវត្តចំពោះ ទ្រព្យសម្បត្តិរបស់ម្ចាស់បំណុលដែលជាកម្មវត្ថុនៃប្រាតិភោគ ដែលបានដាក់នៅក្នុងសំណុំរឿងរក្សាការពារ កូនបំណុលកូនបំណុល និងទទួលបានការសងដោយមានអទិភាពចំពោះប្រាតិភោគដែលបានតម្កល់នោះ។ [40]

ក្រៅពីនេះប្រាតិភោគមានគោលបំណង ដើម្បីទប់ស្កាត់ការប្រើប្រាស់សិទ្ធិដោយបំពានរបស់ម្ចាស់បំណុលពោល គឺម្ចាស់បំណុលមិនអាចធ្វើការរក្សាការពារ ចំពោះទ្រព្យសម្បិត្តិរបស់កូនបំណុលតាមអំពើរចិត្តបានទេ ដោយសារតែត្រូវបំពេញលក្ខខណ្ឌជាច្រើន ហើយប្រាតិភោគក៏អាចជាលក្ខខណ្ឌមួយដែលតម្រូវឱ្យម្ចាស់បំណុលត្រូវបំពេញដែរ។

### ២.២.២. ចំនួននៃប្រាតិភោគ

ក្នុងករណីតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការនឹងពិចារណាអំពីទំហំនៃការខូចខាតកើតឡើងជាយថាហេតុ ចំពោះកូនបំណុល និងកំណត់អំពីចំនួនប្រាតិភោគ។ មូលដ្ឋាននៃការកំណត់ចំនួនប្រាតិភោគ ត្រូវបានកំណត់ដោយផ្អែកលើលក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬសិទ្ធិលើបំណុល និងសេចក្តីបញ្ជាក់ដំបូងដែលម្ចាស់បំណុលបានដាក់។ ផ្ទុយទៅវិញ ប្រសិនបើកម្មវត្ថុនៃការដាក់រឹបអូសជាបណ្តោះអាសន្ន មានតម្លៃធំជាងតម្លៃសិទ្ធិលើបំណុល ចំនួនប្រាតិភោគត្រូវកំណត់តាមតម្លៃសិទ្ធិលើបំណុល ហើយក្នុងករណីតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ ការដាក់ប្រាតិភោគ គឺជាលក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ហេតុនេះម្ចាស់បំណុលត្រូវតែដាក់ប្រាតុភោគទៅតុលាការក្នុងអំឡុងពេលដែលតុលាការកំណត់ មុនពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

### ២.២.៣. នីតិវិធីនៃការដាក់ប្រាតិភោគ

ផ្អែកតាមក្រមនីតិវិធិរដ្ឋប្បវេណី ការដាក់ ឬមិនដាក់ប្រាតិភោគ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ហេតុនេះអាចមានករណីដែលតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ ហើយក៏មានករណីតុលាការមិនបង្គាប់ឱ្យដាក់ប្រាតិភោគដែរ។ ការអនុវត្តជាក់ស្តែង ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុភាគច្រើន ចេញដោយមិនតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៧១

ការដាក់ប្រាតិភោគ ត្រូវធ្វើតាមវិធីតម្កល់ជាប្រាក់ ឬ ជាឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ នៅកន្លែងតម្កល់ ឬវិធីផ្ញើប្រាក់ ឬឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់សមរម្យនៅតុលាការឬវិធីដែលបានកំណត់ផ្សេងៗ [41] ចំពោះវិធីដាក់ប្រាតិភោគ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ចំពោះប្រាតិភោគមានអនុភាពដោយការផ្ញើប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ។

## ២.៣. ការដាក់ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

### ២.៣.១. គោលបំណងនៃការដាក់ប្រាក់រំដោះ

កាលណាបើដីកាសម្រេចរក្សាការពារ ដែលទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្ន បានន័យថាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បី ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប៉ុន្តែនៅពេលដែលបានផ្ញើប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ឬចំនួនទឹកប្រាក់នៃកម្មវត្ថុដែលបានរឹបអូសជាបណ្តោះអាសន្ន ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្នមិនមានអត្ថិភាពទៀតទេ។ ដូច្នេះ តុលាការត្រូវកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អំពីចំនួនទឹកប្រាក់ដែលត្រូវផ្ញើដោយកូនបំណុល ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។[42]

គោលបំណង គឺការពារផលប្រយោជន៍របស់កូនបំណុល និងម្ចាស់បំណុល បើកូនបំណុលផ្ញើចំនួនទឹកប្រាក់ដែលបានកំណត់ដោយតុលាការ កូនបំណុលនោះអាចរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យដែលត្រូវរឹបអូស កូនបំណុលអាចប្រើប្រាស់និងចាត់ចែងទ្រព្យនោះបានដោយសេរី ព្រោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោល។ [43] ប្រសិនបើមានការកើនឡើងតម្លៃគាត់អាចលក់បានថ្លៃ ចំពោះម្ចាស់បំណុលនឹងទទួលបាននូវការពេញចិត្ត ពីចំនួនទឹកប្រាក់របស់កូនបំណុលដែល និងត្រូវបំពេញមកដល់ខ្លួន។ ប្រាក់រំដោះសម្រាប់ជំនួសទ្រព្យដែលត្រូវបានរឹបអូស ដូច្នេះប្រាក់រំដោះគឺស្ថិតនៅក្រោមការអនុវត្តរបស់ម្ចាស់បំណុល។

ដើម្បីទទួលបានប្រាក់រំដោះនេះ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តីថ្មីមួយបន្ថែមទៀតក្នុងករណីដែលម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី ដែលគាត់ទទួលបាននូវលិខិតអនុវត្ត [44] ម្ចាស់បំណុលអាចរឹបអូសសិទ្ធិលើបំណុលខាងលើ ដើម្បីទទួលបានវិញនូប្រាក់ដែលបានផ្ញើដោយផ្អែកលើលិខិតអនុវត្ត។ ដូច្នេះម្ចាស់បំណុលនឹងមានភាពងាយស្រួលក្នុងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុបាន។

---

[41] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា៧ ១

[42] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៧ កថាខណ្ឌទី ១

[43] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦៩ កថាខណ្ឌទី ១

[44] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៣៥០

### ២.៣.២. ចំនួននៃប្រាក់រំដោះ

ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៅត្រង់មាត្រាណាមួយ ចែងអំពីចំនួនប្រាក់រំដោះដែលត្រូវក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះទេ លើកលែងតែតុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការរឹបអូសជាបណ្តោះអាសន្ន។[45] ដូច្នេះ ចៅក្រមមានឆន្ទានុសិទ្ធិក្នុងការសម្រេចអំពីចំនួនប្រាក់រំដោះ។ ដើម្បីរ៉ាប់រង់ឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងការការពារផលប្រយោជន៍សម្រាប់គូភាគី ដូច្នេះ ការដាក់ប្រាក់រំដោះត្រូវពិចារណាតាមពីរចំណុចដោយសមរម្យ។

ចំនួនទឹកប្រាក់សមាមាត្រនៃទ្រព្យដែលត្រូវរឹបអូស បានន័យថាតុលាការត្រូវពិចារណាលើតម្លៃនៃទ្រព្យរបស់កូនបំណុលដែលម្ចាស់បំណុលដែលម្ចាស់បំណុលធ្វើការស្នើសុំរឹបអូស និងយកចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន ជាចំនួនប្រាក់រំដោះដោយសារតែទឹកប្រាក់រំដោះ គឺជាចំនួនទឹកប្រាក់ដែលដាក់ជំនួសនូវទ្រព្យដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន តុលាការជាអ្នកពិចារណាចំនួនបំណុលដែលទាមទារ ។

សិទ្ធិលើបំណុលត្រូវបានរក្សាការពារ ត្រង់នេះតុលាការត្រូវធ្វើយ៉ាងណាឱ្យមានសមតុល្យរវាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល និងចំនួនទឹកប្រាក់ននៃទ្រព្យដែលត្រូវបានរឹបអូស។ តុលាការត្រូវពិចារណាចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារជាចំនួនប្រាក់រំដោះ ដោយសារគោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន នឹងធានានូវការអនុវត្តដោយបង្ខំណាពេលអនាគត ចំពោះកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នដែលមានគោលបំណងឱ្យសងជាប្រាក់ និងប្រាក់ដែលមានតម្លៃសមមូលទៅនឹងចំនួននៃសិទ្ធិលើបំណុល គឺសមរម្យសម្រាប់រឹបអូសដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលបានរៀបរាប់ខាងលើ។

ចៅក្រមអាចកំណត់ចំនួនទឹកប្រាក់រំដោះ ពីការរឹបអូសជាបណ្តោះអាសន្ន ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលឯកសារគម្រូ។

### ២.៣.៣. នីតិវិធីនៃការដាក់ប្រាក់រំដោះ

នៅពេលកូនបំណុលបានផ្ញើប្រាក់រំដោះ កូនបំណុលត្រូវផ្ញើទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការអនុវត្ត។[46]នីតិវិធីលំអិតនៃការផ្ញើប្រាក់នឹងមានកំណត់នៅក្នុង "សេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ស្តីពី នីតិវិធីនៃការផ្ញើប្រាក់ប្រាតិភោគទៅតុលាការ" ដែលក្រសួងយុត្តិធម៌កំពុងធ្វើសេចក្តីព្រាង។

---

45 ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៧ កថាខណ្ឌ

46 ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៧ កថាខណ្ឌទី ២

## ២.៤. ទម្រង់ដីកាវឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

### ២.៤.១. ចំណុចដែលចាំបាច់ដើម្បីបញ្ជាក់អំពីរឿងក្ដី

ដីការសម្រេចវឹបអូសជាបណ្ដោះអាសន្ន ត្រូវមានជាចាំបាច់នូវចំណុចសំខាន់ៗដើម្បីបញ្ជាក់រឿងក្ដីរួមមាន៖ សញ្ញាណនៃភាគី, សញ្ញាណនៃសិទ្ធិលើបំណុលនៃការទាមទារ, និងលេខសុំណំរឿង។ ដោយសារតែដីកាសម្រេចត្រូវបានចេញដោយផ្អែកលើពាក្យសុំ [47] ដីការសម្រេចត្រូវតែជាដីកាសម្រេចដែលទាក់ទងនឹងរឿងក្ដីជាក់លាក់ណាមួយដែលពាក្យសុំត្រូវបានដាក់។ ម្យ៉ាងវិញទៀត យើងមិនអាចបញ្ជាក់អំពីអត្តសញ្ញាណនៃរឿងក្ដីបានឡើយ បើដីកាសម្រេចនោះដីកាសម្រេចនោះមិនសរសេរអំពីចំណុចសំខាន់ៗដើម្បីបញ្ជាក់នូវរឿងក្ដី។

ចំណុចមួយក្នុងចំណោមចំណុចសំខាន់ៗដើម្បីបញ្ជាក់នូវរឿងក្ដី គឺសញ្ញាណដែលទាក់ទងនិងភាគីមានដូចជាឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងឈ្មោះ ហើយអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ចំពោះចំណុច ឯទៀតដែលចាំបាច់ដើម្បីបញ្ជាក់នូវរឿងក្ដី គឺព័ត៌មានទាក់ទងនិងសិទ្ធិលើបំណុលនិងត្រូវបានរក្សាការពារ។ ព័ត៌មានទាក់ទង់នឹងកម្មវត្ថុដែលត្រូវរក្សាការពារ អាចជាចំណុចមួយដែលចាំបាច់សម្រាប់បញ្ជាក់អំពីរឿងក្ដីផងដែល។ ចំពោះខ្លឹមសាសរសេរសម្រាប់ការអនុវត្តជាក់ស្ដែង មានជម្រើសពីរ៖

ទី១៖ ចៅក្រមអាចសរសេរនូវអត្ថន័យទាំងមូលនៃភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដីនៅក្នុងដីកាសម្រេចតែម្ដងក៏បាន ។

ទី២៖ ចៅក្រមអាចសរសេរនូវអត្ថន័យក្នុងទម្រង់សង្ខេបបើភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី ដោយគ្រាន់តែដាក់ថា មានក្នុងឯកសារឧបសម្ព័ន្ធជាការស្រេច។ ម្យាង់វិញទៀតចៅក្រមអាចប្រើបញ្ជីដែលពិពណ៌នាភាគី បញ្ជីសិទ្ធិលើបំណុល និងបញ្ជីទ្រព្យសម្បត្តិដែលបានដាក់ ដោយម្ចាស់បំណុលដែលភ្ជាប់ជាមួយពាក្យសុំ និងបញ្ជាក់អំពីរឿងក្ដីដោយភ្ជាប់ជាមួយនឹងបញ្ជីទាំងនោះទៅ និងដីកាសម្រេចតែម្ដង។ ចំពោះសារៈប្រយោជន៍ គឺភាពខ្លីនៃនីតិវិធីនៃការចេញដីកាសម្រេច ត្រូវមានភាពរហ័សដើម្បីកុំឱ្យកូនបំណុលបញ្ចៀសទ្រព្យរបស់ខ្លួន ទៅឱ្យតតិយជនដែលធ្វើឱ្យខូចខាតប្រយោជន៍ចំពោះម្ចាស់បំណុល។

### ២.៤.២. ចំនួនទឹកប្រាក់សម្រាប់ដាក់ប្រាតិភោគ និងវិធីនៃការដាក់ប្រាតិភោគ

សម្រាប់ប្រាតិភោគ ត្រូវបានដាក់សម្រាប់គោលបំណង ដើម្បីធានាសំណងនៃការខូចខាតដែលកើតឡើងចំពោះកូនបំណុល ដោយសារតែកំហុសរបស់ដីកាសម្រេចរក្សាការពារ។ ដូច្នេះកូនបំណុលមានផលប្រយោជន៍ច្រើនណាស់ចំពោះព័ត៌មានដែលទាក់ទងនិងប្រាតិភោគ ប៉ុន្តែជាធម្មតាកូនបំណុលពុំមានឱកាសទទួលបាននូវ

[47] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣២ កថាខណ្ឌទី១

ព័ត៌មានបែបនេះទេ ដោយសារភាពជាសម្ងាត់នៃការរក្សាការពារ។[48] ប៉ុន្តែល័ក្ខខណ្ឌនៃភាពជាសម្ងាត់លែងមានអត្ថិភាព បន្ទាប់ពីដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅឱ្យកូនបំណុល [49] ហេតុនេះចៅក្រមគម្បីបញ្ជូនព័ត៌មានអំពីប្រាតិភោគទៅក្នុងដីកាសម្រេចដើម្បីប្រាប់ដល់កូនបំណុល អំពីចំនួននៃប្រាតិភោគដែលត្រូវបានដាក់ជាអាទិ៍។

### ២.៤.៣. សេចក្តីសម្រេច

ដីការសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬចាត់ចែងរក្សាការពារ ត្រូវសរសេរបញ្ចូលនូវសេចក្តីសម្រេច ការសម្រេចបញ្ចប់នូវការវិនិច្ឆ័យលើ ពាក្យសុំដែលដាក់ដោយម្ចាស់បំណុល។

### ២.៤.៤. ការកំណត់ជាក់លាក់នូវកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ចំពោះខ្លឹមសារនៃសេចក្តីសម្រេចនេះ តុលាការត្រូវកំណត់ឱ្យច្បាស់នូវកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ដែលវាជាគោលការណ៍សំខាន់ដែលត្រូវតែគោរពជាដាច់ខាត។[50] ប្រសិនបើតុលាការធ្វើការកំណត់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នស្ថិតក្នុងភាពមិនច្បាស់លាស់ នោះការអនុវត្តដីការសម្រេចនឹងជួបបញ្ហាជាក់ជាមិនខាន។ ជាពិសេសទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុ ដែលទាមទារឱ្យមានព័ត៌មានគ្រាប់គ្រាន់អំពីចលនវត្ថុនោះ។ ចំពោះព័ត៌មានដែលទទួលបាន គឺតាមរយៈឯកសារដែលបានភ្ជាប់មកជាមួយពាក្យសុំ ឬឯកសារអំពីការធ្វើសេចក្តីបញ្ជាក់ដំបូងដែលម្ចាស់បំណុលបានដាក់។[51]

ព័ត៌មានដែលសំខាន់សម្រាប់អចលនវត្ថុ គឺឯកសារដែលចេញឱ្យដោយការិយាល័យជំនាញភូមិបាល ជាពិសេសប័ណ្ណកម្មសិទ្ធិអចលនវត្ថុរបស់កូនបំណុល ប្រសិនបើម្ចាស់បំណុលអាចរកបាន។ ទន្ទឹមគ្នានោះសម្រាប់ចលនវត្ថុវិញដូចជា រថយន្តព័ត៌មានដែលអាចកំណត់បាននូវភាពជាក់លាក់របស់រថយន្តនោះ គម្បីចុះបញ្ជីលេខរថយន្តនោះដូចជាប្រភេទរថយន្ត, សេរីឆ្នាំ, ពណ៌, ប្រទេសដែលផលិត, ស្ថានភាពរថយន្ត និងម្ចាស់កម្មសិទ្ធិ។[52]

ចៅក្រមអាចប្រើប្រាស់បញ្ជីពិពណ៌ណនាអំពីទ្រព្យសម្បត្តិដែលម្ចាស់បំណុលបានដាក់ជាមួយពាក្យសុំ និងបញ្ជាក់ពីកម្មវត្ថុនៃដីកាសម្រេចតាមរយៈ បញ្ជីពិពណ៌នាអំពីទ្រព្យដែលភ្ជាប់ជាមួយនិងពាក្យសុំ។

ទោះយ៉ាងទៀតសោតទោះបីជាមាត្រា៥៤៦ វាក្យខ័ណ្ឌទី១ បានចែងថា "តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយកំណត់ជាក់លាក់នូវកម្មវត្ថុ" ក៏ពិតមែនដែលនេះជាគោលការណ៍ទូទៅដែល

[48] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤២
[49] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៣
[50] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៦ វាក្យខណ្ឌទី១
[51] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ១៣១
[52] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៣៨៧

ត្រូវគោរព។ ប៉ុន្តែវាក្យខណ្ឌទី២ នៃមាត្រា៥៤៦ បានចែងថា "ប៉ុន្តែចំពោះដីកាសម្រេចរឹបអូសអចលនវត្ថុជាបណ្តោះអាសន្នអាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុ" ។

គួរកត់សម្គាល់ និងបែងចែកឱ្យបានច្បាស់ទៅលើស្ថានភាព នៃការរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុ។ ចំពោះអចលនវត្ថុ នៅពេលដែលអនុវត្តដីកាសម្រេច ត្រូវធ្វើការចុះបញ្ជូដើម្បីបញ្ជាក់ថា អចលនវត្ថុនោះត្រូវបានរឹបអូសជាបណ្តោះអាសន្នសិន [53] ដូច្នេះ ដើម្បីឈានទៅធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នូវទ្រព្យបានតម្រូវឱ្យមានការកំណត់ជាក់លាក់នូវជំរិញអចលនវត្ថុនោះតាំងនៅ។ ផ្ទុយទៅវិញចំពោះចលនវត្ថុ ពេលអនុវត្តដីកាសម្រេច គឺអាជ្ញាសាលា និងចុះទៅដល់ទីតាំងដែលចលនវត្ថុនោះតាំងនៅរួចធ្វើការរឹបអូសចលនវត្ថុនោះផ្ទាល់តែម្តងដែលវាក៏ជាភាពលំបាកមួយ សម្រាប់ចៅក្រមមិនដឹងអំពីប្រភេទនៃចលនវត្ថុរបស់កូនបំណុលទេ។[54] ដូច្នេះ ច្បាប់មិនតម្រូវឱ្យចៅក្រមកំណត់ជាក់លាក់ អំពីចលនវត្ថុនៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នឡើយ។[55]

## ២.៤.៥. បន្ទុកនៃប្រាក់ប្រដាប់ក្តី

ពេលដែលសម្រេចសេចក្តីលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារត្រូវធ្វើឡើង សេចក្តីសម្រេចនោះត្រូវកំណត់អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ( បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចនេះអាចត្រូវបានប្តឹងទៅតុលាការថ្នាក់ខ្ពស់ ដូច្នេះសេចក្តីសម្រេចនេះឆ្លើយតបទៅនឹង "សេចក្តីសម្រេចដែលបញ្ចប់រឿងក្តីនៅក្នុងតុលាការ" ) ។[56] ដោយភាពជាក់ស្តែងនៅក្នុងការអនុវត្ត យើងពុំងាយឃើញថាបន្ទុកប្រាក់ប្រដាប់ក្តីជាកាតព្វកិច្ចរបស់កូនបំណុលនៃការរឹបអូសណាស់ ព្រោះដោយមានហេតុផលថាកូនបំណុល គឺបានធ្វើឱ្យមានការខាត់បង់នូវផលប្រយោជន៍របស់ម្ចាស់បំណុល ដូច្នេះហើយទើបបានជាបន្ទុករបស់កូនបំណុល។

នៅពេលដែលដីកាសម្រេចទទួលស្គាល់ពាក្យសុំដីកាសម្រេចរក្សាកាពារត្រូវបានធ្វើមានលទ្ធភាពពីរផ្លូវ

- ទស្សនៈទី១ គឺថាដីកាសម្រេចនេះត្រូវកំណត់បន្ទុកនៃប្រាក់ប្រដាប់ ( បណ្តឹងតវ៉ាចំពោះ ដីកាសម្រេចនេះអាចត្រូវមិនឆ្លើយតបទៅនឹង "ការសម្រេចសេចក្តីដែលបញ្ចប់រឿងក្តីនៅក្នុងតុលាការ" ) ។[57]
- ទស្សនៈផ្សេងទៀត គឺថាដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចរក្សាការពារត្រូវកំណត់ប្រាក់ប្រដាប់ក្តី។

[53] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រ ៥៦៧ កថាខណ្ឌទី៤ និងមាត្រា ៤២០ កថាខណ្ឌទី២

[54] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦៥

[55] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៤៦ កថាខណ្ឌទី ២

[56] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា៦៥ កថាខណ្ឌទី ១

[57] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៦៥ កថាខណ្ឌទី ១

ជានិច្ចជាកាល បណ្ដឹងជំទាស់មិនត្រូវបានគេធ្វើចំពោះដីការសម្រេច ដែលទទួលស្គាល់នូវពាក្យសុំឡើយ នៅក្នុងករណីនេះបន្ទុកនៃប្រាក់ប្រដាប់ក្ដីមិនត្រូវសម្រេចឡើយ។ ដើម្បីជៀសនូវស្ថានភាពនេះគេបកស្រាយថា ដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចរក្សាការពារ ត្រូវកំណត់អំពីបន្ទុកប្រាក់ប្រដាប់ក្ដី។

## ២.៥. ការសម្រេចលើពាក្យសុំរបស់តុលាការ

### ២.៥.១. វិធីនៃការវិនិច្ឆ័យ

នៅក្នុងការសម្រេចសេចក្ដី ដែលធ្វើឡើងទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងដោយដីកាសម្រេច ដូច្នេះនីតិវិធីនេះមិនធ្វើតាមនីតិវិធីបណ្ដឹងនោះទេ គឺត្រូវធ្វើតាមនីតិវិធីនៃការចេញដីកាសម្រេច។ ដោយហេតុនេះហើយ ចំពោះការទាញហេតុផលដោយផ្ទាល់មាត់ គឺពុំមានភាពចាំបាច់ជានិច្ចជាកាលនោះទេ ពោល គឺតុលាការត្រូវកំណត់ថា តើត្រូវធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ ឬក៏មិនត្រូវធ្វើ? ។ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺទាមទារឱ្យធ្វើឡើងដោយការសម្ងាត់ដែលតម្រូវឱ្យមានភាពអត្ថិភាពមួយនៃសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ។ ហេតុនេះហើយ ចាំបាច់ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីចំណុចទាំងនេះ ប្រសិនបើតម្រូវឱ្យបញ្ជាក់តែម្ដងបែបនេះ គឺមិនមានអ្វីខុសគ្នាអំពីបណ្ដឹងអង្គសេចក្ដីនោះទេ ។

### ២.៥.២. ដីកាសម្រេចតាមពាក្យសុំ

នៅក្រោយពេលដែលតុលាការបានពិនិត្យ នូវពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ចំពោះការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុរបស់ម្ចាស់បំណុល និងនៅពេលក្រោយពីបានសាកសួរទៅកាន់ម្ចាស់បំណុលរួចតុលាការត្រូវចេញដីកាសម្រេចរក្សាការពារ អំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ ប្រសិនបើតុលាការយល់ឃើញថាលក្ខខណ្ឌនៃការទាមទារ និងភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ និងលក្ខខណ្ឌចាំបាច់ផ្សេងៗទៀតមានភាពគ្រប់គ្រាន់ និងមានភាពត្រឹមត្រូវតាមច្បាប់ហើយនោះជាគោលការណ៍តុលាការត្រូវចេញដីកាសម្រេចរក្សាការពារ ចំពោះការរឹបអូសជាបណ្ដោះអាសន្ននោះ ដោយធ្វើការកំណត់ជាក់លាក់នូវកម្មវត្ថុទៅតាមពាក្យសុំរបស់ម្ចាស់បំណុល បន្ទាប់ពីចេញដីកាសម្រេចរក្សាការពារ ចំពោះការរឹបអូសជាបណ្ដោះអាសន្នតុលាការអនុវត្តផងដែរនោះ ក៏ត្រូវបញ្ជូនដីកាសម្រេចរក្សាការពារចំពោះការរឹបអូសជាបណ្ដោះអាសន្ននោះទៅកាន់គូភាគីផងដែល។

### ២.៥.៣. ដីកាសម្រេចលើកចោលពាក្យសុំ

នៅក្នុងករណីដែលពាក្យសុំចេញដីកាសម្រេចរក្សាការពារ ចំពោះការរឹបអូសជាបណ្ដោះអាសន្នមានភាពខ្វះខាតនូវលក្ខខណ្ឌណាមួយនៃភាពចាំបាច់សម្រាប់ធ្វើបណ្ដឹង ( ដែលអនុវត្តដូចគ្នាចំពោះនីតិវិធីនៃបណ្ដឹងដែលនៅក្នុងនោះមានដូចជាសមត្ថភាពភាគី និងលក្ខណៈសម្បត្តិជាភាគី ជាអាទិ៍ ) នោះពាក្យសុំឱ្យចេញនូវដីកា

សម្រេចរក្សាការពារ ចំពោះការរឹបអូសជាបណ្តោះអាសន្នរបស់ម្ចាស់បំណុលនឹងត្រូវបានលើកចោល។ ហើយប្រសិនបើមានការខ្វះនូវលក្ខខណ្ឌចាំបាច់ នៃការទាមទារណាមួយរបស់ម្ចាស់បំណុល សម្រាប់ការរឹបអូសជាបណ្តោះអាសន្ន នោះក៏ត្រូវបានធ្វើការលើកចោលដូចគ្នាផងដែល ( ដែលនៅក្នុងទ្រឹស្តីវាគួរតែជាការច្រានចោលតែនៅទីនេះវា គឺជាការលើកចោល )។ ហេតុដូច្នេះ តុលាការត្រូវធ្វើការលើកចោលពាក្យសុំចេញដីកាសម្រេចរក្សាការពារនេះ ហើយរីឯដីកាសម្រេចលើកចោលពាក្យសុំ គឺភាគីម្ចាស់បំណុលអាចធ្វើការប្តឹងជំទាស់បានដែលអំឡុងពេលនៃការប្តឹងជំទាស់មានរយៈពេលពី ១ សប្តាហ៍ ទៅដល់ ២ សប្តាហ៍ទៅតាមភាពស្មុគស្មាញរបស់វា។[58] ចំពោះដីកាសម្រេចលើកចោលពាក្យសុំ របស់ម្ចាស់បំណុល ដែលបានប្តឹងសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺពុំចាំបាច់បញ្ជូនទៅឱ្យកូនបំណុលនោះទេ ដោយហេតុថាដីកាសម្រេចលើកចោលពាក្យសុំនោះ ពុំបានប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលទេ ហើយម៉្យាងទៀត ក៏ជាការទុកឱកាសឱ្យម្ចាស់បំណុលស្វែងរកភស្តុតាងបន្ថែមទៀតសម្រាប់ប្តឹងសុំដីកាសម្រេចរឹបអូសជាថ្មីទៀតដែរ ហើយការអនុវត្តរបៀបនេះក៏អាចរក្សាការសម្ងាត់ឱ្យម្ចាស់បំណុលផងដែរ។

ដូច្នេះចំពោះ "ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន" នៅមាត្រា ៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី គម្បីត្រូវពិចារណាក្នុងន័យថាជា ដីកាសម្រេចបង្គាប់ឱ្យរក្សាការពារ។

ជាទូទៅការអនុវត្តដូចគ្នានៃមាត្រា ២១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺមិនស្រប់គ្នានឹងការសម្ងាត់នៃនីតិវិធីរក្សាការពារឡើយ ដូច្នេះមាត្រា ២១៣ មិនអនុវត្តដូចគ្នាចំពោះករណីនេះទេ។

ប៉ុន្តែបើតុលាការធ្វើការសួរកូនបំណុល ឬធ្វើការទាញហេតុផលដោយផ្ទាល់មាត់មុនពេលចេញដីកាសម្រេច តុលាការត្រូវជូនដំណឹងទៅកូនបំណុល ឬធ្វើការទាញហេតុផលដោយផ្ទាល់មាត់មុនពេលចេញដីកាសម្រេច តុលាការត្រូវដំណឹងទៅកូនបំណុលអំពីដីកាសម្រេចលើកចោលនូវពាក្យសុំ។ ដូច្នេះមានន័យថា មាត្រា ២១៣ គឺអនុវត្តដូចគ្នាទៅនឹងករណីនេះ។

## ២.៦. ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅក្នុងការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមរយៈនីតិវិធីដែលច្បាប់បានកំណត់ ដើម្បីធ្វើការជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងជូនចំពោះគូរភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធ និងផលប្រយោជន៍។[59]រីឯការជូនដំណឹង គឺជាវិធីមួយដែលមានលក្ខខណ្ឌទូលាយ និងមានភាពអាយស្រួលជានីតិវិធីនៃការបញ្ជូនដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើប្រាស់មធ្យោបាយដូចជា តាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសនីយ៍

[58] មាត្រា ៥៤៤ នៃសេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

[59] ឯកសាបង្រៀនសិស្សក្រឡាបញ្ជីជំនានទី ៤ ហេងសុខណា នៃរាជបណ្ឌិតសោភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០១៦

សំបុត្រដាដើម ដើម្បីឱ្យអ្នកដែលនឹងត្រូវការទទួលបញ្ជូននោះបានដឹង ។ ដីកាសម្រេចរក្សាការពារ តុលាការត្រូវតែបញ្ជូនដីកាសម្រេចរក្សាការពារនោះទៅភាគី។ [60] ការបញ្ជូនត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់[61] ហើយឯកសារដែលត្រូវបានបញ្ជូន គឺជាឯកសារដែលថតចម្លងលើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។

មន្ត្រីដែលទទួលបន្ទុកនៅក្នុងការបញ្ជូន គឺជាក្រឡាបញ្ជី រីឯការបញ្ជូនត្រូវប្រតិបត្តិដោយបុគ្គលិកប្រៃនីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី។[62] ចំពោះមុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកនៅក្នុងការបញ្ជូនមានដូចជា៖

- ធ្វើ ឬ ផ្តល់នូវសេចក្តីបញ្ជាក់នូវឯកសារសម្រាប់ធ្វើការបញ្ជូន
- ធ្វើការប្រគលអំណាចនៃការបញ្ជូននោះ ទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន
- បន្ទាប់មកធ្វើការទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការណ៍បញ្ជូន រួចមកក្រឡាបញ្ជីត្រូវយករបាយការណ៍នោះទៅជូនចៅក្រម ដើម្បីឱ្យចៅក្រមធ្វើការពិនិត្យមើលថា តើការបញ្ជូននោះត្រឹមត្រូវតាមនីតិវិធី ឬទេ?
- ជាចុងក្រោយ មន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវធ្វើការរក្សាទុករបាយការណ៍នៃការបញ្ជូននេះនៅក្នុងសុំណុំរឿង តាមកាលបរិច្ឆេទនៃលំដាប់ឯកសារទាំងអស់នោះ ដើម្បីបញ្ជាក់ថាឯកសារដែលត្រូវធ្វើការបញ្ជូននោះ គឺបានបញ្ជូនទៅដល់អ្នកដែលត្រូវទទួលការបញ្ជូនរួចហើយ។ រីឯមុខងាមន្ត្រីទទួលបន្ទុកប្រតិបត្តិការណ៍បញ្ជូនមានដូចជា ៖
  - ➢ ធ្វើការបញ្ជូនដោយជាក់លាក់ចំពោះជនដែលត្រូវទទួលការបញ្ជូន
  - ➢ ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូន[63]
  - ➢ ត្រូវដាក់របាយការណ៍អំពីការបញ្ជូននោះទៅតុលាការដើម

របាយការណ៍បញ្ជូនដែលមន្ត្រីដែលទទួលបន្ទុកនៅក្នុងការបញ្ជូនត្រូវធ្វើ ការបញ្ជាក់អំពីចំណុចដូចជា[64]៖

ក. សញ្ញាណនៃរឿងក្តី និងឯកសារត្រូវធ្វើការបញ្ជូន

ខ. ជនដែលត្រូវទទួលការបញ្ជូន

គ. ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានបញ្ជូន

---

[60] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥៣

[61] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៤៦

[62] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៦

[63] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៤ កថាខណ្ឌទី ១

[64] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៤ កថាខណ្ឌទី ២

ឃ. វិធីបញ្ជូន

ង. ចំណាត់ការនៅក្នុងការបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ

ច. ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកទទួលឯកសារ

ឆ. ហេតុការណ៍ដែលអ្នកទទួលការបញ្ជូនមិនព្រមទទួល ( ក្នុងករណីបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោ ។ល។ )

ជ. ហេតុការនៅក្នុងករណីនៃការបញ្ជូនតាមវិធីបង្គ្រប់កិច្ច និងទុកចោល

ឈ. ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។

### ២.៦.១. វិធីនៃការបញ្ជូនដីកា

វិធីនៃការបញ្ជូនមានច្រើនប្រភេទ ដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដូនេះមន្ត្រីដែលទទួលបន្ទុកលើប្រតិបត្តិការណ៍បញ្ជូនត្រូវធ្វើប្រតិត្តិការណ៍ដោយយកចិត្តទុកដាក់។ វិធីនៃការបញ្ជូនមាន ៥ ទម្រង់ដូចខាងក្រោម៖

- **ការបញ្ជូនដោយប្រគល់**

ជាគោលការណ៍ ត្រូវប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ [65] ការបញ្ជូនត្រូវបញ្ជូនទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលនឹងត្រូវទទួលការបញ្ជូន។[66] លំនៅឋានគឺជាកន្លែងដែលជាទីទាំងជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗចំណែកឯទីសំណាក់ គឺក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់នោះទេ ទីសំណាក់ត្រូវចាត់ទុកជាលំនៅឋាន។ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់ គឺអាចធ្វើការបញ្ជូនទៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់អ្នកតំណាងបាន។

- **ការបញ្ជូនដោយបង្គ្រប់កិច្ច**

បើនៅក្នុងករណីដែលមិនបានជួបជនដែលទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូននោះទេ គឺអាចប្រគល់ឯកាសារនោះទៅអ្នកបំរើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬអ្នកនៅជាមួយដែលមានសមត្ថភាពដែលយល់ ដឹងសមរម្យបាន។[67] អ្នកដែលមានសមត្ថភាពយល់ដឹងសមរម្យក្នុងការទទួលឯកសារ៖

- អ្នកដែលមានការយល់ដឹងច្បាស់លាស់អំពីសារៈសំខាន់នៃការបញ្ជូន
- អ្នកដែលយល់អំពីអត្ថន័យនៃឯកសារដែលខ្លួនបានទទួល
- អ្នកដែលមានសមត្ថភាពយកឯកសារនោះ ទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូន។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៧៤ កថាខណ្ឌទី ១

[66] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៤៩

[67] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥២ កថាខណ្ឌទី ១

- **ការបញ្ជូនដោយទុកចោល**

កាលណាបើជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារ ដោយការបញ្ជូនដោយបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូនដោយមិនមានបញ្ជាក់នូវហេតុផលច្បាស់លាស់នោះទេ អ្នកប្រតិបត្តិការបញ្ជូនអាចទុកឯកសារនៅទីកន្លែងនោះបាន។[68]

- **ការបញ្ជូនទៅបរទេស**

បើជនដែលត្រូវទទួលការបញ្ជូន មានទីលំនៅឯបរទេស ហើយពុំមានទីសំណាក់ ឬ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការដែលអាចបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ នោះការបញ្ជូនចំពោះជននោះអាចមានពីរ (២) ករណី ៖

ករណីទី១ ៖ ករណីជនដែលត្រូវទទួលការបញ្ជូនជាជនបរទេសគម្បីធ្វើការបញ្ជូនទៅឱ្យក្រសួង ឬក៏ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសដែលជន ត្រូវទទួលការបញ្ជូននោះជាអ្នកអនុវត្តការបញ្ជូនបន្ត។

ករណីទី២ ៖ ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស គម្បីធ្វើការបញ្ជូនដោយប្រគល់ទៅឱ្យអាគ្គរាជទូតកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។[69]

- **ការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖[70]

- ក្នុងករណីដែលបានខិតខំប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណា នៅតែមិនដឹងពីទីកន្លែងដែលត្រូវបញ្ជូន
- ករណីដែលបានដឹងពីទីកន្លែងដែលត្រូវបញ្ជូន តែការបញ្ជូនមិនអាចធ្វើទៅបានទោះបីព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយធ្វើការទុកចោលក៏ដោយ
- ករណីដែលមិនអាចធ្វើការបញ្ជូនទៅបរទេសបាន
- ករណីដែលតុលាការមិនអាចទទួលលិខិតបញ្ជាក់ពីការបញ្ជូនពីក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ច នៅបរទេសក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែគិតចាប់ពីពេលបញ្ជូន។

ដើម្បីធ្វើការផ្សាយជាសាធារណៈបាន មានតែពាក្យសុំរបស់ភាគីដែលស្នើសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និងបន្ទាប់ពីបានទទួលការអនុញ្ញាតដោយតុលាការ ក៏ប៉ុន្តែតុលាការក៏អាចបង្គាប់

[68] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥២ កថាខណ្ឌទី ២

[69] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៣ កថាខណ្ឌទី ១

[70] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៦

ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈបាន ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបើទោះបីជាគ្មានពាក្យសុំពីភាគីក៏ដោយ ចំពោះករណីដែលតុលាការយល់ឃើញថាជាករណីចាំបាច់។[71]

ប្រសិនបើការបញ្ជូនតាមការផ្សាយជាសាធារណៈនោះ ត្រូវបានធ្វើក្នុងករណីដែលលក្ខខណ្ឌ ដែលការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយ តែនៅតែមិនអាចបញ្ជូនទៅដល់ជនដែលត្រូវទទួលការបញ្ជូននោះបាន ក្រឡាបញ្ជីគម្បីជូនដំណឹងដោយរបៀបសមរម្យតាមរយៈ ទូរស័ព្ទ ផ្ញើតាមប៉ុស្តិ៍ប្រៃសនីយ៍ ឬបិទតាមលំនៅឋាន ទីសំណាក់របស់ជនដែលត្រូវទទួលការបញ្ជូនជាដើម ។

ហើយការបញ្ជូនជាសាធារណៈមានអនុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាស។ ការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈ ដែលត្រូវធ្វើនៅបរទេសវិញ នឹងមានអនុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦ ( ប្រាំមួយ ) សប្តាហ៍បន្ទាប់ពីការបិទប្រកាស។[72] អានុភាពនៅទីនេះមានន័យថាការបញ្ជូនត្រូវបានប្រតិបត្តិការណ៍ និងត្រូវចាត់ទុកថាអ្នកដែលទទួលការបញ្ជូនបានទទួលការបញ្ជូននេះ។

### ២.៦.២. ការបញ្ជូនទៅបុគ្គលដែលពាក់ព័ន្ធ

ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពនៅក្នុងបណ្តឹង ទាល់តែបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ បញ្ញត្តិផ្សេងទៀតបានទើបបុគ្គលនោះអាចធ្វើសកម្មភាពតាមបណ្តឹងដោយខ្លួនឯងបាន។[73] ចំពោះបុគ្គលដែលអសមត្ថភាពក្នុងការធ្វើបណ្តឹងមាន[74]៖

១. អនិតិជន

២. ជនក្រោមអាណាព្យាបាលទូទៅ

៣. ជននៅក្រោមហិតូបត្ថម្ភ។

ជនទាំងបីប្រភេទខាងលើនេះ អាចធ្វើសកម្មភាពបណ្តឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់។

មានករណីលើកលែងដែលអាចឱ្យជននោះអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានដោយមិនត្រូវការមានអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងករណីដូចជា៖

**ករណីទី១ ៖** អនីតិជនដែលទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន [75] គឺជាអនីតិជនដែលទទួលបានការអនុញ្ញាតឱ្យប្រកបអាជីវកម្មមានសមត្ថភាពក្នុង

---

[71] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/0៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៥

[72] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/0៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៧

[73] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/0៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៣

[74] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/0៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៥៤

ការធ្វើបណ្តឹង មានត្រឹមតែបណ្តឹងដែលមានទំនាក់ទំនងនឹងជំនួញតែប៉ុណ្ណោះ។ ហេតុដូច្នេះបើទោះបី អនីតិជន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មក៏ដោយ ប្រសិនបើមិនមែនជាបណ្តឹងទាក់ទងទៅនឹងអាជីវកម្មដែល បានអនុញ្ញាតនោះទេអនីតិជននៅតែអសមត្ថភាពដដែល។

**ករណីទី២ ៖** អនីតិជនដែលទទួលបានអត្តាធិនភាព ទោះបីជាគូភាគីបានលែងលះគ្នាក៏ដោយក៏ អត្ថិភាពនៃអត្តាធិនភាពនៅតែបន្ត[76] ចំណែកឯការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពនៅក្នុងបណ្តឹង ត្រូវបញ្ជូន ទៅអ្នកដំណាងដែលច្បាប់បានកំណត់។ ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាងរួមគ្នាជាច្រើននាក់ ការបញ្ជូននេះ ក៏អាចធ្វើទៅចំពោះតែជនណាម្នាក់ក៏ជាការបង្ហាញថា បានបញ្ជូនទៅដល់ជនដែលអសមត្ថភាពនៅក្នុង បណ្តឹងដែរ។

## ២.៧. ការអនុវត្តដីការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

### ២.៧.១. លក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត គឺដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមានអនុភាព អនុវត្តភ្លាម និងក៏ជាគោលការណ៍ដែលត្រូវធ្វើការអនុវត្តភ្លាមៗ ដោយហេតុថាមានការកម្រិតអំឡុងពេលនៃការ អនុវត្ត។ មានន័យថាអត្ថិភាពនៃអនុភាពអនុវត្តមិនចាំបាច់ត្រូវធ្វើនិយ័តកម្មដោយរូបមន្តអនុវត្តទេ។ ហេតុដូច្នេះ ហើយជាគោលការណ៍ ការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវបានធ្វើឡើងដោយធ្វើការផ្អែកលើឯកសារ ចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ។ ប៉ុន្តែបើកាលណាការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវ បានអនុវត្តចំពោះជនក្រៅភាគី ឬសម្រាបជនក្រៅពីភាគីដែលបានកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះ អាសន្នចំពោះអចលនវត្ថុ ហើយការអនុវត្តនេះទាមទារឱ្យផ្តល់នូវរូបមន្តអនុវត្តដែលជារូបមន្តអនុវត្តពិសេស។[77]

អំឡុងពេលនៃការអនុវត្ត នៃការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មិនអាចអនុវត្តបានទៀត ឡើយប្រសិនបើកាលណាមិនបានអនុវត្តនៅក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលដីកាសម្រេចរឹបអូស ជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលត្រូវបានបញ្ជូនទៅម្ចាស់បំណុល។[78] មូលហេតុនៃការកំណត់បែបនេះ ពីព្រោះថាបើកាលណាមិនអនុវត្តភ្លាមៗនោះទេ នោះការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និងមិនមាន

[75] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២០

[76] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៧ កថាខណ្ឌទី ៣

[77] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២

[78] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ និង វាក្យខណ្ឌ ទី២

ភាពចាំបាច់ឡើយ ក៏ប៉ុន្តែវាក៏ជាសកម្មភាពគ្រប់គ្រាន់ហើយនៅក្នុងការចាប់ផ្តើមការអនុវត្ត នៅក្នុងអំឡុងពេលពីរ (២) សប្តាហ៍ ចំពោះសកម្មភាពបន្តបន្ទាប់ទៅទៀតនៃការអនុវត្ត មិនចាំបាច់ត្រូវធ្វើនៅក្នុងអំឡុងពេលនេះទេ។

រីឯអំឡុងពេលនេះ មិនកែប្រែជាថ្មីដោយដីកាសម្រេចទទួលស្គាល់ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលចេញដោយសារមានការដាក់ពាក្យសុំតវ៉ានោះឡើយ។ ប៉ុន្តែនៅក្នុងករណីដែលការអនុវត្តដីកាសម្រេចរឹបអូជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើការផ្អាកនៅមុនពេលដែលផុតអំឡុងពេលនេះ ត្រូវចាត់ទុកថាអំឡុងពេលមានដំណើរការពីដំបូង ចាប់ពីពេលដែលការផ្អាកបានកន្លងផុត។ បើទោះបីអំឡុងពេលនេះបានកន្លងផុតក៏ដោយ ក៏មិនធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចនវត្ថុបាត់បង់អនុភាពក៏ដោយ ក៏គេអាចធ្វើឧបាស្រ័យចំពោះការអនុវត្តនៅពេលក្រោយពេលដែលផុតអំឡុងពេល ដោយសារការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត ឬ ដោយសារបណ្តឹងជំទាស់បានដែល។[79]

ចំពោះការបញ្ជូនលិខិតអនុវត្ត បើទោះបីនៅមុនពេលដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ជូនទៅតុលាការក៏ដោយ ក៏ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ អាចប្រព្រឹត្តិបានដែល។[80] បញ្ញាតិនេះត្រូវបានកំណត់ដោយផ្អែកទៅលើភាពឆាប់រហ័ស និងមានភាពជាក់លាក់ជាការសម្ងាត់ដែលជាគោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន។

### ២.៧.២. ប្រភេទផ្សេងៗ នៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ចំពោះការអនុវត្តជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជាមូលដ្ឋានត្រូវធ្វើទៅតាមការអនុវត្តការរឹបអូសនៅក្នុងករណីនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារឱ្យមានការសងជាប្រាក់។ ប៉ុន្តែជាគោលការណ៍ ការអនុវត្តនេះមិនឈានចូលដល់ដំណាក់កាលនៃការប្តូរជាប្រាក់ទេ។ ហើយនៅគ្រប់ករណីទាំងអស់ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចនលវត្ថុ ចាប់ផ្តើមដោយធ្វើការដាក់ពាក្យសុំរបស់ភាគីម្ចាស់បំណុល ទៅស្ថាប័នអនុវត្ត។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវប្រព្រឹត្តិទៅតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ។ ចំពោះតុលាការដែលមានសមត្ថកិច្ច ជាតុលាការអនុវត្តរក្សាការពារ គឺជាតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។ ក្រឡាបញ្ជី ត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសម្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជាមូលដ្ឋានមានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ។[81]

[79] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៣៨៤

[80] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦២ កថាខណ្ឌទី ៣

[81] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦៧

### ២.៧.៣. ការផ្អាក និង ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ក៏អាចត្រូវបានផ្អាក នៅក្នុងលក្ខណៈជាការផ្អាកការអនុវត្តដោយសារមានពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឱ្យលុបចោល នូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និងពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬ ពាក្យសុំលុបចោល ការផ្អាកការអនុវត្តដោយាសារមានការតវ៉ាចំពោះការអនុវត្ត និងដោយសារការដាក់ញបណ្តឹងជំទាស់ (មាត្រា ៣៤៣ កថាខណ្ឌទី២ ,មាត្រា ៣៤៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ការផ្អាក់ការអនុវត្តដោយសារមានបណ្តឹងជំទាស់ជាអាទិ៍ (មាត្រា ៣៦៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខុសប្លែកអំពីការអនុវត្តដោយបង្ខំ ការផ្អាកនៅក្រោយពេលការអនុវត្តមិនសូវមានន័យទេ ពីព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការរឹបអូសតែប៉ុណ្ណោះ។

ស្រដៀងគ្នាទៅនិងករណីនៃការអនុវត្តដោយបង្ខំដែរ ការលុបចោលនូវការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្នអាចធ្វើទៅបាន។[82] ធ្វើការបន្ថែមពីលើនេះ ការលុបចោល របៀបអនុវត្តមានប្រព័ន្ធនៃការលុបចោលការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដោយសារការដាក់ផ្ញើនូវប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន។ ទោះបីជាបណ្តឹងជំទាស់អាចប្រព្រឹត្តិទៅបានដីកាសម្រេចសេចក្តីនេះ ការលុបចោលការអនុវត្ត ត្រូវមានអនុភាពភ្លាមៗដោយមិនចាំបាច់ចាំរហូតដល់ពេលចូលជាស្ថាពរ។[83]

### ២.៧.៤. ការបំលែងពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ទៅជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

នៅក្រោយពេលដែលការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវបានធ្វើការអនុវត្តកាលណាបើគ្រប់លក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនោះត្រូវបានបំពេញ ហើយម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្ត នោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នឹងត្រូវបានបំលែងទៅជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុវិញនៅត្រឹមទំហំនៃការអនុវត្តនោះ។ ដូច្នេះ នីតិវិធីនេះអាចឈានបន្តទៅដំណាក់កាលនៃការប្តូរជាប្រាក់បាន ដោយមិនចាំបាច់ធ្វើនីតិវិធីដដែលសម្រាប់ការអនុវត្តដោយបង្ខំទេ។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយបើជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលតម្រូវឱ្យមានការចុះបញ្ជីអំពីការរឹបអូសដាច់ដោយឡែកអំពីការចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្ន នោះត្រូវមានដីការសម្រេចផ្តើមការលក់ដោយបង្ខំរបស់តុលាការដែលមានសមត្ថកិច្ច។ នៅក្នុងករណីដែលម្ចាស់បំណុល ធ្វើឱ្យមានការធ្វេប្រហែសមិនបានដាក់

[82] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/0៧០៦/0២១ .0៦.0៧.២00៧ មាត្រា ៣៦៧ កថាខណ្ឌទី២ និងមាត្រា ៣៧0 កថាខណ្ឌទី១
[83] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/0៧០៦/0២១ .0៦.0៧.២00៧ មាត្រា ៥៦៩ កថាខណ្ឌទី ២

ពាក្យសុំអនុវត្តដោយបង្ខំ ទោះបីជាគ្រប់លក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញហើយក៏ដោយនោះ កូនបំណុលអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយសារការផ្លាស់ប្តូរស្ថានភាពបាន ដោយសារការធ្វើសំអាងទៅលើការលក់នៃភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។[84]

[84] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥៨

# ជំពូកទី ៣

# ស្ថាប័នអនុវត្ត និងការ
# តវ៉ាចំពោះដីកាសម្រេច
# រឹបអូសជាបណ្ដោះអាសន្ន

# ជំពូកទី ៣

# ស្ថាប័នអនុវត្ត និងការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

## ៣.១. ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តដីកាសម្រេច

ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបចុះបញ្ជី អំពីការរឹបអូសជាបណ្ដោះអាសន្នតុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសម្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ។[85] មួយវិញទៀតតុលាការដែលត្រូវអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន រក្សាការពារត្រូវបានហៅថា តុលាការអនុវត្ត តុលការអនុវត្តចាត់ចែងរក្សាការពារ[86] ហើយអាចកំណត់បានទៅលើ លំនៅដ្ឋានរបស់កូនបំណុល ឬ កំណត់ទីកន្លែងដែលអចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តតាំងនៅ[87]។ សាលាជម្រះក្ដីដែលទទួលពាក្យបណ្ដឹងខុសសម្ថតកិច្ចរបស់ខ្លួនត្រូវតែប្រកាសថាខ្លួនគ្មានសមត្ថភាព ហើយប្រាប់គូភាគីអោយទៅរកសាលាជម្រះក្ដីដែលមានសមត្ថកិច្ចក្នុងកាអនុវត្ត។

### ៣.១.១. ស្ថាប័នអយ្យការ

ស្ថាប័នអយ្យការនូវក្នុងនេះ គឺសំដៅដល់ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង នៃសាលាដំបូង ត្រូវអនុវត្តកិច្ចការរបស់អាជ្ញាសាលា ក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅនៅក្រោម ក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្ដីពីអាជ្ញាសាលា។[88] ដោយសារតែនាពេលបច្ចុប្បន្ននេះ ស្ថានប័នអាជ្ញាសាលាមិនទាន់មានគ្រប់តាមបណ្ដាលខេត្តទាំងអស់ទេ ដូច្នេះហើយតាមស្ថាប័នតុលាការមួយចំនួន មានភាពខ្វះខាតនូវអាជ្ញាសាលា ក្នុងការអនុវត្តនូវកិច្ចការមួយចំនួន។ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចឱ្យអ្នកអនុវត្តកិច្ចការជំនួស អនុវត្តកិច្ចការជំនួសខ្លួន ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតក្រោម។[89]

### ៣.១.២. ស្ថាប័នអាជ្ញាសាលា

អាជ្ញាសាលា គឺជាស្ថាប័នដោយឡែកមួយដែលក្នុងការអនុវត្តដែលទទួលបន្ទុកក្នុងការអនុវត្តដោយបង្ខំដែលត្រូវធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការអនុវត្ត ដោយច្បាប់អនុញ្ញាតឱ្យតុលាការផ្ដល់ការ

[85] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៦៨ កថាខណ្ឌទី ២

[86] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣២ កថាខណ្ឌទី ៣

[87] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៨

[88] ប្រកាសស្ដីពី មន្ត្រីទទួលបន្ទុកិច្ចការងារអាជ្ញាសាលា ប្រកា ១ កថាខណ្ឌទី ១ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៧

[89] ប្រកាសស្ដីពី មន្ត្រីទទួលបន្ទុកិច្ចការងារអាជ្ញាសាលា ប្រកា ២ កថាខណ្ឌទី ១ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៧

[90] ណែនាំប្រគល់សិទ្ធិ និងបង្គាប់អាជ្ញាសាលានៅក្នុងករណីជាក់លាក់ដូចជា ( ការអនុវត្ត ឬថ្ងៃសម្រាក និងពេលយប់ ) ដោយអាជ្ញាសាលាត្រូវបង្ហាញលិខិតបញ្ជាក់ថា ខ្លួនបានទទួលការអនុញ្ញាតពីតុលាការអនុវត្តណាដែលខ្លួនស្ថិតនៅ ឬ តុលាការណាដែលចេញសេចក្តីបង្គាប់។[91]

## ៣.២. ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរក្សាការពារ ពុំអាចធ្វើការប្តឹងជំទាស់ភ្លាមបានទេ ប៉ុន្តែគេអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលចេញដីការសម្រេចនោះបាន។ [92] ការដាក់ពាក្យសុំតវ៉ាជាឱកាសឱ្យកូនបំណុលដែលពុំមានឱកាសក្នុងការចូលរួមក្នុងនីតិវិធីជាមុន ក្នុងការសុំឱ្យមានការវិនិច្ឆ័យរកភាពត្រឹមត្រូវ ឬ ក៏មិនត្រឹមត្រូវនៃដីការសម្រេចរឹបអូសជាបណ្តោះអាសន្នមិនមែនដោយតុលាការជាន់ខ្ពស់ទេ ផ្ទុយមកវិញដោយតុលាការថ្នាក់ដដែល។ ករណីដែលតុលាការនៃបណ្តឹងជំទាស់លុបចោល ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់នោះផងដែល។ ពាក្យសុំតវ៉ា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយពុំបានកំណត់អំពីអំឡុងពេលទេ ចំពោះពាក្យសុំតវ៉ានេះអាចដាក់នៅពេលណាក៏បាន ឱ្យតែដីការសម្រេចរឹបអូសជាបណ្តោះអាសន្ននោះនៅមានសុពលភាព។[93] ចំពោះការដាក់ពាក្យសុំតវ៉ា មិនបានធ្វើឱ្យអនុភាពអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ធ្វើការផ្អាកដោយស្វ័យប្រវត្តិនោះទេ គឺត្រូវការសេចក្តីសម្រេចបណ្តោះអាសន្នដោយឡែកដែលធ្វើការបង្គាប់ឱ្យផ្អាកការអនុវត្ត។

សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើឡើងបានតែនៅក្នុងករណីដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការនលុបចោលនៃដីការសម្រេចរក្សាការពារ និងអំពីការព្រួយបារម្ភថាការខូចខាតដែល នឹងមិនអាចសងបានកើតមានឡើងដោយសាការអនុវត្តការរក្សាការពារ នោះប៉ុណ្ណោះ ហើយមួយវិញទៀត ការដាក់ប្រាតិភោគមានអានុភាពជានិច្ច។[94] ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ សំដៅទៅលើស្ថានភាពដែលផ្ទុះយ៉ាងច្បាស់លាស់នឹងអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលវាជាលក្ខខណ្ឌចាំបាច់នៃការចេញដីកាបណ្តោះអាសន្ន។

[90] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ២៤៦ កថាខណ្ឌទី ៣

[91] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៤០

[92] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥០

[93] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៣៤

[94] ក្រមនិតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥១

ឧទាហរណ៍ ៖ មានភាពដែលមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតនៅក្នុងការទទួលស្គាល់ ឬ នៅក្នុងការបកស្រាយច្បាប់។ ដោយឡែកការបារម្ភថាការខូចខាត ដែលមិនអាចសងបាននឹងកើតមានឡើងដោយសារការអនុវត្តរក្សាការពារ សំដៅលើគោលបំណងឱ្យធ្វើការសងជាប្រាក់តាមក្រោយទំនងជានឹងមិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុលបានឡើយ។

ឧទាហរណ៍ ៖ ករណីដែលកូនបំណុលនឹងត្រូវបានក្ស័យធន ឬក៏មិនអាចរស់បាន ដោយមូលហេតុថាការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននូវប្រាក់បញ្ញើនៅធនាគាររបស់កូនបំណុល។

### ៣.២.១. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

នៅពេលដែលតុលាការបានចេញដីកាសម្រេចរក្សាការពារ តាមការស្នើសុំរបស់ម្ចាស់បំណុលហើយប្រសិនបើកូនបំណុលបានទទួលដំណឹងអំពីដីកាសម្រេចនេះ និងមានបំណងប្តឹងតវ៉ាចំពោះដីកាសម្រេចដើមនេះ កូនបំណុល គឺអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេច មកតុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះដដែលបាន មានន័យថា បើសិនជាតុលាការដែលមានសមត្ថកិច្ចបានចេញដីកាសម្រេចជាសាលាដំបូងរាជធានីភ្នំពេញ កូនបំណុលត្រូវដាក់ពាក្យតវ៉ាទៅសាលាដំបូង បើសិនជាសាលាឧទ្ធរណ៍វិញតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវដាក់ពាក្យសុំតវ៉ាត្រូវឧទ្ធរណ៍ដោយបញ្ជាក់អំពី ទី១. **គោលបំណងនៃការតវ៉ា** ទី២. **មូលហេតុនៃការតវ៉ា** ទី៣. **ភស្តុតាងគាំទ្រការតវ៉ា** ( ក្នុងករណីបើមាន ) ដើម្បីឱ្យតុលាការទទួលពាក្យសុំចេញដីកាសម្រេចជាថ្មីក្នុងការទទួលស្គាល់ ឬ ការលុបចោល ឬ ផ្លាស់ប្តូរដីកាសម្រេចដើម។

ទី១. គោលបំណងនៃការតវ៉ា ៖ សម្រាប់កូនបំណុលនៅពេលដាក់ពាក្យតវ៉ា ត្រូវបញ្ជាក់អំពីការទាមទាររបស់ខ្លួនឱ្យបានច្បាស់លាស់ ជាទូទៅ ការទាមទាររបស់កូនបំណុល គឺអាចស្នើសុំលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចដើម។

ទី២. មូលហេតុនៃការតវ៉ា ៖ នៅពេលកូនបំណុលដាក់ពាក្យតវ៉ា ដោយទាមទារឱ្យលុបចោលដីកាសម្រេចដើម មូលហេតុតាមផ្លូវច្បាប់គឺ នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ឬ គ្មានភាពចាំបាច់នៃការរក្សាការពារ ឬ មានអង្គហេតុតវ៉ាដើម្បីរលត់សិទ្ធិដែលត្រូវរក្សាការពារ។ មួយវិញទៀត បើការតវ៉ារបស់កូនបំណុល ក្នុងគោលបំណងផ្លាស់ប្តូរសេចក្តីសម្រេចដើម អាចថាកម្មវត្ថុនៃការរក្សាការពារ ឬ ស្នើឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ដើម្បីធានាដល់សិទ្ធិរបស់កូនបំណុល នៅពេលម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តី។

ទី៣. ភស្តុតាងគាំទ្រការតវ៉ា ៖ នៅពេលកូនបំណុលដាក់ពាក្យសុំតវ៉ា ដោយមានគោលបំណងលុបចោលដីកាសម្រេចដើម ដោយអះអាងអំពីអង្គហេតុតវ៉ាស្តីពីកាសង ឬ ការលើលែងបំណុល ជាអាទិ៍។ ចំណុចនេះខុសគ្នានៅដំណាក់កាលចេញដីការក្សាការពារ និងអំពីដំណាក់កាលចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះ

ដីកាសម្រេចរក្សាការពារ មានន័យថា ដីកាសម្រេចរក្សាការពារតម្រូវឱ្យម្ចាស់បំណុលធ្វើសេចក្តីបញ្ជាក់ដំបូងចំពោះអង្គហេតុដែលម្ចាស់បំណុលបានអះអាង ប៉ុន្តែដំណាក់កាលតវ៉ាចំពោះដីការរក្សាការពារ គឺកូនបំណុលអាចដាក់ភស្តុតាងគាំទ្រ ដោយមិនតម្រូវទាល់តែដោយសេចក្តីបបញ្ជាក់ដំបូងនោះទេ ទោះបីភស្តុតាងនោះជាការសាក់សួរសាក្សីក៏ ឬ ការសាក់សួរសមីភាគី ឬ លទ្ធផលកោសលវិច័យ ក៏អាចប្រើប្រាស់បានសម្រាប់បញ្ជាក់អង្គេតុរបស់កូនបំណុល (មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ចំពោះម្ចាស់បំណុលប៉ុណ្ណោះ គឺមិនអនុវត្តចំពោះកូនបំណុលឡើយ។

លើសពីនេះទៅទៀត នៅក្នុងមាត្រា ៥៥០ នៃក្រមនីតិវិធី ស្តីពីការតវ៉ារបស់កូនបំណុល និងបញ្ញត្តិពាក់ព័ន្ធនឹកការតវ៉ាមិនបានកម្រិតនូវការបញ្ជាក់របស់កូនបំណុលនោះទេ បើគ្មានការកំណត់បែបនេះនាំឱ្យវិធានភស្តុតាងជាទូទៅ អាចត្រូវបានយកមកអនុវត្តផ្អែកតាមមាត្រា ៥៣៩ និងមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ៣.២.២. ការវិនិច្ឆ័យអំពីពាក្យសុំតវ៉ាដីកាសម្រេចរឹបអូស

ក្នុងការវិនិច្ឆ័យនៅក្នុងការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយសារតុលាការមិនអាចចេញ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ ឬការសួរកាលបរិច្ឆេទដែលអាចចូលរួមបានរបស់ភាគីទាំងសងខាង។[95] ប៉ុន្តែការអនុវត្តច្បាប់នៅប្រទេសជប៉ុន តុលាការមិនធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ ពីព្រោះនីតិវិធីនេះត្រូវចំណាយពេលវេលា និងថវិកាច្រើន ( កំណត់អំឡុងពេលសមរម្យដើម្បីកោះហៅភាគី ធ្វើនៅបន្ទប់សវនាការជាសាធារណៈត្រូវដេញដោលជាអាទិ៍ ) ភាគច្រើន តុលាការនឹងធ្វើនីតិវិធីនៃការសួរ ព្រោះចំណាយពេលវេលា និងថវិកាតិច។ ដោយឡែកការអនុវត្តនៅកម្ពុជា ភាគច្រើនតុលាការជ្រើសរើសការទាញហេតុផលដោយផ្ទាល់មាត់។

គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ទៅឱ្យភាគី ជាពិសេសកូនបំណុលនូវការធានានៅក្នុងការចូលរួមនីតិវិធី។ ប៉ុន្តែយ៉ាងណាក៏ដោយ វាមិនចាំបាច់ទាល់តែថានៅក្នុងកាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាឱ្យមាននូវកាលបរិច្ឆេទដែលគូភាគី អាចចូលរួមបានតែម្តងក៏ជាការគ្រប់គ្រាន់ដែល។ ដើម្បីបញ្ជាក់ការវិនិច្ឆ័យអំពីការតវ៉ាជាគោលកាណ៍ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ។[96] ទោះបីជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចតុលាការ អាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ក៏នៅក្នុងនីតិវិធីអំពីការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅដល់គូភាគីអំពីកាលបរិច្ឆេទនៃការ

[95] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥២

[96] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥៣ វាក្យខណ្ឌទី ១

បញ្ចប់ការវិនិច្ឆ័យ ដើម្បីផ្តល់ឱកាសឱ្យគូភាគី ក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យទៅតុលាការឱ្យបានគ្រប់គ្រាន់។ ក៏ប៉ុន្តែបើការ វិនិច្ឆ័យត្រូវបានបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យបាន [97] ពីព្រោះថាការធានានៅក្នុងនិតិវិធីត្រូវបានផ្តល់ឱ្យបានគ្រប់គ្រាន់ហើយ គឺដូចគ្នាទៅនឹងនីតិវិធីនៃបណ្តឹងដែល។

### ៣.២.៣. ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូស

នៅក្នុងខ្លឹមសារសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចបញ្ចប់នៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារតុលាការត្រូវទទួលស្គាល់សេចក្តីសម្រេចដើម ប្រសិនបើការណាតុលាការយលឃើញថាដីការសម្រេចដើមមានភាពត្រឹមត្រូវ ប៉ុន្តែផ្ទុយទៅវិញ កាលណាបើតុលាការយលឃើញថាដីការសម្រេចដើមមានភាពមិនត្រឹមត្រូវ នោះតុលាការត្រូវលុបចោលដីកាសម្រេច ដើមដែលខ្លួនបានចេញតាមការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនោះវិញ។ ហើយនៅពេលដែលសេចក្តីសម្រេចដើមមានចំណុចដែលត្រូវផ្លាស់ប្តូរ ឬ ធ្វើការកែសម្រួល ដោយសារតែមានមូលហេតុស្រប់ច្បាប់បានបង្ហាញពីកូនបំណុលដូចជា ការត្រូវឱ្យម្ចាស់បំណុលធ្វើការដាក់បន្ថែមនូវចំនួនប្រាតិភោគ នៅក្នុងអំឡុងពេលណាមួយ ឬសភាពដើមកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមានតម្លៃធំជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ដែលតុលាការទទួលស្គាល់ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យសុំរក្សាការពារជាអាទិ៍ នោះតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ ឬ ធ្វើការកែសម្រួលដីកាសម្រេចដើម។

ករណីទី១ ៖ នៅពេលម្ចាស់បំណុលលើកូនបំណុល គិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ដោយការអនុវត្តតុលាការបានចេញដីការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដីចំនួនពីកន្លែងដែលដែលជាកម្មសិទ្ធិរបស់កូនបំណុល ដែលមួយកន្លែងមានតម្លៃ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងមួយកន្លែងទៀតមានតន្លៃ ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ហើយកូនបំណុលបានធ្វើការដាក់ពាក្យសុំតវ៉ាចំពោះដីការសម្រេចរឹបអូសរបស់តុលាការ ដែលនៅក្នុងគោលបំណងចងឱ្យតុលាការលុបចោលនូវការរឹបអូសលើដីទី ពីរ ដោយសារតែដីនៅទីកន្លែងទី១ មានតម្លៃគ្រប់គ្រានជាមួយនឹងសិទ្ធិលើបំណុលរប់សម្ចាស់បំណុលមកលើខ្លួន នោះខ្លឹមសារនៃដីការរបស់តុលាការ គឺជាការផ្លស់ប្តូរ។

ករណីទី២ ៖ នៅពេលដែលតុលាការចេញដីកាសម្រេចរក្សាការពារ បានបង្គាប់ឱ្យម្ចាស់បំណុលនៃការរឹបអូសដាក់ប្រាតិភោគជាប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែកូនបំណុលបានដាក់ពាក្យសុំតវ៉ាដោយមានគោលបំណង ស្នើសុំឱ្យតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ចំនួនប្រាតិភោគបន្ថែម ដែលកូនបំណុលបាន

[97] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥៣ វាក្យខណ្ឌទី ៣

ភ្ជាប់មកជាមួយនូវមូលហេតុស្របច្បាប់ និងភស្តុតាងគាំទ្រ នៅក្នុងករណីតុលាការបានទទួលស្គាល់នូវពាក្យសុំតវ៉ា របស់កូនបំណុលនៃការរឹបអូស ក៏ជាការផ្លាស់ប្តូរ ឬ កែប្រែដីការសម្រេចដើមដូចគ្នាផងដែល។

ដោយឡែក ទោះបីជាតុលាការធ្វើការទទួលស្គាល់ពាក្យសុំតវ៉ា របស់ម្ចាស់បំណុលក៏ដោយ ប៉ុន្តែដីកាសម្រេចថ្មី ឬ ផ្លាស់ប្តូរដីកាសម្រេចដើម ក៏ដោយក៏ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារនេះ មិនមានអនុភាពអនុវត្តភ្លាមនោះទេ បើមិនទាន់ចូលជាស្ថាពរ លើកលែងតែតុលាការយល់ឃើញថាមានភាពចាំបាច់ពិសេស ទើបដីកាសម្រេចនោះមានអនុភាពសម្រេចភ្លាមៗ។[98] ភាពចាំបាច់នៅក្នុងក្រមនិតិវិធីរដ្ឋប្បវេណីធ្វើការសំដៅទៅលើស្ថានភាពមួយ ដែលតុលាការយល់ឃើញថា មានភាពចាំបាច់ត្រូវការពារផលប្រយោជន៍កូនបំណុល ក្រោយពីបានចេញដីកាសម្រេចលុបចោលដីកាសម្រេចដើមជាអាទិ៍ ដោយយលថាបើដីការសម្រេចដើមមិនបាត់បង់អនុភាពភ្លាមៗនោះទេ ផលប្រយោជន៍របស់កូនបំណុលដែលនឹងបាត់បង់នឹងមិនអាចធ្វើបដិទានបាន ដូចជាករណីកូនបំណុលអាចនឹងក្ស័យធន ដោយសារខ្លឹមសារនៃដីការសម្រេចដើម ( ធ្វើការហាមឃាត់មិនឱ្យកូនបំណុលធ្វើការសាងសង់សំណង់នៅលើដី L ) បើបន្តអនុភាពមិនឱ្យសាងសង់ទៀតនោះ កូនបំណុលអាចធ្វើការបង្ហាញជូនតុលាការថា នឹងនាំឱ្យខ្លួនមិនអាចប្រគលអាគារជូនអតិថិជនឱ្យទាន់ពេលវេលា ហើយត្រូវសងសំណងជាច្រើនដល់អតិថិជននាំឱ្យខ្លួនក្ស័យធន ។

សេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូស ៖

១. ក្នុងករណីសាលាដំបូងបានចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូស តាមការស្នើសុំរបស់ម្ចាស់បំណុល ហើយកូនបំណុលបានដក់ពាក្យសុំតវ៉ា ប៉ុន្តែតុលាការយល់ថាសេចក្តីសម្រេចដើមត្រឹមត្រូវ នោះដីការសម្រេចមានខ្លឹមសារថា ៖

- ទទួលស្គាលដីការសម្រេចរឹបអូសជាបណ្តោះអាសន្ន
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

២. ក្នុងករណីសាលាដំបូងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមការស្នើសុំរបស់ម្ចាស់បំណុល ហើយកូនបំណុលបានដាក់ពាក្យសុំតវ៉ា ប៉ុន្តែតុលាការយលឃើញថាសេចក្តីដើមមិនត្រឹមត្រូវ នោះខ្លឹមសារនៃដីកាសម្រេចថា ៖

- លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ម្ចាស់បំណុល
- ដីការសម្រេចនេះមានអនុភាពអនុវត្តភ្លាម។

[98] ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ .០៦.០៧.២០០៧ មាត្រា ៥៥៦

៣. នៅក្នុងករណីសាលាដំបូងបានចេញដីការសម្រេចរឹបអូសជាបណ្ដោះអាសន្ន តាមការស្នើសុំរបស់ម្ចាស់បំណុល ហើយកូនបំណុលបានធ្វើការដាក់ពាក្យសុំតវ៉ា ប៉ុន្តែតុលាការមានការយល់ឃើញថាសេចក្ដីសម្រេចដើម គម្បីធ្វើការផ្លាស់ប្ដូរនឹងមានខ្លឹមសារថា៖

- ទទួលស្គាលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន
- បង្គាប់ឱ្យម្ចាស់បំណុលផ្ញើប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកជាប្រាក់ប្រាតិភោគបន្ថែមសម្រាប់កូនបំណុល មកតុលាការ ឱ្យបានមុនថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១
- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

### ៣.២.៤. ការអនុវត្តដីការសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីការសម្រេចរឹបអូស

នៅក្នុងករណី A ជាម្ចាស់បំណុល B ជាកូនបំណុល កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាដី L សាលាដំបូងចេញ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមការស្នើសុំរបស់ A និងបានធ្វើលិខិតចុះបញ្ជីផ្ទុកផ្ដាក់អំពីការរឹបអូសជាបណ្ដោះអាសន្នទៅសុរិយោដី ហើយរដ្ឋបាលសុរិយោដីបានចុះបន្ទុក និងផ្ញើត្រលប់មកតុលាការរួចរាល់ B ដែលជាកូនបំណុលដាក់ពាក្យសុំតវ៉ា សាលាដំបូងបានចេញសេចក្ដីសម្រេចទទួលស្គាល់ដីការសម្រេចរបស់ B ដូច្នេះដើម្បីធ្វើការលុបបន្ទុកនៅលើដីដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន កូនបំណុល B ត្រូវដាក់ពាក្យសុំតវ៉ាដែលមានគោលបំណង ស្នើសុំឱ្យតុលាការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ទៅតុលារការរក្សាការពារ ( មាត្រា ៥៦៤ និងមាត្រា ៣៧០ កថាខណ្ឌទី១ និងចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ។ ដោយផ្អែកតាមពាក្យសុំនេះ តុលាការអនុវត្តរក្សាការពារនឹងចេញ ( ដីកាលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ) ផ្អែកតាមមាត្រា ៥៦៤ មាត្រា ៣៣៧ កថាខណ្ឌទី១ មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច «ក» នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រការ ១៧ កថាខណ្ឌទី៣ នៃប្រកាសអន្តរក្រសួងលេខ៥៩ ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១។ បន្ទាប់ពីតុលាការអនុវត្តរក្សាការពារបានចេញដីកាសម្រេចនេះតុលាការ នឹងឱ្យក្រឡាបញ្ជីធ្វើលិខិតផ្ទុកផ្ដាក់លុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នទៅសុរិយោដី។

បន្ទាប់ពីរដ្ឋបាលសុរិយោដី បានទទួលលិខិតផ្ទុកផ្ដាក់អំពីការលុបចោលនេះ រដ្ឋបាលសុរិយោដីត្រូវសរសេរក្នុងសៀវភៅគោលបញ្ជីដីធ្លី ត្រង់ខ្ទង់ «បន្ទុកលើអចលនវត្ថុ» ដែលមានខ្លឹមសារថា «ត្រូវបានលុបចោលការឹបអូសជាបណ្ដោះអាសន្ន ដែលតុលាការចេញដីការសម្រេចលេខ...........ចុះថ្ងៃទី..........ខែ..........ឆ្នាំ......... តាមដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នលេខ...........ចុះថ្ងៃទី........ខែ......ឆ្នាំ.........

របស់តុលាការរួចបោះត្រា និងចុះហត្ថលេខាកាលបរិច្ឆេទនៃការចុះបញ្ជី បន្ទាប់ពីបំពេញកិច្ចនេះរួចត្រូវផ្ញើត្រលប់មកតុលាការវិញ។[99]

[99] ប្រការ ៣៨ នៃប្រកាសអន្តរក្រសួងលេខ៥៩ ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនិងនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១១

# អនុសាសន៍

នីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺមានភាពលំបាកខ្លាំងនៅក្នុងការស្វែងរកទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តរបស់កូនបំណុល ដែលម្ចាស់បំណុលយល់ឃើញថាអាចធ្វើការធានាដល់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ដែលក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញអំពីការកំណត់ប្រភេទនៃកម្មវត្ថុទីកន្លែងនៃកម្មវត្ថុជាដើម។ ម្ចាស់បំណុលគួរតែប្រញ៉ាប់ប្រញាលនៅក្នុងការដាក់ពាក្យសុំទៅតុលាការ នៅក្នុងករណីដែលខ្លួនបានដឹងថាកូនបំណុលមានចេតនាមិនអនុវត្តកាតព្វកិច្ច ឬក្នុងករណីដែលខ្លួនមានការបារម្ភថាការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលមិនអាចធ្វើទៅបាន ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងបញ្ចៀសពីហានិភ័យដែលកើតឡើង ដោយសាការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលចំពោះម្ចាស់បំណុល។

តុលាការគម្បីធ្វើការយកចិត្តទុកដាក់ នៅក្នុងការបញ្ជូនដីការសម្រេចរឹបអូសនេះទៅឱ្យភាគីដើម្បីឱ្យអ្នកដែលត្រូវទទួលការបញ្ជូនដីកាសម្រេចនោះ អាចរកមធ្យោបាយការពារខ្លួនតាមផ្លូវច្បាប់ និងដាក់ភស្តុតាងដើម្បីការពារផលប្រយោជន៍របស់ខ្លួនតាមរយៈការបង្ហាញពីឆន្ទៈ អំពីកាអនុវត្តកាតព្វកិច្ចរបស់ខ្លួនជូនចំពោះម្ចាស់បំណុលតាមផ្លូវតុលាការ។ រីឯចៅក្រមដែលជាអ្នកសម្រេចសេចក្តី មិនត្រូវសម្រេចសេចក្ដីដោយអគតិទាំងបួនឡើយ គឺ ទោសោគតិ មោហោគតិ ឆន្ទាគតិ និងភ័យោគតិ។ ដែលត្រូវសម្រេចសេចក្តីដោយពិនិត្យមើលលក្ខខណ្ឌចាំបាច់សម្រាប់ការរឹបអូសផ្សេងៗដើម្បីចេញដីកាសម្រេច។

ជាក់ស្ដែង នូវមាតិរបស់ប្រជាពលរដ្ឋមួយក្នុងសង្គម យើងខ្ញុំសង្កេតឃើញថាមានសាធារណៈជនមួយចំនួនយល់ថាការអនុវត្តច្បាប់ គឺមិនមានកំហុសឆ្គងអ្វីឡើយ ចំណែកប្រជាពលរដ្ឋមួយចំនួនទៀតយល់ឃើញថាការអនុវត្តច្បាប់នៅមានកម្រិត និងប្រជាពលរដ្ឋមួយជ្រុងតូចមតិថាការអនុវត្តមិនទាន់បានពេញលេញនៅឡើយទេចំពោះរូបគាត់ ក៍ដូចជាសង្គមជាតិទាំងមូល។ ដូច្នេះយើងខ្ញុំចង់បន្ថែមមតិយោបល់ក្នុងការអភិវឌ្ឍន៍ និងបំពេញបន្ថែមនូវចំណុចខ្វះខាតចំនួនផងដែលដើម្បីអភិវឌ្ឍន៍សង្គមមានដូចជា៖

- ពង្រឹងទៅលើវិស័យយុត្តិធម៌
- ពង្រឹងវិស័យអប់រំ
- ធ្វើការផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ
- បើកវគ្គបណ្តុះបណ្តាល
- កែតម្រូវនូវច្បាប់ឱ្យមានប្រសិទ្ធភាពជាមុន។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវនៅលើប្រធានបទ "នីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ" រួចកន្លងមក យើងខ្ញុំសន្និដ្ឋានបានថា នីតិវិធីរឹបអូសជាបណ្ដោះចំពោះអចលនវត្ថុ គឺជានិតិវិធីមួយដែលមានលក្ខណៈជាបណ្ដោះអាសន្ន និងធ្វើការរំលត់នូវការភ័យខ្លាចរបស់ម្ចាស់បំណុល ទៅលើការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល និងធ្វើការធានាដល់អនុវត្តកាតព្វកិច្ចរបស់កូនបំណុលនៅពេលបច្ចុប្បន្ន និងនាពេលអនាគត និងនៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំមិនអាចអនុវត្តទៅបាន ដោយសារតែការប្រែប្រួលនៅរូបរាងដើមទ្រព្យសម្បត្តិដែលជាកម្មវត្ថុ នៃការអនុវត្តកាតព្វកិច្ចចំពោះសិទ្ធិលើបំណុលរបស់កូនបំណុល។ យើងអាចនិយាយម្យាងទៀតបានថា ដើម្បីធ្វើការហាមឃាត់មិនឱ្យកូនបំណុលធ្វើការផ្ទេរកម្មសិទ្ធិបាន ដែលធ្វើការធានាដល់សិទ្ធិទាមទាររបស់ម្ចាស់បំណុលដែលមានគោលបំណងឱ្យសងជាប្រាក់អាចប្រព្រឹត្តិទៅបាន។ ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ បើយើងសង្កេតមើលទៅលើវា ហាក់បីដូចជាសកម្មភាពការការពារសិទ្ធិរបស់ម្ចាស់បមណុលទាំងស្រុងនៅក្នុងការទាមទារ ប្រសិនបើយើងមើលមួយផ្នែកទៀតការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺគ្រាន់តែជាការកម្រិតនូវសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីមិនឱ្យរួចផុតពីការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប្រសិនបើយើងក្រឡេកមើលមួយជ្រុងទៀតនោះយើងនឹងឃើញថា ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា យើងក៏បានកំណត់អំពីវិធីមួយចំនួនដែលបញ្ចៀសផលប្រយោជន៍របស់កូនបំណុលដូចគ្នា ពីការអនុវត្តនីតិវិធី ឬភាពភ័យខ្លាចជ្រុលរបស់ម្ចាស់បំណុលដែលអាចខ្លាយជាផលប៉ះពាល់ ឬការខូចខាតប្រយោជន៍របស់កូនបំណុលដែលវិធីទាំងនេះមានដូចជា ការបង្គាប់ឱ្យដាក់ប្រាតិភោគពីតុលាការ ការដាក់ប្រាក់រំដោះរបស់កូនបំណុល ដែលវិធីទាំងនេះអាចនាំឱ្យកូនបំណុលអាចទទួលបានការការពារពីច្បាប់ ឬទទួលបាននូវសំណងការខូចខាតដែលបណ្ដាលមកពីម្ចាស់បំណុល នៃការអនុវត្តក្នុងករណីដែលតុលាការរកឃើញថាការអនុវត្តនីតិវិធីរបស់ម្ចាស់បំណុលមានភាពមិនប្រក្រតីដែលផ្ទុយនឹងច្បាប់។

ចំណុចទាំងពីនេះហើយធ្វើឱ្យយើងឃើញថា នីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុមានលក្ខណៈទៅវិញទៅមក ដែលអាចជាការការពារផល់ប្រយោជន៍របស់ម្ចាស់បំណុលទៅលើកូនបំណុល និងអាចជាផល់ប្រយោជន៍ដែលបានបានមកពីការដាក់ប្រាតិភោគរបស់ម្ចាស់បំណុលដោយតុលាការង្គាប់។ ចំណែកឯស្ថាប័នអនុវត្តទៀតសោតត្រូវមានលក្ខណៈពិប្រាកដ និងច្បាស់លាស់ទៅតាមទីកន្លែងអចលនវត្ថុដែលជាកម្មវត្ថុដែលអ្នកដាក់ពាក្យសុំតាំងនៅ ស្ថាប័នអនុវត្តគឺមិនត្រូវរំលោភបំពានសមត្ថកិច្ចទៅលើគ្នាឡើយដែលស្ថាប័នអនុវត្តនេះហើយជាអ្នកចេញនូវសេចក្ដីសម្រេចថាត្រូវរឹបអូស ឬធ្វើការលើកចោលពាក្យសុំ ដែលទាក់ទង់និងផល់ប្រយោជន៍របស់គូភាគីទាំងពីរ។

រីឯការបញ្ជូនក៏ជាចំណុចសំខាន់ផងដែល ចំពោះការអនុវត្តនីតិវិធីអនុវត្តជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដោយសារសេចក្ដីសម្រេចផ្សេងៗរបស់តុលាការ ស្ដីពីការអនុវត្តអាចមានសពោលភាពគិតចាប់ពីពេលដែលគូភាគីទទួលបានឯកសារ ឬ សេចក្ដីសម្រេចផ្សេងៗពីតុលាការ ការបញ្ជូនមានលក្ខណៈច្បាស់លាស់ ដោយមានការកត់ត្រាទុកនៅក្នុងរបាយការណ៍នៃការបញ្ជូនយ៉ាងច្បាស់លាស់ ហើយក៏អាចធ្វើជាភស្តុតាងនៃការវាស់ស្ទង់បានថា ការធ្វើនិតិវិធីរបស់តុលាការស្របទៅតាមបញ្ញត្តិច្បាប់ និងមិនមានភាពភាន់ច្រលំដែលចជាហេតុនាំឱ្យបាត់បង់ផលប្រយោជន៍របស់ភាគីណាមួយឡើយ។ ការបញ្ជូនមានច្រើនទម្រង់ដូចជា ការបញ្ជូនដោយប្រគល ការបញ្ជូនដោយជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច ការបញ្ជូនដោយទុកចោល ការបញ្ជូនដោយការផ្សាយជាសាធារណៈ និងការបញ្ជូនទៅក្រៅប្រទេសផងដែល។

# គន្ថនិទ្ទេស

- ❖ ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦
- ❖ សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគៈ ការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៨
- ❖ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ❖ ឯកសារវគ្គបណ្តុះបណ្តាលវគ្គខ្លី ស្តីពី « ការចាត់ចែងរក្សាការពារ » ដោយវាគ្មិនៈ លោកមេធាវី អ៊ីវ ប៉ូលី និងលោកស្រីមេធាវី ទេព បូផល ឆ្នាំ២០២២ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២
- ❖ សន្ទានុក្រមពាក្យច្បាប់ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
- ❖ ប្រកាសអន្តរក្រសួងលេខ៥៩ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទង់និងនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១
- ❖ ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២
- ❖ ប្រកាសស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការងារអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧
- ❖ មេរៀនស្តីពី « ការរឹបអូសជាបណ្តោះអាសន្ន » រៀបចំឡើងដោយក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចុះនៅខែមិនា ឆ្នាំ២០០៩

# ឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី១** | ក្រមនីតិវិធីរដ្ឋប្បវេណីគន្លីទី៧ ស្តីការចាត់ចែងរក្សាការពារ ប្រកាស់ឱ្យប្រើ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ |
| **ឧបសម្ព័ន្ធទី២** | ប្រកាសអន្តរអន្តរក្រសួងស្តីពី ការមិនទាន់ចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០១៣ |
| **ឧបសម្ព័ន្ធទី៣** | ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ |
| **ឧបសម្ព័ន្ធទី៤** | ប្រកាសអន្តរអន្តរក្រសួងស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១៣ |
| **ឧបសម្ព័ន្ធទី៥** | លិខិតផ្ទុកផ្តាក់ |
| **ឧបសម្ព័ន្ធទី៦** | ឯកសារចម្លងនៃសេចក្តីបញ្ជាក់ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី៧** | ប្រកាសស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការងារអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ |
| **ឧបសម្ព័ន្ធទី៨** | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន |

# ឧបសម្ព័ន្ធទី១

# ក្រមនីតិវិធីរដ្ឋប្បវេណី

# គន្ថីទី៧

# ស្តីការចាត់ចែងក្រោការពារ

# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.-** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៥៣១.-** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្តោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

**មាត្រា ៥៣២.–** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១-ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៣.–** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ៥៣៤.–** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ៖

ក-ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្ដឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៥.–** ការសម្រេចសេចក្តីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និង នីតិវិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៦.–** ការផ្តល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៧.–** សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលាការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្តឹងជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

**មាត្រា ៥៣៨.–** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

**មាត្រា ៥៣៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

## ជំពូកទី ២

## ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.–** តុលាការដែលមានសមត្ថកិច្ច

១-រឿងក្ដីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចបានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៥៤២.-** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.-** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.-** បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១-ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

**មាត្រា ៥៤៥.-** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.-** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

**មាត្រា ៥៤៧.–** ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះ-អាសន្ន ។

២-ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

## ផ្នែកទី ៣
## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

**មាត្រា ៥៤៨.–** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

**មាត្រា ៥៤៩.–** វិធីចាត់ចែងជាបណ្តោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្តល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

## ផ្នែកទី ៤
## ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.–** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥១.–** ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥២.-** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

**មាត្រា ៥៥៣.-** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

**មាត្រា ៥៥៤.-** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

**មាត្រា ៥៥៥.-** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់

# ឧបសម្ព័ន្ធទី២

# ប្រកាសអន្តរក្រសួងស្តីពី ការចុះបញ្ជីអចលនវត្ថុ ទាក់ទងនឹងក្រមនីតិវិធី រដ្ឋប្បវេណី

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** **ក្រសួងយុត្តិធម៌**

លេខ:..២១៤.....ប្រក.ដនស

# ប្រកាសអន្តរក្រសួង

## ស្តីពី

## នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូស ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដនស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី
- តាមការចាំបាច់ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១._ គោលបំណង

ប្រកាសនេះ មានគោលបំណងធានានូវប្រសិទ្ធភាពនៃការចុះបញ្ជី ទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត ។

### ប្រការ ២._ គោលដៅ

ប្រកាសនេះ មានគោលដៅបញ្ញត្តអំពីនីតិវិធីនៃការចុះបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីរបស់តុលាការដែលបានផ្ញើមកស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ។

### ប្រការ ៣._ វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដូចខាងក្រោម ៖

ក. ដីដែលមិនទាន់បានចុះបញ្ជី។

ខ. ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។

### ប្រការ ៤._ និយមន័យ

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

១. អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដី និងចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី ។

២. ដីដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដីដែលមិនទាន់បានចុះក្នុងសៀវភៅចុះបញ្ជី ហើយដែលតុលាការបានសន្មតថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬភោគីនៃដីនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី ៣ និងមាត្រា ៥៤១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣. ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលតុលាការបានសន្មតថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី៣ និងមាត្រា៥៤១ កថាខណ្ឌ ទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. នីតិវិធីចុះបញ្ជីដីលើកដំបូង គឺសំដៅលើនីតិវិធីចុះបញ្ជីដីដែលមិនទាន់បានចុះបញ្ជីទៅក្នុងសៀវភៅចុះបញ្ជី ។

៥. នីតិវិធីចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង គឺសំដៅលើនីតិវិធីចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជីទៅក្នុងសៀវភៅចុះបញ្ជី។

៦. លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី គឺសំដៅលើលិខិតរបស់តុលាការដែលបានផ្ញើមករដ្ឋបាលសុរិយោដី ដើម្បីស្នើសុំធ្វើនីតិវិធីចុះបញ្ជី។

## ជំពូកទី ២
## យន្តការ និងនីតិវិធីនៃការចុះបញ្ជី

### ប្រការ ៥._ ស្ថាប័នមានសមត្ថកិច្ច

១. ស្ថាប័នមានសមត្ថកិច្ចទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ ។

នៅពេលរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ត្រូវចុះលេខនៃការទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីក្នុងសៀវភៅទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដែលបានបង្កើតឡើងដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត តាមប្រការ ៥ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

ប្រសិនបើរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនោះ ត្រូវផ្ញើច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅដោយគ្មានការយឺតយ៉ាវ ។

នៅពេលរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តនោះ ត្រូវផ្ញើច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត រួមទាំងលិខិតអនុញ្ញាតឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូង ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅដើម្បីអនុវត្តនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ។

២. ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ។

៣. ចំពោះលំដាប់នៃការចុះបញ្ជី ត្រូវអនុលោមតាមប្រការ ៧ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

## ប្រការ ៦._ លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

នៅពេលចេញដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូង និង/ឬចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង និងចុះបញ្ជីអំពីការរឹបអូស ឬរឹបអូសជាបណ្តោះអាសន្ន ឬចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងតាមទម្រង់និងខ្លឹមសារដូចខាងក្រោម ៖

ក. កម្មវត្ថុ: ១. ចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូងនិង/ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ។

២. សរសេរអំពីខ្លឹមសារនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬការរឹបអូស ។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ: ទីតាំងដី ទំហំដី លេខក្បាលដីនៃទីតាំងអគារសហកម្មសិទ្ធិ ឈ្មោះអគារសហកម្មសិទ្ធិ និងលេខប័ណ្ណ ។

គ. កម្មសិទ្ធិករ ឬភោគីនៃដីដែលត្រូវបានសន្មត : ឈ្មោះ និងអាសយដ្ឋាន ។ ចំពោះអគារសហកម្មសិទ្ធិ ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវបានសន្មតជាកម្មសិទ្ធិករ ឬអ្នកជួលអចិន្ត្រៃយ៍ ។

ឃ. គោលបំណងនៃការចុះបញ្ជី : ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬការរឹបអូសកម្មសិទ្ធិ សិទ្ធិភោគៈ ឬសិទ្ធិជួលអចិន្ត្រៃយ៍ (ចំពោះតែចំណែកឯកជននៃអគារសហកម្មសិទ្ធិ) ។

ង. មូលហេតុ : ដីកាសម្រេចឱ្យរឹបអូសជាបណ្តោះអាសន្ន ដីកាសម្រេចអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ....ចុះថ្ងៃទី ខែ ឆ្នាំ ។

ច. - ចំពោះការរក្សាការពារ សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល

- ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត

ឆ. - ចំពោះការរក្សាការពារ សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល

- ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត

ឯកសារភ្ជាប់ មានដូចខាងក្រោម ៖

- ចំពោះការរក្សាការពារ :
    - ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
    - ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែង
    - ឯកសារនៃសេចក្តីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដែលមានចែងនៅក្នុងមាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
- ចំពោះការរឹបអូស :
    - ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ
    - ឯកសារបញ្ជាក់អំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការរឹបអូសអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដូចមានចែងក្នុងមាត្រា ៤១៧ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ប្រការ ៧._ ការចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូង

១. នៅពេលដែលបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំចំពោះដីដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមធ្វើនីតិវិធីនៃការចុះបញ្ជីដីលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីដីលើកដំបូងដែលនៅជាធរមាន ។

២. នៅពេលដែលបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំចំពោះចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមធ្វើនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូងដែលនៅជាធរមាន ។

៣. នៅពេលធ្វើការចុះបញ្ជីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះ បញ្ញត្តិនៃប្រការ ៨០ និងប្រការ ៨១ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ប្រការ ៨._ ការចុះបញ្ជីអំពីការចាត់ចែងរក្សាការពារនិងការរឹបអូសតាមលិខិតផ្ទុកផ្តាក់

១. នៅពេលដែលការចុះបញ្ជីដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិដោយអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវបានបញ្ចប់ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅត្រូវសរសេរនៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" អំពីការចុះបញ្ជីនោះ យោងតាមលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី និងតាមប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីដោយគ្មានការយឺតយ៉ាវ ។

២. នៅពេលធ្វើការចុះបញ្ជីដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃប្រការនេះ បញ្ញត្តិនៃប្រការ៨៣ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ប្រការ ៩._ ភាតព្វកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្តជាអាទិ៍

ម្ចាស់បំណុល ឬម្ចាស់បំណុលនៃការអនុវត្តដែលមានក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី មានកាតព្វកិច្ចបង់ជាមុននូវការចំណាយក្នុងការចុះបញ្ជីដីលើកដំបូង និងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ផ្អែកតាមមាត្រា ៣៧៤ និងមាត្រា ៥៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ប្រការ ១០._ ការលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

រដ្ឋបាលសុរិយោដីដែលបានចាប់ផ្តើមនីតិវិធីដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ អាចលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីបាន ចំពោះករណីដូចខាងក្រោមនេះ ៖

១. ក្នុងករណីដែលរកឃើញច្បាស់ថា កូនបំណុល ឬកូនបំណុលនៃការអនុវត្តមិនមែនជាកម្មសិទ្ធិករ ឬភោគីនៃដីដែលជាកម្មវត្ថុនៃការចុះបញ្ជីនៅពេលកំពុងដំណើរការនីតិវិធីចុះបញ្ជីលើកដំបូង ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ដោយផ្អែកតាមបទដ្ឋានគតិយុត្តទាក់ទងនឹងការចុះបញ្ជីដីលើកដំបូងដែលនៅជាធរមាន ។

២. ក្នុងករណីដែលរកឃើញច្បាស់ថា កូនបំណុល ឬកូនបំណុលនៃការអនុវត្តមិនមែនជាកម្មសិទ្ធិករ ឬអ្នកជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលជាកម្មវត្ថុនៃការចុះបញ្ជី នៅពេលកំពុងដំណើការនីតិវិធីដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ ដោយផ្អែកតាមបទដ្ឋានគតិយុត្តទាក់ទងនឹងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលនៅជាធរមាន ។

៣. ក្នុងករណីដែលតុលាការអនុវត្តពុំបានផ្តល់ឯកសារភ្ជាប់ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ មកជាមួយនឹងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ។

៤. ក្នុងករណីដែលពុំបានផ្តល់ឯកសារចាំបាច់សម្រាប់នីតិវិធីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ក្នុងអំឡុងពេលសមរម្យដែលកំណត់ដោយមន្ត្រីចុះបញ្ជី ។

៥. ក្នុងករណីដែលតុលាការអនុវត្តពុំបានផ្តល់ទៅឱ្យរដ្ឋបាលសុរិយោដីនូវសោហ៊ុយសេវាផ្សេងៗទាក់ទងនឹងការចុះបញ្ជីដីលើកដំបូង ឬការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ដែលម្ចាស់បំណុល ឬម្ចាស់បំណុលនៃការអនុវត្តបានបង់តាមប្រការ ៩ នៃប្រកាសនេះរួចហើយ ។

៦. ក្នុងករណីដែលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីត្រូវបានដាក់ខុសសមត្ថកិច្ច ។

៧. ករណីចំណុចដែលមាននៅក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីផ្ទុយនឹងប្រកាសនេះ ។

ក្នុងករណីមានការលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីដោយផ្អែកតាមប្រការនេះ រដ្ឋបាលសុរិយោដីត្រូវធ្វើលិខិតលើកចោលជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុនៃការលើកចោល ហើយត្រូវផ្ញើលិខិតលើកចោលនេះ និងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រួមទាំងឯកសារភ្ជាប់ទៅតុលាការដែលបានចេញលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ ។

**ប្រការ ១១._ នីតិវិធីនៃការចុះបញ្ជីលើកដំបូង ក្រោយពីការលើកចោល**

១. ទោះបីជាមានការលើកចោលនូវលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកតាមប្រការ ១០ កថាខណ្ឌទី ១ ចំណុចទី ១ និងចំណុចទី២ ក៏ដោយ ក៏ការលើកចោលនេះពុំរាំងដល់ការអនុវត្តនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិតាមការស្នើសុំពីបុគ្គលដែលត្រូវជាកម្មសិទ្ធិករឬភោគីនៃដីពិតប្រាកដ ឬកម្មសិទ្ធិករឬអ្នកជួលអចិន្ត្រៃយ៍ចំណែកឯកជននៃអគារសហកម្មសិទ្ធិពិតប្រាកដឡើយ។

២. ម្ចាស់សិទ្ធិពិតប្រាកដដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើ ជាអ្នកទទួលបន្ទុកលើសោហ៊ុយសម្រាប់ការចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ។

ក្នុងករណីដែលម្ចាស់សិទ្ធិពិតប្រាកដនោះ មិនបានបង់សោហ៊ុយនោះទេ មន្ត្រីចុះបញ្ជីមានសិទ្ធិផ្អាកនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះបាន ។

## ជំពូកទី៣

## អន្តរប្បញ្ញត្តិ

**ប្រការ ១២._ អន្តរប្បញ្ញត្តិ**

ប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីចុះបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដែលត្រូវបានផ្ញើមករដ្ឋបាលសុរិយោដីមានសមត្ថកិច្ចមុនការអនុវត្តប្រកាសអន្តរក្រសួងនេះ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលនីតិវិធីចុះបញ្ជីទាំងនោះត្រូវបានអនុវត្តរួចហើយ ។

# ជំពូកទី៤
# អវសានប្បញ្ញត្តិ

## ប្រការ ១៣._ កាលបរិច្ឆេទនៃការអនុវត្ត

ប្រកាសនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

## ប្រការ ១៤._ និរាករណ៍នៃបទប្បញ្ញត្តិដែលផ្ទុយ

បទប្បញ្ញត្តិទាំងឡាយណាដែលមានអានុភាពពេលប្រកាសនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងប្រកាសនេះ ចាប់ពីថ្ងៃដែលប្រកាសនេះត្រូវបានអនុវត្ត ។

រាជធានីភ្នំពេញ ថ្ងៃទី...២១...ខែ...វិច្ឆិកា...ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍានៈ

**ចម្លងជូន:**

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
  *"ដើម្បីជូនជ្រាប"*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *តុលាការគ្រប់ជាន់ថ្នាក់*
- *មហាអយ្យការអមតុលាការកំពូល*
- *មហាអយ្យការអមសាលាឧទ្ធរណ៍*
- *អយ្យការអមសាលាដំបូងរាជធានី ខេត្ត*
- *សាលារាជធានី ខេត្ត*
- *មន្ទីរ ដនសស "ដើម្បីមុខការ"*
- *ឯកសារ កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី៣

# ពាក្យសុំឱ្យចេញដីកា

# សម្រេចរក្សាការពារ

# ព្រះរាជាណាចក្រកម្ពុជា

①

## ជាតិ សាសនា ព្រះមហាក្សត្រ

### ទម្រង់គំរូ[8]

### ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ

ខ្ញុំ **P** ជាមេធាវីនៃក្រុមមេធាវី...................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់......... ផ្លូវលេខ............សង្កាត់.................ខណ្ឌ...............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ...............។

### សូមគោរពជូន

### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក. ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ**

១. រឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធ។

២. កូនបំណុលត្រូវធ្វើប្រាក់រំដោះចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន។[9]

៣. ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់កូនបំណុល។

**ខ. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ**

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ម្ចាស់បំណុល និងកូនបំណុល បានចុះកិច្ចសន្យាខ្ចីប្រាក់ ក្នុងចំនួនទឹកប្រាក់ ១០០.០០០ (មួយសែន) ដុល្លារអាមេរិក ដោយកំណត់ពេលសងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។[10] នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ ម្ចាស់បំណុល និង កូនបំណុល បានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខារបស់កូនបំណុលអំពីការបង់ការប្រាក់ចំនួន ១០%/ឆ្នាំ (ដប់ភាគរយក្នុងមួយឆ្នាំ) និងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ២០%/ឆ្នាំ (ម្ភៃភាគរយក្នុងមួយឆ្នាំ) នៃប្រាក់កម្ចីចំនួន ១០០.០០០ (មួយសែន) ដុល្លារអាមេរិក ខាងលើ។[11] (ភស្តុតាង $X_1$)

[8] ទម្រង់គំរូនេះ គាត់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ជាពិសេសចំណុចស្ដីពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ។

[9] ចំណុចស្ដីពីប្រាក់រំដោះ ជាការកំណត់របស់តុលាការ ហេតុនេះ ម្ចាស់បំណុលមិនចាំបាច់សរសេរនូវចំណុចនេះក៏បាន។

[10] មាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី។

[11] មាត្រា ៥៨៣ កថាខណ្ឌទី ៣ និងមាត្រា ៥៨៤ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី។

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ម្ចាស់បំណុលបានប្រគល់ប្រាក់ចំនួន ១០០.០០០ (មួយសែន) ដុល្លារអាមេរិក ទៅឱ្យកូនបំណុល ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ខាងលើ។[12] (ភស្តុតាង $X_2$)

ថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ បានកន្លងផុត។[13]

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ម្ចាស់បំណុលមិនបានទទួលការសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ពីកូនបំណុល ដែលជាការសងមួយផ្នែកនៃសិទ្ធិលើបំណុលនោះទេ ហើយក៏មិនបានលើកលែងបំណុលចំពោះផ្នែកដែលនៅសល់ផងដែរ ពីព្រោះមុនពេលដាក់បណ្ដឹង ម្ចាស់បំណុលបានទាមទារប្រាក់ទៅកូនបំណុលតាមរយៈទូរស័ព្ទ។

ហេតុនេះសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះកូនបំណុល គិតមកដល់ថ្ងៃដាក់ពាក្យសុំនេះ មានចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) ដុល្លារអាមេរិក។

## គ. ភាពចាំបាច់នៃការរក្សាការពារ

ថ្មីនេះៗ កូនបំណុល បានប្រកាសដាក់លក់ ដី L1&L2 ដូចមានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធ ដែលជាកម្មសិទ្ធិរបស់កូនបំណុល តាមរយៈគណនី Facebook របស់កូនបំណុលដែលមានឈ្មោះ BB ដោយប្រកាសលក់ដីទាំងពីរក្នុងតម្លៃ ១៣០.០០០ (មួយសែនបីម៉ឺន) ដុល្លារអាមេរិក ដែលជាតម្លៃទាបជាងទីផ្សារ។

ចាប់តាំងពីថ្ងៃដែលកូនបំណុលមិនសងប្រាក់ ម្ចាស់បំណុលបានធ្វើការដាស់តឿនឱ្យកូនបំណុលសងប្រាក់ជាច្រើនលើកច្រើនសាតាមរយៈទូរស័ព្ទ សូម្បីតែមុនពេលដាក់ពាក្យបណ្ដឹង ក៏ម្ចាស់បំណុលបានទាក់ទងទៅកូនបំណុលដើម្បីបញ្ជាក់អំពីបញ្ហានេះដែរ ប៉ុន្តែកូនបំណុលមិនលើកទូរស័ព្ទ ឆាតតាម **Telegram** ក៏កូនបំណុលមិនចូលមើលដែរ នេះបញ្ជាក់យ៉ាងច្បាស់ថា កូនបំណុលមានបំណងគេចវេសមិនសងប្រាក់ដែលជំពាក់។

ម្យ៉ាងវិញទៀត ក្នុងអំឡុងពេលដែលម្ចាស់បំណុល នៅមានទំនាក់ទំនងជាមួយកូនបំណុលកន្លងមក ម្ចាស់បំណុលបានដឹងថា ទ្រព្យសម្បត្តិមានតម្លៃរបស់កូនបំណុល មានតែដីចំនួន ០២ (ពីរ) កន្លែងខាងលើនោះប៉ុណ្ណោះ។

ប្រសិនបើមិនចាត់វិធានការបន្ទាន់ជាបណ្ដោះអាសន្ននោះទេ កូនបំណុលអាចចាត់ចែងដីទាំងនោះទៅឱ្យតតិយជន។ ពេលនោះ ដីទាំងពីរកន្លែងនឹងមិនស្ថិតក្រោមកម្មសិទ្ធិរបស់កូនបំណុលទៀតឡើយ នាំឱ្យការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល នឹងមិនអាចអនុវត្តដោយបង្ខំបាន ហេតុនេះ មានភាពចាំបាច់ក្នុងការរឹបអូសជាបណ្ដោះអាសន្ននូវដីទាំងពីរកន្លែងរបស់កូនបំណុល ដើម្បីការពារសិទ្ធិរបស់ម្ចាស់បំណុល ក្នុងការទាមទារឱ្យសងប្រាក់។

[12] មាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី។

[13] មាត្រា ៥៩១ និងមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី។

**ឃ. សេចក្តីបញ្ជាក់ដំបូង**

១. កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ (ភស្តុតាង $X_1$)

២. លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ (ភស្តុតាង $X_2$)

៣. របាយការណ៍ស្តីពីស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល។ (ភស្តុតាង $X_3$)

**ខ. ឯកសារភ្ជាប់**

១. ច្បាប់ថតចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់កូនបំណុល

២. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

៣. លិខិតថតចម្លងនៃភស្តុតាងនីមួយៗខាងលើចំនួន ០២ (ពីរ) ច្បាប់

៤. ឯកសារវាយតម្លៃដី L1,L2

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

**អ្នកតំណាងដោយអាណត្តិ**

# ឧបសម្ព័ន្ធ
# បញ្ជីនាគី

**ម្ចាស់បំណុល៖**

ឈ្មោះ **A** អាសយដ្ឋាន......................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **P** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់.......... ផ្លូវលេខ.............សង្កាត់..................ខណ្ឌ................រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី..................................................................................។

**កូនបំណុល៖**

ឈ្មោះ **B** អាសយដ្ឋាន......................................................................................................។

# ឧបសម្ព័ន្ធ
# បញ្ជីសិទ្ធិលើបំណុល

**១. ប្រាក់ដើមចំនួន៖** 100,000 ( មួយសែន ) ដុល្លារអាមេរិក

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

**២. ការប្រាក់៖** 10% ក្នុងមួយឆ្នាំនៃប្រាក់កម្ចី 100,000 (100,000 X 10% X 2) ស្មើនឹង 20,000( ពីរម៉ឺន ) ដុល្លារអាមេរិក

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

**៣. ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច (ការប្រាក់យឺតយ៉ាវ)៖** 20% ក្នុងមួយឆ្នាំនៃប្រាក់កម្ចី 100,000 (មួយសែន ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ រហូតដល់ពេលសងសិទ្ធិលើបំណុលគ្រប់ចំនួន

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធ

## បញ្ជីវត្ថុ (អចលនវត្ថុ)

### ដី L1

**១. ទីតាំងអចលនវត្ថុ៖** ផ្ទះលេខ៣០៤ ផ្លូវលេខ១១៨ ក្រុម៥ ភូមិ ២ សង្កាត់ផ្សារថ្មីទី ១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**២. លេខក្បាលដី៖** វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០១៨០៣៤៥-១១៩២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**៣. ទំហំដី៖** ១២០ (មួយរយម្ភៃ) ម៉ែត្រការ៉េ។

**៤. រូបភាពប្រើប្រាស់ដី៖** ដីលំនៅឋាន។

**៥. សមាសភាគនៃដី៖** មានអគារ (ផ្ទះ)។

### ដី L2

**១. ទីតាំងអចលនវត្ថុ៖** ភូមិព្រៃករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

**២. លេខក្បាលដី៖** វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៦០៣-១២០៦ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**៣. ទំហំដី៖** ៧៥០ (ប្រាំពីររយហាសិប) ម៉ែត្រការ៉េ។

**៤. រូបភាពប្រើប្រាស់ដី៖** ដីលំនៅឋាន។

**៥. សមាសភាគនៃដី៖** គ្មានអគារ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ទម្រង់គំរូ[14]
## របាយការណ៍ស្តីពី
## ស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២០ កូនបំណុលបានប្រកាសលក់ដីជាបន្ទាន់ ចំពោះ L1 ,L2 ដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ ក្នុងតម្លៃ ១៣០.០០០ (មួយសែនបីម៉ឺន) ដុល្លារអាមេរិក តាមរយៈគណនី Facebook របស់កូនបំណុលឈ្មោះ BB ប៉ុន្តែការផុសនេះ មិនបានប៉ុន្មាននាទី កូនបំណុលក៏លុបចោលវិញ ។

តាមការស្រាវជ្រាវរបស់ម្ចាស់បំណុល ដីទាំងពីរនេះ គួរតែលក់ក្នុងតម្លៃប្រហែល ១៥០.០០០ (មួយសែនប្រាំម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែដោយសារតែ កូនបំណុលប្រញាប់លក់ដីនោះឆាប់ៗ ទើបលក់ក្នុងតម្លៃដែលទាបជាងតម្លៃទីផ្សារ ។

ហេតុនេះ ម្ចាស់បំណុលធ្វើការវាយតម្លៃថា កូនបំណុលកំពុងព្យាយាមលក់ដីទាំងពីរកន្លែងខាងលើ ហើយដីទាំងពីរនេះ ប្រហែលជាអាចមានអ្នកទិញក្នុងពេលឆាប់ៗនេះ ពីព្រោះទីតាំងល្អ ហើយតម្លៃថោកជាងតម្លៃទីផ្សារ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

**ម្ចាស់បំណុល**

[14] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេររបាយការណ៍ស្តីពីស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ទម្រង់គំរូ[15]
## របាយការណ៍សង្ខេបស្តីពីការវាយតម្លៃអចលនវត្ថុ

**យោង៖ V14-1603**

**កាលបរិច្ឆេទវាយតម្លៃ៖ 10** មករា **2020**

**គោលបំណងនៃការវាយតម្លៃ៖** ការលក់តាមផ្លូវតុលាការ

**ឈ្មោះកម្មសិទ្ធិករ៖ B**

**រៀបចំសម្រាប់ ៖** តុលាការ

ការវាយតម្លៃលើអចលនវត្ថុដែលមានទីតាំងស្ថិតនៅភូមិ ២ សង្កាត់ផ្សារថ្មី ១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០១៨០៣៤៥-១១៩២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**តម្លៃទីផ្សារ**

**108,000** (មួយសែនប្រាំបីពាន់) ដុល្លារអាមេរិក

ការបែងចែកតម្លៃទីផ្សារ៖

| កម្មវត្ថុនៃអចលនវត្ថុ | ផ្ទៃក្រឡា (ម៉ែត្រការ៉េ) | តម្លៃជាដុល្លារអាមេរិក/ម៉ែត្រការ៉េ | តម្លៃទីផ្សារ (ដុល្លារអាមេរិក) |
|---|---|---|---|
| ដី | **120** | **$600** | **$72,000** |
| អគារ | **72** | **$500** | **$36,000** |

**តម្លៃលក់ដោយបង្ខំ (លក់ឡាយឡុង)**

**90,000** (ប្រាំបួនម៉ឺន) ដុល្លារអាមេរិក

**តម្លៃធានារ៉ាប់រងករណីភ្លើងឆេះ**

**108,000** (មួយសែនប្រាំបីពាន់) ដុល្លារអាមេរិក

តំណាងឱ្យ **ABC Co., Ltd**

ប្រធានផ្នែកវាយតម្លៃ នាយកប្រតិបត្តិ

លេខវិញ្ញាបនបត្រ **V-10-079-03** លេខអាជ្ញាបណ្ណ **EV-10-07**

[15] ទម្រង់គំរូនេះ គាត់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបាយការណ៍ស្តីពីការវាយតម្លៃអចលនវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ឧទាហរណ៍គំរូ
## របាយការណ៍សង្ខេបស្តីពីការវាយតម្លៃអចលនវត្ថុ

**យោង៖ V14-1604**

**កាលបរិច្ឆេទវាយតម្លៃ៖ 10** មករា **2020**

**គោលបំណងនៃការវាយតម្លៃ៖** ការលក់តាមផ្លូវតុលាការ

**ឈ្មោះកម្មសិទ្ធិករ៖ B**

**រៀបចំសម្រាប់ ៖** តុលាការ

ការវាយតម្លៃលើអចលនវត្ថុដែលមានទីតាំងស្ថិតភូមិព្រៃករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៦០៣-១២០៦ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**តម្លៃទីផ្សារ**

**48,000** (បួនម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក

ការបែងចែកតម្លៃទីផ្សារ៖

| កម្មវត្ថុនៃអចលនវត្ថុ | ផ្ទៃក្រឡា (ម៉ែត្រការ៉េ) | តម្លៃជាដុល្លារអាមេរិក/ម៉ែត្រការ៉េ | តម្លៃទីផ្សារ (ដុល្លារអាមេរិក) |
|---|---|---|---|
| ដី | **$750** | **$64** | **$48,000** |

**តម្លៃលក់ដោយបង្ខំ (លក់ឡាយឡុង)**

**40,000** (បួនម៉ឺន) ដុល្លារអាមេរិក

តំណាងឱ្យ **ABC Co., Ltd**

ប្រធានផ្នែកវាយតម្លៃ នាយកប្រតិបត្តិ

លេខវិញ្ញាបនបត្រ **V-10-079-03** លេខអាជ្ញាបណ្ណ **EV-10-07**

សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

②

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០
ដីកាសម្រេចលេខ ២០ «ខ» ដ.រ
ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០

## ទម្រង់គំរូ[16]

## ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ

## យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញមាត្រា ៥៤១ និងមាត្រា ៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០២-០៣-២០២០
- បានឃើញសំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០២-០៣-២០២០

**ម្ចាស់បំណុល៖** ឈ្មោះ **A** អាសយដ្ឋាន..........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **P** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល៖** ឈ្មោះ **B** អាសយដ្ឋាន............................................................................។

## សំអាងហេតុ

១. ......................................................................................................................

២. ......................................................................................................................

៣. ......................................................................................................................

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឱ្យម្ចាស់បំណុលផ្ញើប្រាក់ចំនួន ២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ជាប្រាតិភោគសម្រាប់កូនបំណុល មកតុលាការឱ្យបានមុនថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

២. ប្រសិនបើម្ចាស់បំណុលមិនអនុវត្តករណីយកិច្ចខាងលើ (១) តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យសុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០

**ចៅក្រម**

[16] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពី ខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ ជាពិសេសការកំណត់នូវចំនួនប្រាតិភោគ។

③

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០
ដីកាសម្រេចលេខ ២១ «ខ» ដ.រ
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០

## ទម្រង់គំរូ[17]

## ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[18]

## យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញមាត្រា ៥៤១ និងមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០២-០៣-២០២០
- បានឃើញសំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០២-០៣-២០២០

**ម្ចាស់បំណុល៖** ឈ្មោះ A អាសយដ្ឋាន........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល៖** ឈ្មោះ B អាសយដ្ឋាន.........................................................................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ**

១. រឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធ។

២. កូនបំណុលត្រូវផ្ញើប្រាក់រំដោះចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន។

៣. ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់កូនបំណុល។

**បញ្ជីសិទ្ធិលើបំណុល៖** បញ្ជីឧបសម្ព័ន្ធស្ដីពីសិទ្ធិលើបំណុល

**បញ្ជីឧបសម្ព័ន្ធនៃវត្ថុ៖** បញ្ជីឧបសម្ព័ន្ធស្ដីពីវត្ថុ

[17] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីខ្លឹមសារនៃដីកាសម្រេចប្រភេទរឹបអូសជាបណ្ដោះអាសន្នទាក់ទងនឹងចំណុចនៃសេចក្ដីសម្រេចបញ្ចប់។

[18] មាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្ដីបញ្ជាក់ដំបូង**

១. កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ (ភស្តុតាង $X_1$)

២. លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ (ភស្តុតាង $X_2$)

៣. របាយការណ៍ស្ដីពីស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល។ (ភស្តុតាង $X_3$)

**សំអាងហេតុ**

.........................................................................................................................................

.........................................................................................................................................

........................................................................................................................................។

**សេចក្ដីសម្រេចបញ្ចប់**

១. រឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធនៃវត្ថុ។[19]

២. កូនបំណុលត្រូវធ្វើប្រាក់រំដោះចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន។[20]

៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

ដីកាសម្រេចនេះ អាចប្ដឹងតវ៉ាបានតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០

**ចៅក្រម**

[19] មាត្រា ៥៤៦ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[20] មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

# ព្រះរាជាណាចក្រកម្ពុជា

④

## ជាតិ សាសនា ព្រះមហាក្សត្រ

### ទម្រង់គំរូ[21]

### ពាក្យសុំឱ្យអនុវត្តរក្សាការពារ

ខ្ញុំ **P** ជាមេធាវីនៃក្រុមមេធាវី...................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់......... ផ្លូវលេខ............សង្កាត់.................ខណ្ឌ................រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ...............។

### សូមគោរពជូន

### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ៖** សំណើសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ

**យោង៖** - សំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

- មាត្រា **៥៦៤** និងមាត្រា **៥៦៧** នៃក្រមនីតិវិធីរដ្ឋប្បវេណី[22]

សេចក្ដីដូចមានកំណត់នៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមការស្នើសុំរបស់ម្ចាស់បំណុល ហេតុនេះស្នើសុំអនុវត្តដូចខ្លឹមសារខាងក្រោម៖

#### ក. សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

#### ខ. សេចក្ដីសុំឱ្យអនុវត្ត

វិធានអនុវត្តបង្ខំដោយផ្ទាល់ ដោយស្នើសុំតុលាការធ្វើលិខិតផ្អាកផ្ទាក់ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ទៅរដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ និងរដ្ឋបាលសុរិយោដីខេត្តកណ្ដាល។

[21] ទម្រង់គំរូនេះ គាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំអនុវត្តរក្សាការពារ។
[22] ខ្លឹមសារនៃពាក្យសុំអនុវត្តរក្សាការពារ អនុលោមតាមមាត្រា ៣៤៩ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**គ. សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តរក្សាការពារ**

កំណត់នៅក្នុងឧបសម្ព័ន្ធនៃវត្ថុដែលភ្ជាប់ជាមួយនឹងពាក្យសុំនេះ។

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០

**អ្នកតំណាងដោយអាណត្តិ**

ឯកសារភ្ជាប់

១. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

២. ដីកាសម្រេចបើកអូសជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ «ច្បាប់ដើម»

# ឧបសម្ព័ន្ធ
# បញ្ជីនាគី

**ម្ចាស់បំណុល៖**

ឈ្មោះ **A** អាសយដ្ឋាន.............................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **P** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់.......... ផ្លូវលេខ.............សង្កាត់..................ខណ្ឌ................រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី.............................................................................................។

**កូនបំណុល៖**

ឈ្មោះ **B** អាសយដ្ឋាន.............................................................................................................។

# ឧបសម្ព័ន្ធ
# បញ្ជីសិទ្ធិលើបំណុល

**១. ប្រាក់ដើមចំនួន៖** 100,000 ( មួយសែន ) ដុល្លារអាមេរិក

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

**២. ការប្រាក់៖** 10% ក្នុងមួយឆ្នាំនៃប្រាក់កម្ចី 100,000 (100,000 X 10% X 2) ស្មើនឹង 20,000( ពីរម៉ឺន ) ដុល្លារអាមេរិក

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

**៣. ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច (ការប្រាក់យឺតយ៉ាវ)៖** 20% ក្នុងមួយឆ្នាំនៃប្រាក់កម្ចី 100,000 ( មួយសែន ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ រហូតដល់ពេលសងសិទ្ធិលើបំណុលគ្រប់ចំនួន

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធទី៤

# ប្រកាសអន្តរក្រសួង ស្តីពី ការចុះបញ្ជីអចលនវត្ថុធាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១៣

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការចុះបញ្ជីអចលនវត្ថុ
# ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

# និង

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី
# អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី


រៀបចំដោយ
ក្រុមការងារអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និងសំណង់
និង
ក្រុមការងារប្រឹក្សាយោបល់របស់ប្រទេសជប៉ុន
ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ( JICA )
ប្រចាំក្រសួងយុត្តិធម៌



ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ២០០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ក្រសួងយុត្តិធម៌**

លេខ : ៤៩ ប្រក.ដ.ន.ស/១១

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៦អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- តាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីអចលនវត្ថុឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

១-ប្រកាសនេះ បញ្ញត្តអំពីនីតិវិធីនៃការផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស ការផ្ទេរ ការលុបចោល ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្ន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីនៃការចុះបញ្ជីទាំងនោះ ។

២-ប្រកាសនេះ ក៏បញ្ញត្តផងដែរអំពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុតាមរយៈ សាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ យោងតាមមាត្រា ៥២៩ (ការចាត់ទុកថាបានបង្ហាញឆន្ទៈ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ ត្រូវយកមកអនុវត្ត ចំពោះដីដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយដែលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានចេញ ។

ប្រកាសនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលត្រូវបានចុះបញ្ជី ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ។

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី**

ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីតាមន័យនៃប្រកាសនេះ គឺរដ្ឋបាលសុរិយោដីដែលបានកំណត់ដូចខាងក្រោមនេះ :

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ នៃប្រការ ២ (គោលបំណង)

ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្ដាក់ទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ២ នៃប្រការ ២ (គោលបំណង) ភាគីឈ្មះក្ដី ឬ ភាគីដែលមានកំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់នូវការទាមទារត្រូវដាក់ពាក្យសុំទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុដែលត្រូវចុះបញ្ជីតាំងនៅ ឬ រដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល ។

## ជំពូកទី ២
## ការចុះបញ្ជីតាមលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី

### ផ្នែកទី ១

### ទម្រង់ និងឯកសារភ្ជាប់ នៃលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី

**ប្រការ ៥ : ទម្រង់នៃលិខិតផ្ទុកផ្ដាក់**

លិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្ដាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី ។ ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃលិខិតផ្ទុកផ្ដាក់ ដូចមានចែងក្នុងផ្នែកទី ២ (ប្រភេទនៃលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី) នៃជំពូកទី ២ (ការចុះបញ្ជីតាមលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី) នៃប្រកាសនេះ ដោយមានបង្ហាញនៅក្នុងគំរូឧបសម្ព័ន្ធទៅតាមប្រភេទនៃលិខិតផ្ទុកផ្ដាក់នីមួយៗ ។

**ប្រការ ៦ : ឯកសារភ្ជាប់ជាមួយលិខិតផ្ទុកផ្ដាក់**

នៅពេលប្រគល់លិខិតផ្ទុកផ្ដាក់ ក្រឡាបញ្ជីត្រូវផ្ដល់ឯកសារចាំបាច់មួយចំនួនទៅឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីទៅតាមប្រភេទនៃលិខិតផ្ទុកផ្ដាក់ ដូចមានចែងក្នុងផ្នែកទី ២ (ប្រភេទនៃលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី) នៃជំពូកទី ២ (ការចុះបញ្ជីតាមលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី) នៃប្រកាសនេះ ។

# ផ្នែកទី ២

## ប្រភេទនៃលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី

## កថាភាគទី ១

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ប្រការ ៧ :** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយផ្អែកលើមាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការអនុវត្ត ចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ។

បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានចេញរួចហើយ តែមានពាក្យសុំអនុវត្តដោយបង្ខំថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការបានទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីមួយទៀត (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ។

ចំពោះការចុះបញ្ជីដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ៧ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ) នេះ លិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :......................(សរសេរអំពីខ្លឹមសារនៃការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន....................)

គ-គោលបំណងនៃការចុះបញ្ជី..........................................(រឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច "ក")

ឃ-មូលហេតុ...............................(ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ

លេខ.......ចុះថ្ងៃទី......ខែ.....ឆ្នាំ......និងឈ្មោះរបស់តុលាការ..............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត......................(អាសយដ្ឋាន.............. ................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត......................(អាសយដ្ឋាន.............. ................................)

ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូត នៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំផង ដែរ ។

**ប្រការ ៨ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោល នីតិវិធីលក់ដោយបង្ខំបានកើតឡើងទៅលើអចលនវត្ថុដែលត្រូវរឹបអូស ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័ន មានសមត្ថកិច្ចឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ហើយលិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌ ទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:....................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស អចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..........................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន.......................................................)

គ-គោលបំណងនៃការចុះបញ្ជី................. (លុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច “ក” )

ឃ-មូលហេតុ....................(ពាក្យសុំលក់ដោយបង្ខំត្រូវបានដកចេញ ចុះថ្ងៃទី..... ខែ........ឆ្នាំ......... ឬដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី...... ខែ.......ឆ្នាំ........ ហើយថ្ងៃទី....ខែ........ឆ្នាំ......... ដែលដីកាសម្រេចមានអានុភាព និង ឈ្មោះរបស់តុលាការ..............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត........................(អាសយដ្ឋាន............. .............................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន............
..............................) ។

ឯកសារភ្ជាប់ជាមួយ ៖

១-ក្នុងករណីមានការដកពាក្យសុំឱ្យលក់ដោយបង្ខំ ៖

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំមានអានុភាព ៖

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជី ថាបានចូលជាស្ថាពរ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ឃ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ង-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ៤ នៃមាត្រា ៤៤៣ (វិធានការក្នុងករណីលក់ហួសកម្រិត) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

**ប្រការ ៩ :** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការផ្ទេរផលុបភោគ តាមការលក់ដោយបង្ខំ ដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគដែលអ្នកទិញបានធ្វើលទ្ធកម្ម និងឱ្យលុបការចុះបញ្ជីដោយត្រូវ :

១-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

២-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៣-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ។

៤-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ។

ចំពោះលិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :........................................(សរសេរអំពីខ្លឹមសារនៃការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី )

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន ..........................................)

គ-គោលបំណងនៃការចុះបញ្ជី :

-ផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការលក់ដោយបង្ខំទៅអោយឈ្មោះ.......................

-លុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ទៅលើចំណុច "ក"

-លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច "ក"

-លុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ទៅលើចំណុច"ក" ។

ឃ-មូលហេតុ :

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........ចុះថ្ងៃទី.....ខែ......ឆ្នាំ......និងឈ្មោះរបស់តុលាការ....................................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...............នៅថ្ងៃទី.....ខែ.....ឆ្នាំ.....។

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត........................(អាសយដ្ឋាន...................................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន...................................................)

ឆ-អត្តសញ្ញាណអ្នកទិញ...................(ថ្ងៃទី......ខែ.......ឆ្នាំ.......ទីកន្លែងកំណើត ឈ្មោះឪពុកម្ដាយ អាសយដ្ឋាន............................ របស់អ្នកទិញ) ។

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ២

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**ប្រការ ១០ :** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ

ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៥១១ និងមាត្រា ៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការអនុវត្តចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមាន

សមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគនោះ ។

បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានចេញរួចហើយ តែមានពាក្យសុំអនុវត្តសិទ្ធិប្រាតិភោគថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការបានទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីមួយទៀត (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ញើផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ច ធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយអនុវត្តសិទ្ធិប្រាតិភោគ ។

ចំពោះការចុះបញ្ជីដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ១០ (លិខិតផ្ញើផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ) នេះ លិខិតផ្ញើផ្ដាក់ក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ញើផ្ដាក់) ត្រូវសរសេរបន្ថែម នូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ: ........................(សរសេរអំពីខ្លឹមសារការផ្ញើផ្ដាក់ចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.........................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី )

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន ..............................................)

គ-គោលបំណងនៃការចុះបញ្ជី..............................(រឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច "ក" )

ឃ-មូលហេតុ......................(ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.......និងឈ្មោះរបស់តុលាការ..............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន............... ...................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន.............. ...................................)

ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូត នៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំផងដែរ ។

**ប្រការ ១១ : លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើងទៅលើការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ហើយលិខិតផ្ទុកផ្តាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:....................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ...........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ..............(អាសយដ្ឋាន.........................................)

គ-គោលបំណងនៃការចុះបញ្ជី.......................(លុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុចំណុច “ក” )

ឃ-មូលហេតុ..............(ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវបានដកចេញ ចុះថ្ងៃទី......ខែ.........ឆ្នាំ......... ឬ ដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ........ឆ្នាំ........... ហើយថ្ងៃទី......ខែ........ឆ្នាំ........ ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ...........................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន...............................................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន...............................................................)

ឯកសារភ្ជាប់ជាមួយ:

១-ក្នុងករណីមានការដកពាក្យសុំការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹម

ត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំ ធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ មានអានុភាព :

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៤៩៨ (ការផ្អាក និងការលុបចោលការអនុវត្តសិទ្ធិប្រាតិភោគ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥(ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវលិខិតចម្លងយថាភូតនៃដីកាសម្រេចលុបចោល ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធី ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ឃ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់)ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ។

ង-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ៤ នៃមាត្រា ៤៤៣ (វិធានការក្នុងករណីលក់ហួសកម្រិត) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

**ប្រការ ១២ : លិខិតផ្ញើកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគតាមការអនុវត្តសិទ្ធិប្រាតិភោគដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ញើកផ្តាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម និងឱ្យលុបការចុះបញ្ជី ។ ប៉ុន្តែក្នុងករណីអ្នកទិញជាអ្នកធានាដោយវត្ថុ ដែលជាម្ចាស់សិទ្ធិដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ក្រឡាបញ្ជីមិនចាំបាច់ធ្វើការផ្ញើកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគទេ ។

ចំណុចដែលត្រូវផ្អាកផ្អាក់ឱ្យចុះបញ្ជីផ្ទេរសិទ្ធិ និងឱ្យលុបការចុះបញ្ជីគឺ :

១-ផ្អាកផ្អាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

២-ផ្អាកផ្អាក់ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៣-ផ្អាកផ្អាក់ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ។

៤-ផ្អាកផ្អាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ។

លិខិតផ្អាកផ្អាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្អាកផ្អាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :......................(សរសេរអំពីខ្លឹមសារនៃការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន )

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន................................................)

គ-គោលបំណងនៃការចុះបញ្ជី :

-ផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការលក់ដោយបង្ខំទៅឱ្យឈ្មោះ ..................................

-លុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច "ក"

-លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច "ក"

-លុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន ទៅលើចំណុច "ក" ។

ឃ-មូលហេតុ ៖

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......ចុះថ្ងៃទី....ខែ.....ឆ្នាំ..... និងឈ្មោះរបស់តុលាការ...........................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ..................នៅថ្ងៃទី........ខែ.......ឆ្នាំ.........

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត....................(អាសយដ្ឋាន................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត......................(អាសយដ្ឋាន................)

ឆ-អត្តសញ្ញាណអ្នកទិញ...........................(ថ្ងៃទី.....ខែ.....ឆ្នាំ......ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ អាសយដ្ឋាន ........................................)

ឯកសារភ្ជាប់ជាមួយ៖

-ឯកសារចម្លងយថាភូត នៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ដែលបញ្ជាក់ថាអ្នកទិញ បានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ៣

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះ
## សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ១៣ ៖** លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានចុះបញ្ជីបានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។

ចំពោះពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុល (ប្រសិនបើមាន)

-សញ្ញាណរបស់ម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុលនៃការអនុវត្ត និងកូនបំណុលទី ៣

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃសិទ្ធិលើបំណុល ដែលម្ចាស់បំណុលទាមទារឱ្យអនុវត្តដោយបង្ខំទៅលើកូនបំណុលនៃការអនុវត្ត ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:..............................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ...... ..............................(អាសយដ្ឋាន.............................................)

គ-គោលបំណងនៃការចុះបញ្ជី..........................(ការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ....................(ដីកាសម្រេចចរឹបអូសលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....ហើយថ្ងៃទី.....ខែ.....ឆ្នាំ......ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ ..............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន........... ........................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត............................(អាសយដ្ឋាន......... ........................)

ឆ-ឈ្មោះកូនបំណុលទី ៣ ............................(អាសយដ្ឋាន.................
........................)

ជ- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូស ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជី អំពីកាលបរិច្ឆេទ ដែលដីកាសម្រេចរឹបអូសនោះមានអានុភាព។

ចំពោះដីកាសម្រេចរឹបអូសខាងលើមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលមានសេចក្តីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

**ប្រការ ១៤ : លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដោយផ្អែកលើមាត្រា ៤០៨ មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើមានពាក្យសុំឱ្យលុបការចុះបញ្ជី ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ក្នុងករណីណាមួយដូចខាងក្រោមនេះ :

- បើពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលត្រូវបានដកវិញ ឬ
- បើដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលមានអានុភាព ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការផ្ញើប្រាក់ទៅតុលាការអនុវត្តដូចជា : សញ្ញាណនៃរឿងក្តី ឈ្មោះនាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត មូលហេតុនៃការផ្ញើចំនួនទឹកប្រាក់ដែលបានផ្ញើជាដើម ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុៈ..........................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណ

ដែលជាកម្មវត្ថុនៃហីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន ..........................................................................)

គ-គោលបំណងនៃការចុះបញ្ជី..................(ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ........................(ការដកពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលនៅថ្ងៃទី.......ខែ......ឆ្នាំ.......ដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលលេខ......ចុះថ្ងៃទី......ខែ.......ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ ឬ ការសងប្រាក់ ឬ ការផ្ញើប្រាក់របស់កូនបំណុលទី ៣ ចុះថ្ងៃទី..... ខែ......ឆ្នាំ........)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន........... ...........................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត............................(អាសយដ្ឋាន.......... ...........................................)

ឆ-ឈ្មោះកូនបំណុលទី៣....................................(អាសយដ្ឋាន.......... ...........................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល ដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីមានការដកពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុល :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លង យថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានអានុភាព :

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ)
ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

៣-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុល នៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្តីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តនោះ ។

៤-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការអនុវត្ត :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្តីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីកូនបំណុលទី ៣ ។

## ប្រការ ១៥ : លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើបានបញ្ចប់ការលក់ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតរួចហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជី

ផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូសតាមពាក្យសុំរបស់អ្នកទិញ ។

ចំពោះពាក្យសុំរបស់អ្នកទិញ ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលត្រូវបានផ្ទេរ

-សញ្ញាណអ្នកទិញ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណម្ចាស់អចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

-មូលហេតុនៃការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:..................................(សរសេរអំពីខ្លឹមសារឱ្យចុះបញ្ជីផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូស)

ក-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (អាសយដ្ឋាន.........................)

គ-គោលបំណងនៃការចុះបញ្ជី.......................(ផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត និងលុបការចុះបញ្ជីអំពីការរឹបអូស )

ឃ-មូលហេតុ.................(អាជ្ញាសាលាបានទទួលប្រាក់ពីការលក់ នៅថ្ងៃទី....... ខែ........ឆ្នាំ........... និងឈ្មោះរបស់តុលាការ..........................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត......................(អាសយដ្ឋាន.............. ........................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត........................(អាសយដ្ឋាន.............. ........................................)

ឆ-ឈ្មោះកូនបំណុលទី ៣..............................(អាសយដ្ឋាន............ ........................................)

ជ-អត្តសញ្ញាណអ្នកទិញ.......................................(អាសយដ្ឋាន...........
......................................)

ឈ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានជានា

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់

-ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម នៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅអាជ្ញាសាលារួចហើយ

-ឯកសារចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកទិញ ។

## កថាភាគទី ៤
## ការចុះបញ្ជីដែលពាក់ព័ន្ធនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

**ប្រការ ១៦ : លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើកថាខណ្ឌទី៣ និងទី ៤ នៃមាត្រា ៥៦៧ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

នៅពេលដែលតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល ។

បើដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្នបានអនុវត្តរួចហើយ តែមានពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថ្មីទៀត (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចចេញដោយតុលាការផ្សេង យោងតាមមាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:..........................(សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន..............................)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.................(អាសយដ្ឋាន .................................)

គ-គោលបំណងនៃការចុះបញ្ជី...............(ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ទៅលើអចលនវត្ថុចំណុច"ក")

ឃ-មូលហេតុ..........................(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ.......ចុះថ្ងៃទី..... ខែ.....ឆ្នាំ.......និងឈ្មោះរបស់តុលាការ....................... ។

ង-ឈ្មោះម្ចាស់បំណុល................................(អាសយដ្ឋាន...............................................................)

ច-ឈ្មោះកូនបំណុល.................................(អាសយដ្ឋាន...............................................................)

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ។

**ប្រការ ១៧ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៥៦៧ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ បើពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានដក ឬ បើដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្នបានបង្កើតអានុភាព ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ច ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននោះ ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

ខ-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្ដោះអាសន្នចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ................ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ......ចុះថ្ងៃទី....ខែ.....ឆ្នាំ.....របស់តុលាការ.....

...លរ.Aj....(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិជួលអចិន្ត្រៃយ៍** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្ដោះអាសន្នសិទ្ធិជួលអចិន្ត្រៃយ៍ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ........ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់តុលាការ............. លរ.Aj....(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ឃ-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្ដោះអាសន្នចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ................ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ.....ចុះថ្ងៃទី....ខែ.....ឆ្នាំ.... របស់តុលាការ..... ............លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ង-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នផលុបភោគ** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្ដោះអាសន្នផលុបភោគ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ....ចុះថ្ងៃទី....ខែ....ឆ្នាំ.....របស់តុលាការ............លរ.Aj.... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ច-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំណែកផលុបភោគដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្ដោះអាសន្នចំណែកផលុបភោគរបស់ឈ្មោះ...................... តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ......ចុះថ្ងៃទី....ខែ....ឆ្នាំ......របស់តុលាការ...... ..............លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី

(ជាទឹកខៀវ ឬ ខ្មៅ) " ។

**ប្រការ ៣៣ :** របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដី ទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ១៧ (លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើកថាខណ្ឌ ទី ៣ ទី ៤ នៃមាត្រា ៥៦៧ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការលុបទៅតាមប្រភេទនៃការលុបអំពីការរឹបអូសជាបណ្ដោះអាសន្ន :

**ក-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នកម្មសិទ្ធិ ឬ ការលុបការរឹបអូសជាបណ្ដោះអាសន្នចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពី " ការរឹបអូសជាបណ្ដោះអាសន្នកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូសជាបណ្ដោះអាសន្ន............ដែលតុលាការ.............. បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី....ខែ....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់តុលាការ...................លរ.Aj... ឬការដកពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្ន ឬ ការដកពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី....ខែ .....ឆ្នាំ...... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

**ខ-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពី ការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពី " ការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូសជាបណ្ដោះអាសន្ន........... ដែលតុលាការ................ បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី...ខែ.....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ..... ចុះថ្ងៃទី...ខែ......ឆ្នាំ.......របស់តុលាការ..........លរ.Aj.... ឬ ការដកពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្ន ឬ ការដកពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី.....ខែ.....

ឆ្នាំ..... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

គ-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពី ការរឹបអូសជាបណ្តោះអាសន្នផលុបភោគ ឬ ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំណែកផលុបភោគ ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹង ការចុះបញ្ជីអំពី " ការរឹបអូសជាបណ្តោះអាសន្នផលុបភោគ ឬ ចំណែកផលុបភោគ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូសជាបណ្តោះអាសន្ន........ដែលតុលាការ...........បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....តាមដីកាសម្រេចលុបចោលលេខ......ចុះថ្ងៃទី....ខែ...ឆ្នាំ.....របស់តុលាការ.......លរ.Aj... ឬ ការដកពាក្យសុំដីការឹបអូសជាបណ្តោះ-អាសន្ន ឬ ការដកពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នចុះថ្ងៃទី....ខែ....ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

## កថាភាគទី ៦
## របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ៣៤ :** របៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវ-ភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្តាក់ដែលបានកំណត់ក្នុងប្រការ ១៨ (លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ី-ប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើមាត្រា ៥៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃការរឹបអូសជាបណ្តោះអាសន្ន :

ក-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើកម្មសិទ្ធិ ត្រូវសរសេរក្នុង

“ សៀវភៅគោលបញ្ជីដីធ្លី ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលរបស់កូនបំណុលឈ្មោះ............ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលលេខ.....ចុះថ្ងៃទី.....ខែ.......ឆ្នាំ....... របស់តុលាការ......................... លរ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាធារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ )” ។

ខ-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង “ សៀវភៅគោលបញ្ជីដីធ្លី ” នៅក្នុងខ្ទង់ (Column) ត្រង់ “ បន្ទុកលើអចលនវត្ថុ ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលរបស់កូនបំណុលឈ្មោះ............ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលលេខ......ចុះថ្ងៃទី.....ខែ....ឆ្នាំ........ របស់តុលាការ...................... លរ.Aj.... (ជាទឹកក្រហម) រួចបោះត្រាលេខាធារឹកនិងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើសិទ្ធិផ្លូវអចិន្ត្រៃយ៍ ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីសិទ្ធិផ្លូវអចិន្ត្រៃយ៍ ” នៅក្នុងខ្ទង់ (Column) ត្រង់ “ បន្ទុកលើអចលនវត្ថុ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលរបស់កូនបំណុលឈ្មោះ............ តាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលលេខ.......ចុះថ្ងៃទី....ខែ......ឆ្នាំ....... របស់តុលាការ..................... លរ.Aj.... (ជាទឹកក្រហម) រួចបោះត្រាលេខាធារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

ឃ-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីសិទ្ធិផ្លូវអចិន្ត្រៃយ៍” នៅក្នុងខ្ទង់ (Column) ត្រង់ “ បន្ទុកលើអចលនវត្ថុ ” ដោយត្រូវសរសេរថា :

“ ត្រូវបានរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលរបស់កូនបំណុលឈ្មោះ............

តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលលេខ........ចុះថ្ងៃទី....ខែ.....ឆ្នាំ.......
របស់តុលាការ.......................លរ.Aj.... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និង
ចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

ង-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានា
ដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើផលុបភោគ ត្រូវសរសេរក្នុង
" សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយ
ត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលរបស់កូនបំណុលឈ្មោះ.............
តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលលេខ.......ចុះថ្ងៃទី....ខែ.....ឆ្នាំ........
របស់តុលាការ.......................លរ.Aj.... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និង
ចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

ច-ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានា
ដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើចំណែកផលុបភោគដែល
ជាសិទ្ធិរួម ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុក
លើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលរបស់កូនបំណុលឈ្មោះ...............
តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលលេខ......ចុះថ្ងៃទី....ខែ.....ឆ្នាំ........
របស់តុលាការ.......................លរ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និង
ចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ) " ។

**ប្រការ ៣៥ :** របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្តាក់ដែលបានកំណត់ក្នុងប្រការ ១៩ (លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ៥ នៃមាត្រា ៥៦៦ មាត្រា ៤០៨ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការលុបទៅតាមប្រភេទ

នៃការលុបការរឹបអូសជាបណ្ដោះអាសន្ន :

ក-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដូចគ្នានឹងការចុះបញ្ជីអំពី "ការរឹបអូសជាបណ្ដោះអាសន្ន សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូសជាបណ្ដោះអាសន្ន..........ដែលតុលាការ....................បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី....ខែ.....ឆ្នាំ.....តាមដីកាសម្រេចលុបចោលលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....របស់តុលាការ................លរ.Aj... ឬការដកពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ឬ ការដកពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត នៅថ្ងៃទី......ខែ......ឆ្នាំ...... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

ខ-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើសិទ្ធិជួលអចិន្ត្រៃយ៍ ឬ លើចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដូចគ្នានឹងការចុះបញ្ជីអំពី "ការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូសជាបណ្ដោះអាសន្ន.........ដែលតុលាការ..........បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.....ចុះថ្ងៃទី.....ខែ....ឆ្នាំ....របស់តុលាការ...........លរ.Aj... ឬការដកពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ឬ ការដកពាក្យសុំអោយអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត នៅថ្ងៃទី....ខែ....ឆ្នាំ....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

គ-ចំពោះការលុបការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានបង្កើតនៅលើផលុបភោគ ឬ លើចំណែកផលុបភោគដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពី "ការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូសជាបណ្ដោះអាសន្ន..........ដែលតុលាការ................ បានចេញដីកាសម្រេចលេខ......ចុះថ្ងៃទី....ខែ.....ឆ្នាំ.....តាមដីកាសម្រេចលុបចោលលេខ.... ....ចុះថ្ងៃទី.....ខែ......ឆ្នាំ.....របស់តុលាការ..................លរ.Aj.... ឬ ការដកពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ឬ ការដកពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត នៅថ្ងៃទី......ខែ... ឆ្នាំ...... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

## កថាភាគទី ៧
## របៀបចុះបញ្ជីដែលពាក់ព័ន្ធនឹងការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

**ប្រការ ៣៦** : របៀបចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និង សៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ២០ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុដោយផ្អែកលើមាត្រា ៥៧០ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង :

ក-ចំពោះការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងកម្ម-

សិទ្ធិ ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ តាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ....ចុះថ្ងៃទី...ខែ.....ឆ្នាំ.... របស់តុលាការ............. លរ.Aj.... " (ជាទឹកក្រហម) រួចបោះត្រាលេខាធិការ (ជាទឹកខៀវ) និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ខ-ចំពោះការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ.................តាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ.....ចុះថ្ងៃទី.....ខែ....ឆ្នាំ....របស់តុលាការ.......លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ (ជាទឹកខៀវ) និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**គ-ចំពោះការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងសិទ្ធិផ្លូវអចិន្ត្រៃយ៍** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិផ្លូវអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងសិទ្ធិផ្លូវអចិន្ត្រៃយ៍តាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ....ចុះថ្ងៃទី....ខែ....ឆ្នាំ....របស់តុលាការ................ លរ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាធិការ (ជាទឹកខៀវ) និងចុះកាលបរិច្ឆេទនៃការចុះ-បញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ឃ-ចំពោះការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិផ្លូវអចិន្ត្រៃយ៍" នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍របស់ឈ្មោះ............តាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ.......ចុះថ្ងៃទី....ខែ.......ឆ្នាំ.........របស់តុលាការ...........លរ.Aj....(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ (ជាទឹកខៀវ) និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ ) " ។

ង-ចំពោះការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងផលុបភោគ ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងផលុបភោគតាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ........ចុះថ្ងៃទី.....ខែ.....ឆ្នាំ....របស់តុលាការ..............លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ (ជាទឹកខៀវ) និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ ) " ។

ច-ចំពោះការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំណែកផលុបភោគដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា :

" ត្រូវបានចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំណែកផលុបភោគរបស់ឈ្មោះ............តាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ.....ចុះថ្ងៃទី....ខែ...ឆ្នាំ....របស់តុលាការ...............................លរ.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាធិការ (ជាទឹកខៀវ) និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ប្រការ ៣៧ : របៀបចុះបញ្ជីអំពីការលុបការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្តាក់ដែលបានកំណត់ក្នុងប្រការ ២១ (លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ដោយផ្អែកលើមាត្រា ៥៧០ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីលុបទៅតាមប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង :

ក-ចំពោះការចុះបញ្ជីអំពីការលុបការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពី " ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង............. ដែលតុលាការ...............បានចេញដីកាសម្រេចលេខ......ចុះថ្ងៃ....ខែ.....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ........ចុះថ្ងៃ.....ខែ....ឆ្នាំ..... របស់តុលាការ....................... លរ.Aj.... ឬ តាមការដកពាក្យសុំដីកាចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬ តាមការដកពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង ចុះថ្ងៃទី.... ខែ....ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម ) " ។

**ខ-ចំពោះការចុះបញ្ជីអំពីការលុបការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងសិទ្ធិផ្លូវអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីសិទ្ធិផ្លូវអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពី " ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងសិទ្ធិផ្លូវអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង............... ដែលតុលាការ.................បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី....ខែ.....ឆ្នាំ.......តាមដីកាសម្រេចលុបចោលលេខ.....ចុះថ្ងៃទី....ខែ.......ឆ្នាំ........របស់តុលាការ............លរ.Aj.... ឬ ការដកពាក្យសុំដីកាចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬ ការដកពាក្យសុំអនុវត្តដីកាចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ចុះថ្ងៃទី....ខែ......ឆ្នាំ..... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) "។

**គ-ចំពោះការចុះបញ្ជីអំពីការលុបការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់-ចែងផលុបភោគ ឬ ចំណែកផលុបភោគដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដូចគ្នានឹងការចុះបញ្ជីអំពី " ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងផលុបភោគ ឬ ចំណែកផលុបភោគ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង............... ដែលតុលាការ.................បានចេញដីកាសម្រេចលេខ......ចុះថ្ងៃទី....ខែ.....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.......ចុះថ្ងៃទី.....ខែ.....ឆ្នាំ.........របស់តុលាការ............លរ.Aj... ឬ ការដកពាក្យសុំដីកាចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬ ការដកពាក្យសុំ

អនុវត្តដីកាចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ចុះថ្ងៃទី.....ខែ.....ឆ្នាំ.... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

## កថាភាគទី ៨
## និតិវិធីបន្ទាប់ពីការចុះបញ្ជី

**ប្រការ ៣៨ : ការផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ទៅក្រឡាបញ្ជី**

បន្ទាប់ពីបានចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជីរួចហើយ រដ្ឋបាលសុរិយោដីត្រូវថតចម្លងចេញពីសៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិផលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគដែលបានចុះនោះ ដោយមានសេចក្តីបញ្ជាក់របស់ប្រធានរដ្ឋបាលសុរិយោដី រាជធានី-ខេត្ត ថា “ បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ” រួចផ្ញើទៅក្រឡាបញ្ជីដែលបានផ្ញើលិខិតផ្ទុកផ្តាក់នោះ ។

**ប្រការ ៣៩ : លិខិតផ្ទុកផ្តាក់ឱ្យកែតម្រូវ**

បើក្រឡាបញ្ជីពិនិត្យឃើញថា ឯកសារថតចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិផលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ ដែលត្រូវបានផ្ញើមកក្រឡាបញ្ជីចុះមិនបានត្រឹមត្រូវទៅតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ដូចជា មានចំណុចខ្វះ ឬ ចំណុចដែលមិនត្រឹមត្រូវ ឬ ការសរសេរខុសខ្ទង់ (Column) ជាអាទិ៍ ក្រឡាបញ្ជីអាចឱ្យរដ្ឋបាលសុរិយោដី រាជធានី ខេត្ត ធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវឡើងវិញបាន ។

ក្រោយពីរដ្ឋបាលសុរិយោដីបានធ្វើការកែតម្រូវរួចហើយ បញ្ញត្តិនៃប្រការ ៣៨ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ជំពូកទី ៣
## ការចុះបញ្ជីតាមអំណាចសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ

**ប្រការ ៤០ : ការចុះបញ្ជីតាមសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្ត ដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ**

ចំពោះការចុះបញ្ជីអំពីការបង្កើត ការកែប្រែ និងការលុបនូវសិទ្ធិ តាមសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ ភាគីអ្នកឈ្នះក្តី ឬ ភាគីដែលមានកំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់នូវការទាមទារ ត្រូវដាក់ពាក្យសុំទៅស្ថាប័នមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយនូវអនុសារសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ ព្រមទាំងឯកសារ ដែលចាំបាច់ផ្សេងទៀត ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**ប្រការ ៤១ : វិធានការអន្តរកាលទូទៅ**

នៅក្រោយពេលប្រកាសនេះ ត្រូវបានអនុវត្តនីតិវិធីនៃការផ្ទុកផ្តាក់ និងនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចាប់ផ្តើមមុនពេលអនុវត្តប្រកាសនេះ ត្រូវបន្តអនុវត្តបញ្ចប់តាមប្រកាសនេះ ។ ក្នុងករណីនេះ បញ្ញត្តិនេះពុំរារាំងអានុភាព ដែលបានកើតឡើងនៅក្នុងនីតិវិធីដែលបានធ្វើមុនពេលដែលប្រកាសនេះ ត្រូវបានអនុវត្តឡើយ ។

ក្នុងករណីប្រកាសនេះ ត្រូវបានអនុវត្តក្រោយពេលក្រឡាបញ្ជីបានធ្វើការផ្ទុកផ្តាក់ ឬ ភាគីបានស្នើសុំចុះបញ្ជីរួចហើយ ប៉ុន្តែមន្ត្រីមានសមត្ថកិច្ចចុះបញ្ជី មិនទាន់បានចុះបញ្ជីនៅឡើយ គឺត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

**ប្រការ ៤២ :វិធានការអន្តរកាលស្តីពីសិទ្ធិជួលរយៈពេលវែង**

សិទ្ធិជួលរយៈពេលវែង ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវចាត់ទុកថា ជាសិទ្ធិជួលអចិន្ត្រៃយ៍ ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិជួលរយៈពេលវែង ត្រូវអនុលោមតាមវិធីអនុវត្តចំពោះអចលនវត្ថុ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៤៣ : កាលបរិច្ឆេទនៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែ បានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

**ប្រការ ៤៤ : និរាករណ៍ នៃបទប្បញ្ញត្តិដែលផ្ទុយ**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានអានុភាពនៅពេលប្រកាសនេះ ត្រូវបានអនុវត្តហើយ ផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងប្រកាសនេះ ចាប់ពីថ្ងៃដែលប្រកាសនេះ ត្រូវបានអនុវត្ត ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អ៊ឹម ឈុនលឹម

រដ្ឋមន្ត្រី
ក្រសួងយុត្តិធម៌
អង្គ វង្សវឌ្ឍានា

**ចម្លងជូន :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-តុលាការគ្រប់ជាន់ថ្នាក់
-មហាអយ្យការអមតុលាការកំពូល
-មហាអយ្យការអមសាលាឧទ្ធរណ៍
-អយ្យការអមតុលាការរាជធានី ខេត្ត
-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
-នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
-មន្ទីរ ដនសស រាជធានី ខេត្ត
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង................
លេខ........................

................,ថ្ងៃទី....ខែ.......ឆ្នាំ.......

## លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ

( ប្រការ ៧ )

យើង.........................ក្រឡាបញ្ជីនៃសាលាដំបូង..................................

សូមជម្រាបជូន
លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី.......(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត )

កម្មវត្ថុ : ..................(ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ)...........................................................................

ក-អត្តសញ្ញាណនៃអចលនវត្ថុ លេខក្បាលដី ឬលេខប័ណ្ណ :.........................

ទីតាំងដី : ................................................................................

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ :...... ...............................អាសយដ្ឋាន:...................................................... ..................................................................................................។

គ-គោលបំណងនៃការចុះបញ្ជី : .................(ការរឹបអូសកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ)..............................(ទៅលើអចលនវត្ថុចំណុច “ក”)។

ឃ-មូលហេតុ :...............(ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ.......

ចុះថ្ងៃទី........ខែ.........ឆ្នាំ.......... និងឈ្មោះរបស់តុលាការ..........................)។

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត :........................................................

អាសយដ្ឋាន :...............................................................................................

............................................................................................។

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត :............................................................

អាសយដ្ឋាន :...............................................................................................

............................................................................................។

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ.........ចុះថ្ងៃទី

......ខែ......ឆ្នាំ......និងឈ្មោះរបស់តុលាការ .........................................

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

ឧបសម្ព័ន្ធទី ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង................
លេខ.......................

.................,ថ្ងៃទី....ខែ.......ឆ្នាំ.......

## លិខិតផ្អកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ

( ប្រការ ៨ )

យើង.......................ក្រឡាបញ្ជីនៃសាលាដំបូង.................................

សូមជម្រាបជូន
លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី.....(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត )

កម្មវត្ថុ : .............(ផ្អកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ).................................................................

ក-អត្តសញ្ញាណនៃអចលនវត្ថុ លេខក្បាលដី ឬលេខប័ណ្ណ :......................
ទីតាំងដី :.................................................................................

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ :....
.............................................................................................
អាសយដ្ឋាន :.............................................................................
.............................................................................................។

គ-គោលបំណងនៃការចុះបញ្ជី :...................... (លុបការចុះបញ្ជីអំពីការរឹប

អ្នកសកម្មសិទ្ធិ ឬសិទ្ធិផ្លួលអចិន្ត្រៃយ៍ ឬផលុបភោគ)...................................
(ទៅលើអចលនវត្ថុចំណុច "ក")។

ឃ-មូលហេតុ :.............................................................
............................................................................ ។

-(ពាក្យសុំលក់ដោយបង្ខំ ត្រូវបានដកចុះថ្ងៃទី...... ខែ........ ឆ្នាំ...... របស់ឈ្មោះ..................) ឬ

-(ដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.........ចុះថ្ងៃទី.....ខែ...... ឆ្នាំ.......ហើយថ្ងៃទី.......ខែ........ឆ្នាំ........ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ......................)។

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត : ..........................................
អាសយដ្ឋានៈ ..................................................................
............................................................................។

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត :...........................................
អាសយដ្ឋានៈ ..................................................................
............................................................................ ។

ឯកសារភ្ជាប់ជាមួយ :
(ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយ នូវឯកសារពាក់ព័ន្ធ)

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១២

សាលាដំបូង.................
លេខ.....................

...............,ថ្ងៃទី....ខែ.......ឆ្នាំ.......

## លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន
( ប្រការ ១៦ )

យើង........................ក្រឡាបញ្ជីនៃសាលាដំបូង.................................

សូមជម្រាបជូន
លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង
សុរិយោដី.......(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត )

កម្មវត្ថុ : .............(ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ ឬ សិទ្ធិជួល អចិន្ត្រៃយ៍ ឬ ផលុបភោគ.........)............................................។

ក-អត្តសញ្ញាណនៃអចលនវត្ថុ លេខក្បាលដី ឬ លេខប័ណ្ណៈ....................................
ទីតាំងដី : ...........................................................................................
.......................................................។

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគី នៃអចលនវត្ថុ ..................
អាសយដ្ឋាន :...........................................................................................
.........................................................................................។

គ-គោលបំណងនៃការចុះបញ្ជី :............(ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) ...........................................................
.................................(ទៅលើអចលនវត្ថុចំណុច "ក"

ឃ-មូលហេតុ :.............(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ.......ចុះថ្ងៃទី........
ខែ......ឆ្នាំ........និងឈ្មោះរបស់តុលាការ...........................)

ង-ឈ្មោះម្ចាស់បំណុល :.................................................................

អាសយដ្ឋាន :........................................................................
........................................................................................។

ច-ឈ្មោះកូនបំណុល :.................................................................

អាសយដ្ឋាន :........................................................................
........................................................................................។

ឯកសារភ្ជាប់ជាមួយ :

- ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

ឧបសម្ព័ន្ធទី ១៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង................
លេខ.....................

...............,ថ្ងៃទី....ខែ.......ឆ្នាំ.......

**លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន**
**( ប្រការ ១៧ )**

យើង.........................ក្រឡាបញ្ជីនៃសាលាដំបូង.................................

សូមជម្រាបជូន
លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង
សុរិយោដី........(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត)

**កម្មវត្ថុ :** ............(ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ).................................................។

ក-អត្តសញ្ញាណនៃអចលនវត្ថុ លេខក្បាលដី ឬ លេខប័ណ្ណ:.......................
ទីតាំងដី : ......................................................................
........................................................................។

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ .....
អាសយដ្ឋាន :....................................................................
........................................................................។

គ-គោលបំណងនៃការចុះបញ្ជី:......(លុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នូវកម្មសិទ្ធិ ឬសិទ្ធិសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ)..........(ទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ :...........................................................

-(ការដកពាក្យសុំដីកាវិបអូសជាបណ្ដោះអាសន្ន ឬការដកពាក្យសុំអនុវត្តវិបអូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី ......ខែ......ឆ្នាំ.......) ឬ

-(ដីកាសម្រេចលុបចោលការអនុវត្តការវិបអូសជាបណ្ដោះអាសន្នលេខ.......ចុះថ្ងៃទី .....ខែ......ឆ្នាំ....... ហើយថ្ងៃទី......ខែ.......ឆ្នាំ....... ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ..................................) ។

ង-ឈ្មោះម្ចាស់បំណុល :..........................................................

អាសយដ្ឋាន :..........................................................................

.................................។.........................................................។

ច-ឈ្មោះកូនបំណុល :......................................................

អាសយដ្ឋាន :..........................................................................

..............................................................................................។

**ឯកសារភ្ជាប់ជាមួយ :**

(ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ)

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១៤

# ពាក្យសុំ
## ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត
( ប្រការ ១៨ )

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................ភេទ........អាយុ.........អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ....................ផ្លូវលេខ.........................ភូមិ.............................. ...............ឃុំ សង្កាត់................... ក្រុង ស្រុក ខណ្ឌ.............................. រាជធានី ខេត្ត...........................ជាម្ចាស់បំណុល ។

សូមគោរពជូន
លោក/លោកស្រីប្រធានសាលាដំបូង..........................

កម្មវត្ថុ : ........................(សុំផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត)...................... ។

-សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល : (ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ......ថ្ងៃទី....ខែ....ឆ្នាំ.....របស់តុលាការ..........................) (ប្រសិនបើមាន) ។

-សញ្ញាណរបស់កម្មសិទ្ធិករនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុល និងកូនបំណុលទី ៣ :

.-(ឈ្មោះកម្មសិទ្ធិករ.....................................................)

.-(អាសយដ្ឋាន.......................................................... ..........................................................................)

.-(ឈ្មោះកូនបំណុល.....................................................)

.-(អាសយដ្ឋាន.......................................................)

.-(ឈ្មោះកូនបំណុលទី៣.................................................................)

.-(អាសយដ្ឋាន...........................................................................................

.........................................................................................................................)

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ :

.-(លេខក្បាលដី ឬ លេខប័ណ្ណ.......................................................................)

.-(ទីតាំងដី...............................................................................................

.........................................................................................................................)

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល ដែលត្រូវបានធានា :

.-(ហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំ ....................................)

.-(ថ្ងៃទី.....ខែ.....ឆ្នាំ......នៃការបង្កើតហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំ.............)

.-(មូលហេតុនៃសិទ្ធិលើបំណុលដែលត្រូវបានធានា : (ការលក់ ការខ្ចី កិច្ចសន្យាម៉ៅការ អំពើអនីត្យានុកូល កិច្ចសន្យា..............ចុះថ្ងៃទី........ខែ.......ឆ្នាំ.......)

.-(ចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល.......................................................)

-សញ្ញាណនៃសិទ្ធិលើបំណុលដែលនឹងត្រូវបានការពារ :

.-(មូលហេតុនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) : (ការលក់ ការខ្ចី កិច្ចសន្យាម៉ៅការ អំពើអនីត្យានុកូល កិច្ចសន្យា..............ចុះថ្ងៃទី........ខែ.......ឆ្នាំ.......)

.-(ចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល.......................................................)

ធ្វើនៅរាជធានី ខេត្ត,.............,ថ្ងៃទី......ខែ........ឆ្នាំ.........

ហត្ថលេខា/ ស្នាមមេដៃ

ឈ្មោះម្ចាស់បំណុល

ឧបសម្ព័ន្ធទី ១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង................
លេខ......................

................,ថ្ងៃទី....ខែ.......ឆ្នាំ.......

## លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

( ប្រការ ១៨ )

យើង...........................ក្រឡាបញ្ជីនៃសាលាដំបូង...................................

សូមជម្រាបជូន
លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង
សុរិយោដី.............(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត )

កម្មវត្ថុ : ................(ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)..............................។

ក-អត្តសញ្ញាណនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត :

-(លេខក្បាលដី ឬ លេខប័ណ្ណ................................................... )

-(ទីតាំងដី ........................................................................
..............................................................................)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ ....
អាសយដ្ឋាន :..........................................................................
..........................................................................

គ-គោលបំណងនៃការចុះបញ្ជី : ....(ការរឹបអូសជាបណ្ដោះអាសន្ននូវសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត).............(ទៅលើអចលនវត្ថុ

បំណុច“ក”)

ឃ-មូលហេតុ : ....(ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នសិទ្ធិលើបំណុលលេខ.... ចុះថ្ងៃទី.....ខែ.........ឆ្នាំ.......... ហើយថ្ងៃទី.....ខែ......ឆ្នាំ....... ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ............................) ។

ង-ឈ្មោះម្ចាស់បំណុល :....................................................

អាសយដ្ឋាន :..................................................................។

ច-ឈ្មោះកូនបំណុល :....................................................

អាសយដ្ឋាន :..................................................................។

ឆ-ឈ្មោះកូនបំណុលទី៣ :....................................................

អាសយដ្ឋាន :..................................................................។

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា :

-(ហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំ ........................)

-(ថ្ងៃទី....ខែ.......ឆ្នាំ........នៃការបង្កើតហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំ)

-(មូលហេតុនៃសិទ្ធិលើបំណុលដែលត្រូវបានធានា):.............(ការលក់ ការខ្ចី កិច្ចសន្យា ម៉ៅការ អំពើអនីត្យានុកូល កិច្ចសន្យា...............ចុះថ្ងៃទី.....ខែ.....ឆ្នាំ...... )

-(ចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល ..........................................)

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីអំពីកាលបរិច្ឆេទដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានអានុភាព

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុល ដែលមានសេចក្ដីបញ្ជាក់ថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

ឧបសម្ព័ន្ធទី ១៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង................
លេខ......................

...............,ថ្ងៃទី....ខែ.......ឆ្នាំ.......

## លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត

( ប្រការ ១៩ )

យើង........................ក្រឡាបញ្ជីនៃសាលាដំបូង.................................

សូមជម្រាបជូន

លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី...........(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត )

កម្មវត្ថុ:..........(ការផ្ទុកផ្តាក់ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត).........................។

ក-អត្តសញ្ញាណនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត លេខក្បាលដី ឬលេខប័ណ្ណ:........................................................។
ទីតាំងដី :...................................................................
.................................................................។

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគី នៃអចលនវត្ថុ............
អាសយដ្ឋាន :..............................................................
............................................................................ ។

គ-គោលបំណងនៃការចុះបញ្ជី :..........(លុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត)..............................(ទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ : ..............................................................

-(ការដកពាក្យសុំចេញដីកាសំរេចរឹបអូសជាបណ្តោះអាសន្ន សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតនៅថ្ងៃទី....ខែ.......ឆ្នាំ..........) ឬ

-(ការដកពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្ន សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតនៅថ្ងៃទី....ខែ.....ឆ្នាំ......) ឬ

-(ដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតលេខ......ចុះថ្ងៃទី.....ខែ....ឆ្នាំ......ដែលមានអានុភាពនៅថ្ងៃទី.....ខែ.....ឆ្នាំ..... និងឈ្មោះរបស់តុលាការ....................)។

ង-ឈ្មោះម្ចាស់បំណុល : ..................................................................

អាសយដ្ឋាន :..................................................................................

.............................................................................................។

ច-ឈ្មោះកូនបំណុល : ..................................................................

អាសយដ្ឋាន :..................................................................................

.............................................................................................។

ឆ-ឈ្មោះកូនបំណុលទី៣ :..................................................................

អាសយដ្ឋាន :..................................................................................

.............................................................................................។

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគនិងសិទ្ធិលើបំណុលដែលត្រូវធានា :

-(ហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំ ...................................................)

-(ថ្ងៃទី ខែ ឆ្នាំ នៃការបង្កើតហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំ..........................)

-(មូលហេតុនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) : (ការលក់ ការខ្ចី កិច្ចសន្យាម៉ៅការ អំពើអនីត្យានុកូល កិច្ចសន្យា..............ចុះថ្ងៃទី........ខែ.......ឆ្នាំ.......)

-(ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល...................................................)

ឯកសារភ្ជាប់ជាមួយ :

(ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ)

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

# ឧបសម្ព័ន្ធទី៥

# លិខិតផ្ទុកផ្តាក់

⑤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## ទម្រង់គំរូ[25]

លិខិតលេខ...........

**យើង...............ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ**

**លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[26]**

**សូមជម្រាបជូន**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល**

**កម្មវត្ថុ៖** សំណើសុំចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ដូចមានបញ្ជាក់ខាងក្រោម៖

**ក.សញ្ញាណនៃអចលនវត្ថុ៖** អចលនវត្ថុដែលបានទីតាំងស្ថិតនៅភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៦០៣-១២០៦ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **(L2)**។

**ខ. ឈ្មោះកម្មសិទ្ធិករនៃអចលនវត្ថុ៖** ឈ្មោះ **B** មានអាសយដ្ឋាននៅ.........................................

**គ. គោលបំណងនៃការចុះបញ្ជី៖** រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដូចមានកំណត់ក្នុងចំណុច «ក» នៃលិខិតនេះ។

**ឃ. មូលហេតុ៖** ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

**ង. ម្ចាស់បំណុលនៃការអនុវត្ត៖** ឈ្មោះ **A** មានអាសយដ្ឋាននៅ...............................................

**ច. កូនបំណុលនៃការអនុវត្ត៖** ឈ្មោះ **B** មានអាសយដ្ឋាននៅ...............................................

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្របសម្រួលតាមនីតិវិធីច្បាប់។

សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

<u>ឯកសារភ្ជាប់</u>

ឯកសារចម្លងយថាកូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានី «ច្បាប់ដើម»

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

---

[25] ទម្រង់គំរូនេះ គាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីខ្លឹមសារនៃលិខិតផ្ទុកផ្តាក់។

[26] មាត្រា ៥៦៤, ៥៦៧, ៤២០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រការ១៦ ឧបសម្ព័ន្ធទី១២ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

# ឧបសម្ព័ន្ធទី៦
# ឯកសារចម្លងនៃសេចក្តី
# បញ្ជាក់ចុះបញ្ជីអំពីការរើប
# អូសជាបណ្តោះអាសន្ន

⑥

# ឯកសារចម្លងនៃសេចក្តីបញ្ជាក់ចុះបញ្ជីអំពីការរើបអូសជាបណ្តោះអាសន្ន

| | | | | |
|---|---|---|---|---|
| រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ផ្លូវ |
| លេខក្បាលដី | សន្លឹកផែនទី | មធ្យោបាយធ្វើអត្តសញ្ញាណកម្មក្បាលដី | | ទំហំដី |
| ប្រភេទដី | រូបភាពប្រើប្រាស់ដី | លក្ខណៈនៃការប្រើប្រាស់ដី | | អក្ខរសញ្ញា |
| ឈ្មោះកម្មសិទ្ធិករ | | | | |

| អត្រានុកូលដ្ឋានម្ចាស់អចលនវត្ថុ | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| នាមត្រកូលនិងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត | សារតោ | លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រម តុលាការ | បន្ទុកលើអចលនវត្ថុ | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| B<br>( លីវ ) | ១០.១០.១៩៨០<br>សង្កាត់ផ្សារថ្មីទី ៣ | ឪ៖ Z<br>ម៖ W | | ១. ត្រូវបានរឹបអូសជាបណ្តោះអាសន្នកម្មសិទ្ធិ ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ[27]<br>២.................... | |

[27] ប្រការ ៣២ ចំណុច «ក» នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

# ឧបសម្ព័ន្ធទី៧

# ប្រកាសស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការទោរអោជ្ញាសាលា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❖❖⚖❖❖

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ៣០.តបយក/០៧

# ប្រកាស

## ស្តីពី

## មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

*********

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញសេចក្តីបង្គាប់លេខ ១១៧ សរ.រវ.៩៧ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និង សេចក្តីសំរេចផ្សេងៗរបស់តុលាការ
- យោងតាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## ស ម្រេ ច

**ប្រការ ១** ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

១- ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង នៃសាលាដំបូង ត្រូវអនុវត្តកិច្ចការរបស់

អាជ្ញាសាលា ក្នុងនាមជា"មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា" នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីអាជ្ញាសាលា ។

២-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវអនុវត្តកិច្ចការខាងក្រោមនេះ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម :

ក-កិច្ចការដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀតថា ត្រូវចាត់ចែងដោយអាជ្ញាសាលា ។

ខ-កិច្ចការពាក់ព័ន្ធនឹងការរក្សា ការគ្រប់គ្រងវត្ថុ ឬ សកម្មភាពផ្សេងទៀតដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថា ត្រូវចាត់ចែងដោយអាជ្ញាសាលា ។

**ប្រការ ២** អ្នកអនុវត្តកិច្ចការជំនួស អ្នកជំនួយក្នុងការអនុវត្តកិច្ចការ ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវអនុវត្តកិច្ចការដោយខ្លួនឯង ។ ប៉ុន្តែក្នុងករណីដែលប្រតិបត្តិការបញ្ជូន ដោយយោងតាមកថាខណ្ឌទី ៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយរន្ធានុសិទ្ធិ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមានមូលហេតុពិសេសដែលមិនអាចអនុវត្តកិច្ចការនោះដោយខ្លួនឯង មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចឱ្យអ្នកអនុវត្តកិច្ចការជំនួស អនុវត្តកិច្ចការនោះជំនួសខ្លួន ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

២-ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចប្រើអ្នកបច្ចេកទេស ឬ កម្មករបាន ។

៣-ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចប្រើអ្នកជំនួយក្នុងការអនុវត្តកិច្ចការ ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

៤-ប្រធានសាលាដំបូង អាចលុបចោលនូវការអនុញ្ញាតដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៅពេលណាក៏បានដែរ ។

**ប្រការ ៣** ជំនួយក្នុងការអនុវត្តកិច្ចការ

១-ប្រសិនបើមានការលំបាកពិសេស ក្នុងការអនុវត្តកិច្ចការដោយឯកឯង ឬ មាន



5

ការចាំបាច់ពិសេសផ្សេងទៀត ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចស្នើសុំជំនួយពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាផ្សេងទៀត ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

២-ប្រសិនបើមិនអាចទទួលជាមុននូវការអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយសារមានភាពចាំបាច់បន្ទាន់ចំពោះរឿងក្តី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវទទួលការអនុញ្ញាតនោះភ្លាម ក្រោយការស្នើសុំជំនួយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានីមួយៗ អាចទទួលការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ក្នុងការអនុវត្តកិច្ចការ ។

**ប្រការ ៤** ការរក្សាទុកនូវប្រាក់ដែលបានទទួលតាមកិច្ចការ ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវប្រគល់ប្រាក់ ឬ វត្ថុផ្សេងទៀតដែលខ្លួនបានរឹបអូស ឬ បានទទួលការប្រគល់ តាមការអនុវត្តកិច្ចការរបស់ខ្លួន ទៅអ្នកដែលត្រូវទទួលប្រាក់ ឬ វត្ថុនោះភ្លាម ឬ សាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ត្រូវរក្សាទុកនូវប្រាក់ ឬ វត្ថុនោះ លើកលែងតែករណីដែលត្រូវតម្កល់ ឬ ករណីផ្សេងទៀតដែលច្បាប់បានកំណត់ ។

២-នៅពេលដែលទទួលប្រាក់ ឬ វត្ថុផ្សេងទៀតពីភាគី ឬ បុគ្គលផ្សេងទៀត តាមការអនុវត្តកិច្ចការរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចេញលិខិតបញ្ជាក់ការទទួល (បង្កាន់ដៃ) ហើយត្រូវតក់ត្រាឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ ឬ ប្រភេទ និង ចំនួននៃវត្ថុដែលខ្លួនបានទទួល និង ថ្ងៃ ខែ ឆ្នាំទទួល នៅក្នុងសំណុំរឿង ។

**ប្រការ ៥** ការចាត់ចែងកិច្ចការ

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ តាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះកិច្ចការដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់ ក្នុងនាមជាកិច្ចការដែលជាផ្នែកមួយនៃនីតិវិធីនៃរឿងក្តីដែលតុលាការនោះកំពុងចាត់ការ ។

២-ការបែងចែកកិច្ចការរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវកំណត់ដោយ

ដីកាសម្រេចរបស់ប្រធានតុលាការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះបំពេញការងារ ។ ប៉ុន្តែ ចំពោះកិច្ចការដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថា ត្រូវចាត់ចែងដោយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាជាកំណត់ណាម្នាក់ ក្នុងចំណោមកិច្ចការដែលបានកំណត់នៅក្នុងចំណុច ខ កថាខណ្ឌទី ២ នៃប្រការ ១ (មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា) មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ត្រូវចាត់ចែងកិច្ចការនោះ ។

## ប្រការ ៦ ការដកហូត

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួនក្នុងករណីដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនោះ :

ក-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឬ សហព័ទ្ធរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ជាភាគី ឬ មានទំនាក់ទំនងនៃសិទ្ធិរួម ឬ កាតព្វកិច្ចរួមជាមួយនឹងភាគី ។

ខ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬ ញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) ឬ ញាតិដែលរស់នៅជាមួយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ។

គ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាអ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

ឃ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាអ្នកតំណាងរបស់ភាគីចំពោះកិច្ចការដែលខ្លួនត្រូវចាត់ចែង ។

២-ភាគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានរួមទាំងជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ ។

## ប្រការ ៧ ឧបាស្រ័យ

ចំពោះពាក្យសុំឧបាស្រ័យចំពោះការគណនាសោហ៊ុយ ឬ ការចាត់ចែងផ្សេងទៀតរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាស្តីពីកិច្ចការដែលត្រូវបានចាត់ចែង តាមពាក្យសុំ ឬ ចំពោះពាក្យសុំឧបាស្រ័យចំពោះការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងកិច្ចការទាំងនោះ ត្រូវអនុលោមតាមករណីនៃការតវ៉ាចំពោះការអនុវត្តដែលបានកំណត់



5

នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៤៤ (ការតវ៉ាចំពោះការអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែករណីដែលមានបញ្ញត្តិពិសេស នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

ប្រការ ៨ របៀបដាក់ពាក្យសុំ

១-ពាក្យសុំចំពោះមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវធ្វើដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរបញ្ជាក់ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង ព្រមទាំងខ្លឹមសារនៃចំណុចដែលសុំនោះ ។

២-ក្នុងករណីដែលពាក្យសុំត្រូវបានដាក់ដោយអ្នកតំណាង ត្រូវភ្ជាប់លិខិតបញ្ជាក់សិទ្ធិតំណាង ជាមួយនឹងពាក្យសុំ ។

ប្រការ ៩ លំដាប់នៃការចាត់ចែងកិច្ចការ

មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ តាមលំដាប់ដែលខ្លួនបានទទួល លើកលែងតែករណីដែលមានស្ថានភាពពិសេស ។

ប្រការ ១០ ម៉ោងធ្វើការ និង ការចាត់ចែងកិច្ចការក្រៅម៉ោងធ្វើការ

១-ម៉ោងធ្វើការរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺចាប់ពីម៉ោងប្រាំពីរព្រឹក ដល់ម៉ោងប្រាំល្ងាច ។

២-ប្រសិនបើមានភាពចាំបាច់បន្ទាន់ ឬ ភាពចាំបាច់ពិសេសផ្សេងទៀត មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ ទោះជាក្រៅម៉ោងធ្វើការក៏ដោយ ។

ប្រការ ១១ ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ

នៅពេលបំពេញមុខនាទីរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ ។

ប្រការ ១២ ចំណុចត្រូវសរសេរនៅក្នុងកំណត់ហេតុ 5

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួន ។

២-នៅក្នុងកំណត់ហេតុដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ ហើយត្រូវសរសេរឈ្មោះ និង ចុះហត្ថលេខា :

ក-សញ្ញាណរឿងក្តី ។

ខ-ពេលវេលា និង ទីកន្លែងដែលបំពេញមុខនាទី ។

គ-ខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង។

ឃ-ថ្ងៃ ខែ ឆ្នាំ ដែលធ្វើកំណត់ហេតុ ។

**ប្រការ ១៣** ពន្ធដាក់ពាក្យសុំ

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ។

២-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ ទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ។

**ប្រការ ១៤** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

១-អ្នកដាក់ពាក្យសុំ ត្រូវទទួលបន្ទុកក្នុងការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំនេះ ។

២-ចំពោះសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់ តុលាការត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។

៣-សោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មានដូចតទៅ :

ក-សោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅ សម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ។

ខ-សោហ៊ុយសម្រាប់ការផ្ញើឯកសារ ទូរស័ព្ទ និង ទូរសារ ជាអាទិ៍ ។ ៤

គ-សោហ៊ុយសម្រាប់ការជូនដំណឹងជាសាធារណៈ ។

ឃ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់អ្នកសង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ (អ្នកសង្កេតការណ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ង-កម្រៃសម្រាប់អ្នកបច្ចេកទេស ឬ កម្មករ ។

ច-សោហ៊ុយសម្រាប់ការដឹកជញ្ជូន ថែរក្សា និង គ្រប់គ្រងវត្ថុ ។

ឆ-សោហ៊ុយសម្រាប់ការប្រមូលផល ។

ជ-សោហ៊ុយសម្រាប់ការទទួលលិខិតបញ្ជាក់ពីស្ថាប័នសាធារណៈ ។

ឈ-សោហ៊ុយសម្រាប់ថត និង ផ្តិតរូបថត ដើម្បីថតស្ថានភាពបច្ចុប្បន្ននៃវត្ថុ ។

ញ-សោហ៊ុយសម្រាប់ការធ្វើលិខិតបញ្ជាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៩ នៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សោហ៊ុយស្នាក់នៅ និង កម្រៃសម្រាប់អ្នកវាយតម្លៃ ។

ឋ-សោហ៊ុយធ្វើលិខិតរាយការណ៍ដែលត្រូវដាក់ជូនទៅតុលាការអនុវត្ត ។

ឌ-សោហ៊ុយចាំបាច់សម្រាប់ការលក់តាមវិធីផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៤-ចំពោះការគណនាចំនួននៃសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅដែលបានកំណត់នៅក្នុងចំណុច ក នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវអនុលោមទៅតាមករណីនៃក្រឡាបញ្ជី ។

**ប្រការ ១៥** ការបង់សោហ៊ុយជាមុន

១-ចំពោះកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំ សាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម អាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននូវសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការនោះ តាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកដាក់ពាក្យសុំនោះ បានទទួលការសង្គ្រោះលើបណ្តឹង ។

5

២-ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបង់ជាមុននូវចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាអាចលើកចោលពាក្យសុំនោះបាន ។

**ប្រការ ១៦** បញ្ញត្តិពិសេសក្នុងករណីនៃពាក្យសុំដោយអ្នកដែលបានទទួលការសង្គ្រោះលើបណ្ដឹង

ក្នុងចំណោមសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការអនុវត្តដោយបង្ខំដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំរបស់អ្នកដែលបានទទួលការសង្គ្រោះលើបណ្ដឹង ប្រសិនបើមានសោហ៊ុយខ្លះដែលមិនអាចប្រមូលពីកូនបំណុលនៃការអនុវត្ត រដ្ឋត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។

**ប្រការ ១៧** អានុភាពនៃប្រកាសនេះ

ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទដែលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ។ ៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

**ចម្លងជូន** :

- តុលាការខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- តុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមតុលាការខេត្ត-ក្រុង
- តុលាការយោធា និង អយ្យការអមតុលាការយោធា
- អគ្គាធិការដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- គណៈមេធាវី
  "ដើម្បីជ្រាប"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៨

# ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

# ព្រះរាជាណាចក្រកម្ពុជា

① 

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទម្រង់គំរូ[1]

## ពាក្យសុំតវ៉ាចំពោះការរក្សាការពារ[2]

ខ្ញុំ T ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់...... ផ្លូវលេខ..........សង្កាត់.................ខណ្ឌ...............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ៖**សំណើសុំតវ៉ានឹងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖សំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

### ក. គោលបំណងនៃការតវ៉ា

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

### ខ. មូលហេតុនៃការស្នើសុំលុបចោល

① នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ៖.......................................... ...........................................................................................................................................។

② នត្ថិភាពនៃភាពចាំបាច់ដែលត្រូវរក្សាការពារ ៖............................................................ ...........................................................................................................................................។

③ សិទ្ធិលើបំណុលរលត់ដោយការសង ឬការលើកលែង (អង្គហេតុតវ៉ា) ៖ (ប្រសិនបើមាន)

...........................................................................................................................................

...........................................................................................................................................។

---

[1] ទម្រង់គំរូនេះ គាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំតវ៉ាចំពោះការរក្សាការពារ។

[2] មាត្រា ៥៣៤ មាត្រា ៥៥៤ និងមាត្រា ៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

ហេតុនេះ សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលបានរលត់ដោយការលើកលែង ឬគ្មានភាពចាំបាច់ដែលត្រូវរក្សាការពារ។[3]

**គ. មូលហេតុនៃការស្នើសុំឱ្យមានអានុភាពអនុវត្តភ្លាមៗ**

① អត្ថិភាពនៃមូលហេតុគតិយុត្តច្បាស់លាស់នៃការលុបចោល ៖.........................................
..........................................................................................................................។

② អត្ថិភាពនៃភស្តុតាងច្បាស់លាស់គាំទ្រមូលហេតុនៃការលុបចោល ៖..................................
..........................................................................................................................។

③ ការខូចខាតរបស់កូនបំណុលនឹងមិនអាចធ្វើបដិទានបាន ៖.............................................
..........................................................................................................................។

**ឃ. ភស្តុតាង**

១. លិខិត...................។ (ភស្តុតាង **Y1**)

២. រូបថតសន្លឹក................។ (ភស្តុតាង **Y2**)

៣. ខ្សែអាត់វីដេអូ.............។ (ភស្តុតាង **Y3**)

**ខ. ឯកសារភ្ជាប់**

១. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

២. លិខិតថតចម្លងនៃភស្តុតាងនីមួយៗខាងលើចំនួន ០២ (ពីរ) ច្បាប់

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០

**អ្នកតំណាងដោយអាណត្តិ**

[3] ការបញ្ជាក់អំពីលក្ខណៈគតិយុត្តនៃការទាមទារឱ្យបានច្បាស់លាស់ ដើម្បីកំណត់អំពីគោលបំណងនៃពាក្យសុំរបស់កូនបំណុល ថាកូនបំណុលទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ផ្អែកលើមូលហេតុអ្វី ដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងកំណត់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

# ឧបសម្ព័ន្ធ
# បញ្ជីភាគី

**ម្ចាស់បំណុល៖**

ឈ្មោះ **A** អាសយដ្ឋាន.....................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **P** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់...... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី..................................................................................។

**កូនបំណុល៖**

ឈ្មោះ **B** អាសយដ្ឋាន.....................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **T** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់..... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី..................................................................................។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

②

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

## ទម្រង់គំរូ[4]
## កំណាត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល

(មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

ម៉ោងប្រាំបួនព្រឹក ថ្ងៃទីដប់មួយ ខែឧសភា ឆ្នាំពីរពាន់ម្ភៃ នៅសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រម** ៖ លោក **J** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី** ៖ លោក **C** ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ម្ចាស់បំណុល** ៖ ឈ្មោះ **A** អាសយដ្ឋាន.................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **P** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល** ៖ ឈ្មោះ **B** អាសយដ្ឋាន.................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **T** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ**

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**ខ្លឹមសារនៃការសាកសួរ**

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

..........................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

[4] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពី ខ្លឹមសារនៃការធ្វើកំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុលដែលជាកិច្ចនីតិវិធីត្រូវបំពេញដោយតុលាការ មុនពេលចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

.................................................................................................................................

៣. តើកូនបំណុល B មានភស្តុតាងអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ ?

.................................................................................................................................

៤. តើម្ចាស់បំណុល A យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ B ?

.................................................................................................................................

៥. តើម្ចាស់បំណុល A មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ ?

.................................................................................................................................

បញ្ឈប់កំណត់ហេតុនេះ នៅម៉ោងដប់មួយ នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យគូភាគីស្តាប់ និងគូភាគីបានឆ្លើយថា ត្រឹមត្រូវហើយ ហើយបានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើកំណត់ហេតុនេះ ផងដែរ។

**កូនបំណុល** **អ្នកតំណាងដោយអាណត្តិ (កូនបំណុល)**

**ម្ចាស់បំណុល** **អ្នកតំណាងដោយអាណត្តិ (ម្ចាស់បំណុល)**

**ក្រឡាបញ្ជី** **ចៅក្រម**


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០
ដីកាសម្រេចលេខ ២៣ «ខ» ជ.រ
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០

**ទម្រង់គំរូ**[5]

**ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ**[6]

**យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញមាត្រា ៥៥០ មាត្រា ៥៥២ និងមាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០១-០៥-២០២០

**ម្ចាស់បំណុល៖** ឈ្មោះ A អាសយដ្ឋាន........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល៖** ឈ្មោះ B អាសយដ្ឋាន..........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ T ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**ក.សេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** លេខ២១«ខ» ជ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ

១. រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធនៃវត្ថុ។

២. កូនបំណុលត្រូវផ្ញើប្រាក់រំដោះចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) ដុល្លារអាមេរិក ដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

[5] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទាក់ទងនឹងចំណុចនៃសេចក្តីសម្រេចបញ្ចប់។

[6] ទម្រង់នៃដីកាសម្រេចនេះមានលក្ខណៈជាឧបាស្រ័យ បើឧបាស្រ័យទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ ត្រូវប្រើលំនាំតាមដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ បើទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី៣ ត្រូវប្រើលំនាំដីកាសម្រេចរក្សាការពារប្រភេទទី៣ ផ្អែកតាមមាត្រា ៥៣៩ មាត្រា ២១៦ និងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

**ខ.គោលបំណងនៃការតវ៉ារបស់កូនបំណុល**

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**គ.កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល** ចុះថ្ងៃទី១១-០៥-២០២០

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

..................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

..................................................................................................................................

**៣.** តើកូនបំណុល **B** មានភស្ដុតាងអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ?

..................................................................................................................................

**៤.** តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B**?

..................................................................................................................................

**៥.** តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្ដុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ?

..................................................................................................................................

## សំអាងហេតុ

ផ្អែកតាមភស្ដុតាង **$Y_1$** តុលាការទទួលស្គាល់ថា កូនបំណុលបានសងប្រាក់កម្ចីទៅម្ចាស់បំណុលមួយផ្នែកចំនួន ................. (...........) ដុល្លារអាមេរិក ។

ផ្អែកតាមភស្ដុតាង **$Y_2$** តុលាការទទួលស្គាល់ការអះអាងរបស់កូនបំណុល ដែលបានលើកឡើងថាម្ចាស់បំណុលបានលើកលែងបំណុលដែលនៅសល់ចំនួន........... (............) ដុល្លារអេមរិក។

ផ្អែកតាមភស្ដុតាង **$Y_3$** តុលាការទទួលស្គាល់ថា កូនបំណុលនឹងក្ស័យធន បើបន្តអត្ថិភាពនៃការអនុវត្តរក្សាការពារ ហើយមូលហេតុនៃការស្នើសុំលុបចោលដីកាសម្រេចដើមរបស់កូនបំណុលមានភាពត្រឹមត្រូវតាមច្បាប់ ផ្អែកតាមមាត្រា .......នៃក្រមរដ្ឋប្បវេណី និងមានភស្ដុតាងបញ្ជាក់អង្គហេតុជាមូលហេតុនៃការលុបចោលនេះច្បាស់លាស់។

នៅក្នុងរឿងក្ដីនេះ ដោយសារម្ចាស់បំណុលចាញ់ក្ដីទាំងស្រុង ហេតុនេះ បន្ទុកនៃប្រាក់ប្រដាប់ក្ដីជារបស់ម្ចាស់បំណុល (មាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

## សេចក្តីសម្រេចបញ្ចប់

១. លុបចោលដីកាសម្រេចរើបអូសជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

ដីកាសម្រេចនេះ អាចប្តឹងជំទាស់បានតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

④

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទម្រង់គំរូ[7]

## ពាក្យសុំតវ៉ាចំពោះការរក្សាការពារ[8]

ខ្ញុំ T ជាមេធាវីនៃក្រុមមេធាវី...................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់...... ផ្លូវលេខ.........សង្កាត់.................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ...............។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ៖** សំណើសុំតវ៉ានឹងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖សំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

### ក. គោលបំណងនៃការតវ៉ា

១. លុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

### ខ. មូលហេតុនៃស្នើសុំលុបចោល

① នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ៖.......................................
...........................................................................................................................។

② នត្ថិភាពនៃភាពចាំបាច់ដែលត្រូវរក្សាការពារ ៖..........................................................
...........................................................................................................................។

③ សិទ្ធិលើបំណុលរលត់ដោយការសង ឬការលើកលែង (អង្គហេតុតវ៉ា) ៖ (ប្រសិនបើមាន)

...........................................................................................................................
...........................................................................................................................។

[7] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំតវ៉ាចំពោះការរក្សាការពារដែលដីកាសម្រេចដើមជាដីកាសម្រេចរក្សាការពារប្រភេទទី៣ (ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយកំណត់ឋានៈជាបណ្ដោះអាសន្ន)។

[8] មាត្រា ៥៣៤ មាត្រា ៥៥៤ និងមាត្រា ៥៥ ៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

ហេតុនេះ សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលបានរលត់ដោយការសង ឬគ្មានភាពចាំបាច់ដែលត្រូវរក្សាការពារ។[9]

**គ. មូលហេតុនៃការស្នើសុំឱ្យមានអានុភាពអនុវត្តភ្លាមៗ**

① អត្ថិភាពនៃមូលហេតុគតិយុត្តច្បាស់លាស់នៃការលុបចោល ៖..........................................
...........................................................................................................................។

② អត្ថិភាពនៃភស្តុតាងច្បាស់លាស់គាំទ្រមូលហេតុនៃការលុបចោល ៖..................................
...........................................................................................................................។

③ ការខូចខាតរបស់កូនបំណុលនឹងមិនអាចធ្វើបដិទានបាន ៖............................................
...........................................................................................................................។

**ឃ. ភស្តុតាង**

១. លិខិត...................។ (ភស្តុតាង **$Y_1$**)

២. រូបថតសន្លឹក...............។ (ភស្តុតាង **$Y_2$**)

៣. ខ្សែអាត់វីដេអូ............។ (ភស្តុតាង **$Y_3$**)

**ង. ឯកសារភ្ជាប់**

១. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

២. លិខិតថតចម្លងនៃភស្តុតាងនីមួយៗខាងលើចំនួន ០២ (ពីរ) ច្បាប់

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១

**អ្នកតំណាងដោយអាណត្តិ**

[9] ការបញ្ជាក់អំពីលក្ខណៈគតិយុត្តនៃការទាមទារឱ្យបានច្បាស់លាស់ ដើម្បីកំណត់អំពីគោលបំណងនៃពាក្យសុំរបស់កូនបំណុល ថាកូនបំណុលទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ផ្អែកលើមូលហេតុអ្វី ដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងកំណត់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិកាគទានច្បាប់

# ឧបសម្ព័ន្ធ
# បញ្ជីនាគី

**ម្ចាស់បំណុល៖**

ឈ្មោះ **A** អាសយដ្ឋាន..........................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **P** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់...... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី.........................................................................................។

**កូនបំណុល៖**

ឈ្មោះ **B** អាសយដ្ឋាន..........................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **T** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់..... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី.........................................................................................។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

⑤

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

## ទម្រង់គំរូ[10]

## កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល

(មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

ម៉ោងប្រាំបួនព្រឹក ថ្ងៃទីដប់ប្រាំបី ខែឧសភា ឆ្នាំពីរពាន់ម្ភៃមួយ នៅសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រម** ៖ លោក **J** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី** ៖ លោក **C** ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ម្ចាស់បំណុល** ៖ ឈ្មោះ **A** អាសយដ្ឋាន...............................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **P** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល** ៖ ឈ្មោះ **B** អាសយដ្ឋាន...............................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **T** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ**

១. លុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**ខ្លឹមសារនៃការសួរ**

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

..........................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

[10] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពី ខ្លឹមសារនៃការធ្វើកំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុលដែលជាកិច្ចនីតិវិធីត្រូវបំពេញដោយតុលាការ មុនពេលចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

.......................................................................................................................

៣. តើកូនបំណុល **B** មានភស្តុតាងថ្មីអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ?

.......................................................................................................................

៤. តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B**?

.......................................................................................................................

៥. តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ?

.......................................................................................................................

បញ្ឈប់កំណត់ហេតុនេះ នៅម៉ោងដប់មួយ នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យគូភាគីស្តាប់ និងគូភាគីបានឆ្លើយថា ត្រឹមត្រូវហើយ ហើយបានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើកំណត់ហេតុនេះ ផងដែរ។

**កូនបំណុល** **អ្នកតំណាងដោយអាណត្តិ (កូនបំណុល)**

**ម្ចាស់បំណុល** **អ្នកតំណាងដោយអាណត្តិ (ម្ចាស់បំណុល)**

**ក្រឡាបញ្ជី** **ចៅក្រម**


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

⑥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១
ដីកាសម្រេចលេខ ២៣ «ខ» ដ.រ
ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១

## ទម្រង់គំរូ[11]
## ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ[12]
## យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញមាត្រា ៥៥០ មាត្រា ៥៥២ និងមាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី១១-០៥-២០២១

**ម្ចាស់បំណុល៖** ឈ្មោះ A អាសយដ្ឋាន..................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល៖** ឈ្មោះ B អាសយដ្ឋាន..................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ T ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅ អគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**ក.ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន** លេខ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ

១. កំណត់ថាម្ចាស់បំណុលមានសិទ្ធិទាមទារប្រាក់ពីកូនបំណុលជាបណ្ដោះអាសន្ន។

២. បង្គាប់ឱ្យកូនបំណុលបង់ប្រាក់ជាបណ្ដោះអាសន្នចំនួន **$ 400** (បួនរយ) ដុល្លារអាមេរិក ត្រឹមថ្ងៃទី ០៥ ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់គ្រប់ចំនួន **$ 8,000** (ប្រាំបីពាន់) ដុល្លារអាមេរិក ទៅឱ្យម្ចាស់បំណុល។

៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

[11] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទាក់ទងនឹងចំណុចនៃសេចក្ដីសម្រេចបញ្ចប់។

[12] ទម្រង់នៃដីកាសម្រេចនេះមានលក្ខណៈជាឧបាស្រ័យ បើឧបាស្រ័យទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ ត្រូវប្រើលំនាំតាមដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ បើទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី៣ ត្រូវប្រើលំនាំដីកាសម្រេចរក្សាការពារប្រភេទទី៣ ផ្អែកតាមមាត្រា ៥៣៩ មាត្រា ២១៦ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

## ខ.ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ម្ចាស់បំណុលទាមទារឱ្យកូនបំណុលបង់ប្រាក់ជាបណ្តោះអាសន្នចំនួន **$ 400** (បួនរយ) ដុល្លារអាមេរិក ត្រឹមថ្ងៃទី០៥ ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់គ្រប់ចំនួន **$8,000** (ប្រាំបីពាន់) ដុល្លារអាមេរិក ឱ្យម្ចាស់បំណុល ហៅកាត់ថា «ការបង់ប្រាក់ជាបណ្តោះអាសន្ននៃរឿងក្តីនេះ» ដោយមូលហេតុការរំលោយកិច្ចសន្យាការងាររបស់កូនបំណុលបំពានសិទ្ធិរបស់ម្ចាស់បំណុល។

## គ.ចំណុចវិវាទ

១.តើម្ចាស់បំណុលបានលួចប្រាក់ និងគៃបំបាត់ប្រាក់កូនបំណុល?

២.តើម្ចាស់បំណុលមានភាពចាំបាច់ ដែលត្រូវឱ្យកូនបំណុលធ្វើការបង់ប្រាក់ជាបណ្តោះអាសន្ននៃរឿងក្តីនេះឬទេ?

## ឃ.គោលបំណងនៃការតវ៉ា

១. លុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

## ង.កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល ចុះថ្ងៃទី១៨-០៥-២០២១

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

....................................................................................................................................

....................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

....................................................................................................................................

....................................................................................................................................

**៣.** តើកូនបំណុល **B** មានភស្តុតាងថ្មីអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ?

....................................................................................................................................

....................................................................................................................................

**៤.** តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B**?

....................................................................................................................................

**៥.** តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ?

....................................................................................................................................


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

## សំអាងហេតុ

ផ្អែកតាមភស្តុតាង Y1 តុលាការមិនអាចទទួលស្គាល់ថា ម្ចាស់បំណុលបានតែបំបាត់ប្រាក់ក្រុមហ៊ុនកូនបំណុលនោះទេ។

ផ្អែកតាមភស្តុតាង Y2 តុលាការមិនអាចទទួលស្គាល់ការអះអាងរបស់កូនបំណុល ដែលបានលើកឡើងថា ម្ចាស់បំណុលបានទទួលប្រាក់ចំនួន........... (............) ដុល្លារអាមេរិក ដោយចាត់ទុកជាប្រាក់បញ្ចប់វិវាទរវាងម្ចាស់បំណុល និងកូនបំណុលនោះទេ។

ផ្អែកតាមភស្តុតាង Y3 តុលាការមិនអាចទទួលស្គាល់ថា កូនបំណុលនឹងក្ស័យធន បើបន្តអត្ថិភាពនៃការអនុវត្តរក្សាការពារ ហើយមូលហេតុនៃការស្នើសុំលុបចោលដីកាសម្រេចដើមរបស់កូនបំណុលមានភាពមិនត្រឹមត្រូវតាមច្បាប់ ផ្អែកតាមមាត្រា .......នៃក្រមរដ្ឋប្បវេណី និងគ្មានភស្តុតាងបញ្ជាក់អង្គហេតុជាមូលហេតុនៃការលុបចោលនេះឡើយ។

នៅក្នុងរឿងក្តីនេះ ដោយសារកូនបំណុលចាញ់ក្តីទាំងស្រុង ហេតុនេះ បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់កូនបំណុល (មាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. ទទួលស្គាល់ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

ដីកាសម្រេចនេះ អាចប្តឹងជំទាស់បានតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១

**ចៅក្រម**


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់